CEN
CAMBODIA EXPRESS NEWS

# ចំណងដួងចិត្ត

**ប្រលោមលោកក្នុងមនោសញ្ចេតនា**


រៀបរៀងដោយ

**គុយ~ ឡូត**



បោះពុម្ពផ្សាយជាថ្មីដោយ **ស្រី ម៉ិនជន**



**រក្សាសិទ្ធិ**



**ព.ស. ២៥៤៥ គ.ស. ២០០២**

# សេចក្តីផ្តើម

នេះជាប្រលោមលោកផ្នែកខាងទេសចរណ៍មួយ ដែលទើបតែមានជា ដំបូងក្នុងគំនរអក្សរសិល្ប៍ របស់អ្នកនិពន្ធជាតិខ្មែរទាំងឡាយ ។ លំអដ៏សោភ័ណរបស់ដែនមួយ ដែលអ្នកនិពន្ធលើកយកមកពោលនេះ គឺលំអប្រាសាទដ៏អស្ចារ្យរបស់បុព្វបុរសខ្មែរ ដែលអ្នកប្រវត្តិសាស្ត្រសាកល ទទួលស្គាល់និងកោតសរសើរព្រមទាំងកត់ត្រាទុកថា " **វត្ថុអស្ចារ្យទី ៧ នៅក្នុងពិភពលោក** " រូបចម្លាក់និយាយពីមហិទ្ធិឫទ្ធីបូកនឹងក្បាច់រចនា និយាយពីការសប្បាយរីករាយ, បានថែរក្សាជាដរាបនូវប្រវត្តិដើមរបស់យើង ហើយភាពនោះឯងនៅតែរស់រវើកជានិច្ច ក្រោមខ្សែភ្នែកអ្នកប្រវត្តិសាស្ត្រ ទាំងខេមរជាតិ ទាំងបរទេស ។

ក៏ព្រោះតែហេតុនោះ ទើបអ្នកនិពន្ធប្រាថ្នាឱ្យអ្នកអានបានឃើញភាព ដ៏អស្ចារ្យទាំងនោះរបស់ជាតិយើងឱ្យបានគ្រប់គ្នា ដើម្បីយល់តម្លៃនៃអរិយធម៌ ដ៏ថ្កើងរបស់ខ្មែរ ហើយរិតតែរួមចិត្តស្និទ្ធស្រឡាញ់កម្ពុជាជាមាតុភូមិខ្លាំងឡើង ។

ហើយអ្នកនិពន្ធប្រាថ្នាផងទៀត ឱ្យអ្នកអានបានឃើញទីក្រុងថ្មីនៃ សៀមរាប ដែលជាក្រុងសមល្មមដល់ការរាប់អាននៃទេសចរឯប្រជាជននៅ អាណាខេត្តនេះ ក៏សមរម្យជាខ្មែរអ្នកខ្ពស់ប្រពៃគួរឱ្យស្រឡាញ់រាប់រកឥត រង្កៀស ។

ដូច្នេះឯង ទើបគួរណាស់តែលើកសោភណភាពនៃដែនដីពិសិដ្ឋនោះ មកលាតត្រដាងតាមបែបប្រលោមលោក ហើយដើម្បីស្របតាមសោភណភាព នោះ ក៏ត្រូវតែប្រលោមលោកនេះមានចំណងជើងថា " ដែនដួងចិត្ត " យ៉ាងនេះ ។

ទំព័រតទៅ ទោះជាមានការពន្លើសខ្លះក៏ដោយ ប្រលោមលោកនេះក៏ នៅតែមានគំនិតដដែល គឺរក្សានិងរំលេចឡើងនូវ សោភណភាពនោះជាដរាប ។

ភ្នំពេញថ្ងៃ ២៣ កញ្ញា ១៩៦៣

អ្នកនិពន្ធ



គុយ ឡូត
ផែនផ្ពុផចិត្ត

# ដែនដួងចិត្ត

បន្ទាប់ពីពេលធ្វើដំណើរយ៉ាងយូរតាមរថយន្តឈ្នួលដែលលឿនដូចគេ ហោះ ហើយដែលដូចជាមិនសូវឈប់សោះនោះ ខ្ញុំក៏បានមកដល់ទីក្រុងមួយ ។ ឡានបរឆ្លងស្ពានមួយហើយបត់ទៅឆ្វេងតាមដងវិថីទៅឈប់នៅខាងលិចផ្សារ ។ ខ្ញុំដល់ក្រុងសៀមរាបហើយ ។ ពេលនោះខ្ញុំនិងអ្នកដំណើរឯទៀតនាំគ្នាចុះពី លើរថយន្ត ដោយមាននៅដៃខ្លះកាន់ ខ្លះយួរហិបហាយនឹងអីវ៉ាន់ផង ។ អ្នកដំណើរខ្លះគេមានបងប្អូនមកចាំទទួល លុះឃើញគ្នាក៏តាំងប្រវាប្រឱបសំដែង សេចក្ដីរីករាយ រួចរហ័សនាំគ្នាឡើងជិះរទេះសណ្ដោង ដែលយើងហៅថា រ៉ឺម៉ក នោះទៅ ។ ឯខ្ញុំ ខ្ញុំអាសូរខ្លួនបន្តិច ត្បិតគ្មានបងប្អូនឯណាមកចាំទទួលសោះ ។ មិត្តខ្ញុំម្នាក់ឈ្មោះសុវណ្ណ ដែលគេបានសរសេរសំបុត្រ ហៅខ្ញុំមកលេងនោះក៏មិនឃើញមកទទួលដែរ គេមិនដឹងជាខ្ញុំមកទេ ព្រោះខ្ញុំក៏ឥតបានប្រាប់ថ្ងៃខែឱ្យគេ ដឹងដែរ ។ ដូច្នេះខ្ញុំនេះតែម្នាក់ឯងគត់ ដែលមកជាន់ខេត្តថ្មីមួយគ្មានស្គាល់គេ ដល់ម្នាក់សោះ ។ ខ្ញុំយួរហិបស្បែកដើរមករកផ្សារវិញ ។

ពេលនោះថ្ងៃត្រង់ហើយ តែមនុស្សម្នានៅតែមានមីរដេរដាស តាមខ្ញុំ យល់ ជិតដល់ថ្ងៃចូលឆ្នាំគឺវាអ៊ូអរយ៉ាងនេះ ។ ឯបណ្ដាជននោះទៀតសោត សង្កេតទៅពុំមែនមានសុទ្ធតែអ្នកនៅក្រុងនេះទាំងអស់ទេ ត្បិតឃើញមានរថ យន្តផ្ទាល់ខ្លួនទំនើប១ ចតត្រៀបត្រានៅទីនោះ ។ ខ្ញុំឃើញយាមសណ្ដោង ដែល គេហៅថា រ៉ឺម៉កនោះ បររពុយ នាំអ្នកជិះទៅវិញទៅមក ។ ភាពនេះមិនប្លែកពី ក្រុងឯទៀត១ដែលខ្ញុំធ្លាប់ទៅនោះទេ ។

ខ្ញុំចូលទៅភោជនីយដ្ឋានមួយដែលមិនសូវមានមនុស្សប៉ុន្មាន ដើម្បី ទទួលទានអាហារថ្ងៃត្រង់ ។ ខ្ញុំឃ្លានបន្តិចហើយ. . . ព្រោះតាំងពីយប់ម៉ោង ៤ ចេញពីព្រះរាជធានីមកនោះ ខ្ញុំគ្មានអ្វីដាក់ពោះ ក្រៅពីនំប៉័ងមួយ និងទឹកដោះ គោមួយកែវនោះឡើយ ។ មិនមានការចំឡែកទេ ហេតុដែលខ្ញុំមិនចូលទៅផ្ទះ ដែលមានមនុស្សកុះករនោះ មកពីទម្លាប់ម្យ៉ាងរបស់ខ្ញុំដែលមិនចូលចិត្តសភាព អ៊ូអរតែប៉ុណ្ណោះ ។ ពេលចូលទៅអង្គុយលើកៅអីស្រួលបួលហើយ ខ្ញុំបញ្ជាទៅ អ្នកបំរើដែលចាំតែស្ដាប់សេចក្ដីបង្គាប់របស់ខ្ញុំនោះ ឱ្យធ្វើបាយដាក់សាច់មក ។ វាទៅប្រាប់គ្នាវាតទៅទៀត ។ ចន្លោះពេលចាំបាច់មកដល់នោះ ខ្ញុំក៏បើកហិប ស្បែកពិនិត្យមើលថ្នាំសង្កូវនិង ខោអាវក្រែងវាបែកអំពូលផ្សេង១ ព្រោះថា ដំណើរយួរហិបចុះយួរឡើង រលាក់រលែកតាំងពីក្នុងឡានមកដល់នេះ លែងអី នឹងទង្គុករណ្ដំបែកបាក់ ? ខ្ញុំមើលទៅ ! ប្រអប់ម្ជុលចាក់មើលទៅប្រអប់ថ្នាំ ឃើញនៅរៀបរយទាំងអស់ ។ ខ្ញុំបិតហិបទៅវិញ ។

ការដែលមានថ្នាំសង្កូវយ៉ាងនេះ នាំឱ្យគេស្មានថាខ្ញុំជានិស្សិតពេទ្យឬ គ្រូពេទ្យ តែពុំមែនដូច្នោះឡើយ ។ តាមពិត ខ្ញុំគ្រាន់តែធ្លាប់ធ្វើជាលេខាធិការ ពេទ្យកាល់ម៉ែតមួយឆ្នាំតែប៉ុណ្ណោះ ។ ដោយធ្លាប់ដើរតាមលោកគ្រូពេទ្យ នឹង គិលានុបដ្ឋាកខ្លះ និងធ្លាប់បំរើគេខ្លះ ខ្ញុំក៏ឆ្លៀតចំណាំបាននូវមុខថ្នាំរាយរងដូចជា ថ្នាំឈឺក្បាល វិលមុខ ខ្យល់គ ខ្យល់ចាប់អី១ជាដើម ហើយក៏ចេះប្រើម្ជុលបាន ទៀតផង ។ រឿងដែលយកថ្នាំយកម្ជុលមកនេះ វាក៏ជាទំលាប់មួយដែរ ដើរ ស្រុកគេត្រូវតែយកឱសថតាមខ្លួនការពារសេចក្ដីទុក្ខម្ដងម្កាល ។

ពេលដែលខ្ញុំបិទហិបទៅវិញ ក្រោយនោះអ្នកបំរើលើកអាហារយក មកឱ្យ ។ ខ្ញុំជូតចង្កើះជូតស្លាបព្រា ហើយចាប់ទទួលទានដោយស្ងប់ស្ងៀម ។ កង្ហារផ្លិត វិលមិនញាប់ប៉ុន្មាន បាននាំឱ្យកើតខ្យល់រំភើយ១គួររីករាយ ។ បរិ ភោគបណ្ដើរនឹកព្រាងបណ្ដើរថា : អញត្រូវទៅរកសណ្ឋាគារដេកមួយយប់ ស្អែកឡើងសឹមដើររកផ្ទះសុវណ្ណ ។ បើផ្ទះគេធំហើយម៉ែឪគេរាប់អានអញ គេ ហៅឃាត់អញសឹមអញដេកផ្ទះគេ តែបើផ្ទុយពីនេះអញនៅដេកសណ្ឋាគារ រហូតត្រឡប់ទៅវិញ ។ បន្ទាប់ពីគិតដូច្នេះ ក៏បង្ហួសគំនិតដល់ទៅសេចក្ដីសំបុត្ររបស់មិត្តសុវណ្ណ ដែលគេអួតប្រាប់ខ្ញុំថា ក្រុងសៀមរាបរបស់គេនេះមាននារីល្អ មិនចាញ់ក្រុងកំពង់ចាមរបស់ខ្ញុំ ឬក៏ព្រះរាជធានីឬក៏ក្រុងបាត់ដំបងទេ ។ ខ្ញុំក៏ចេះតែគន់ដែរ ហើយនឹងចាំគន់តទៅទៀតចំពោះពាក្យអំនួតរបស់សុវណ្ណ ប៉ុន្តែ ប៉ាន់មើលទៅអ្នកនៅស្រុកនេះ

សុទ្ធៗគ្មានណាមួយឆើតទេ ។ ដែលឆើតនោះ ប្រហែលជាអ្នកដំណើរមកពី ភ្នំពេញ មកពីណាៗមិនដឹង ។ នេះជាការផ្តងនឹក របស់ខ្ញុំត្បិតខ្ញុំយល់ថាគ្មានលំអងណាឱ្យស្មើនឹងលំអភ្នំពេញ បាត់ដំបង កំពង់ ចាមទេ ។

ប៉ុន្តែ ! ប៉ុន្តែ ! ខណៈនោះការផ្តងនឹកនេះត្រូវរលាយខ្សុលទៅភ្លាម ដោយអារម្មណ៍មួយមកប្រត្យក្សនឹងភ្នែក ។ នារីម្នាក់ទ្រទ្រង់ដោយរូបឆើត ឆាយ នាងមានចានស្រាក់នៅដៃដើរចូលមក ។ ខ្ញុំភាំងនឹងអារម្មណ៍ថ្មីនេះមិន តិចឡើយ ។ នាងស្រស់ដើរកាត់មុខខ្ញុំដោយសម្លឹងមុខខ្ញុំបន្តិចក្នុងទំនងធម្មតា របស់មនុស្សដែលមិនស្គាល់គ្នា ហើយដើរហួសទៅក្នុងបង្គាប់ឱ្យគេធ្វើម្ហូបអ្វី ខ្ញុំ មិនអាចដឹងបាន ។

ខ្ញុំពមបាយបណ្តើរ ភ្នែកមើលនាងបណ្តើរ ។ លំអរបស់នាងបង្គាប់ឱ្យ ខ្ញុំភ្លេចនឹកដល់សេចក្តីអៀនខ្មាស ចំពោះអ្នកបំរើពីរបីនាក់ ដែលនៅក្បែរនោះ ឡើយ ។ ខ្ញុំមើលនាងឥតដាក់ភ្នែក ។ ពីក្រោយ ចង្កេះនាងរាងវៀវរីតនឹងជាវ អាវមានជរដូចធ្មេញរណារ ។ អាវ សាច់មិនជាស្តើងក្តោបសាច់ចំឡុករបស់នាង យ៉ាងតឹងនាំឱ្យឃើញខ្សែអាវទ្រនាប់ពីក្នុង ។ ដើមដៃដែលដាក់សំយុងនោះសែន សមនឹងដងខ្លួន ដែលទ្រង់អែនបន្តិច ។ នាងមានសក់វែងមកគ្របសាច់កញ្ចឹង ក រួញក្រញុលខាងចុងបីដូចសំណុំផ្កា ។ ខណៈនោះ ជួនជានាងបែរមកចំ ខ្ញុំក៏រហ័សដាក់ភ្នែកចុះ ។ ខ្ញុំឥតដឹងថានាងមើលខ្ញុំ ឬមិនមើលនោះឡើយ ។ ខ្ញុំងើបឡើង វិញ ឃើញនាងឈរទ្រង់ចំហៀងបន្តិច មើលទៅទីផ្សេង ។ ក៏ជាឱកាសល្អប្រពៃ ហើយ ដែលខ្ញុំបានឃើញនាងពីខាងមុខដូច្នេះ ។ នាងមានទម្រង់មុខមូលទ្រវែង សែនសមនឹងច្រមុះរៀវស្រួច បីដូចគេសិតបង្ហូតតមកលើរង្វង់មាត់តូចល្មមដ៏ មានពណ៌ក្រហមព្រឿងដូចផ្កាកូលាប ។ ចិញ្ចើមទាំងគូ ខ្មៅជិតកោងចុះ គ្រប លើរង្វង់នេត្រដែលខ្មៅដូចនិល ។ ថ្ពាល់ទ្រង់ខួចខាងស្តាំបន្តិច សម្ពស្សម៉ដ្ឋខៃ វិស័យពងមាន់ ។ សរសៃសក់រួញមួយកញ្ចុំត្រង់គុម្ពត្រចៀក ញាំងវង់ភក្ត្រដ៏សមស្រាប់មកនោះឱ្យរឹតតែស្រស់វិសេសឡើងជាងរូបគំនូរទៅទៀត ។ មិនជា តុបតែងខ្លួនទេ នាងពាក់អាវសដៃខ្លី ស្លៀកសំពត់ព្រៃខ្មៅ តែរាងរៅរបស់នាងសែនសង្ហាណាស់ទៅហើយ ។ ទ្រូងទ្រទ្រង់ស្តន់យុគលដែលមូលក្បំ វាសមនឹង ក ដែលមានសម្ពស្សផ្ទរផង់ ដ៏មានខ្សែមាសមួយខ្សែជាអលង្ការ ។

តាមលក្ខណៈរបស់នាង ខ្ញុំស្មានបានថា នាងជានារីមានត្រកូលខ្ពង់ខ្ពស់ ម្នាក់នៅក្នុងអាណាខេត្តនេះ ។ ពេលនេះហើយ ទើបខ្ញុំទទួលចុះចាញ់សំដីរបស់ សុវណ្ណ ។

- មែន សុវណ្ណអើយ គ្នាជឿឯងហើយ ហើយគ្នាយល់ថា ក្រុងរបស់ ឯងឈ្នះក្រុងកំពង់ចាមរបស់គ្នាថែមទៀតផង ។ នេះជាសំដីក្នុងពោះរបស់ខ្ញុំ ដែលប្រុងនឹងឆ្លើយទៅមិត្តសុវណ្ណវិញ បើកាលណាគេសួរថា :

- ម៉េច ចរណៃ ! ឯងសប្បាយទេ ក្រុងសៀមរាបរបស់គ្នា អាចទប់ ទល់នឹងក្រុងកំពង់ចាម បាត់ដំបង និងភ្នំពេញបានទេ ? តាមស្មានសុវណ្ណមិត្តខ្ញុំ ប្រហែលជាសួរដូចខាងលើនេះមិនខាន ។

ក្នុងបរិយាកាសដ៏ស្ងប់ស្ងៀមនោះ នារីនាងក្រលៀសភ្នែកមើលទៅ ថ្នល់ រួចលោតែឧទានស័ព្ទយ៉ាងភ័យតក្កមា :

- អួយ លោកប៉ាខ្ញុំ ! លោកប៉ាខ្ញុំដួល . . .

ហើយនាងប្រញាប់រត់ចេញទៅ ។ ខ្ញុំតាមមើលនាងដោយស្ទួន់ វំពៃ ឃើញបុរសចាស់ម្នាក់ដួលក្រាបទៅលើចិញ្ចើមថ្នល់ ក្បែរឡានមួយ ។ នាងស្រី រត់ដល់លើកត្រកងបុរសនោះ :

- អួយ លោកអើយជួយខ្ញុំផង លោកប៉ាខ្ញុំម៉េចអីចេះ !

នាងហៅគេឯងដោយទឹកមុខភិតភ័យ ។ បុរសជាឪនោះមានឈាម ហូរចេញពីថ្ងាស ដោយដួលប៉ះនឹងចិញ្ចើមថ្នល់យ៉ាងដំណំ ។

ជាមួយនឹងអ្នកដទៃទៀតដែរ ខ្ញុំក៏មកដល់ជនរងគ្រោះ ហើយមិន បង្អង់ ខ្ញុំក៏ចូលទៅត្រកងខ្លួនបុរសនោះឱ្យអង្គុយឡើង ។ គាត់បាត់មាត់ឈឹង ហើយរាងកាយទន់រងាកសាច់ត្រជាក់ ។ ខ្ញុំភ័យជួសនាងស្រីនេះដែរ ខ្លាចគាត់ ខ្យល់គទើបដាក់គាត់ផ្តេកទៅវិញ ហើយរត់មកយកហិបដែលនៅកន្លែងបាយ ។ ខ្ញុំបើកយកថ្នាំបូមដាក់ក្នុងបំពង់បាញ់ជាស្រេចទើបម្នីម្នារត់ទៅវិញ ដោយយក ហិបជាប់ទៅផង ។ មនុស្សរោមជិត ។ ខ្ញុំសុំគេញែកចូលទៅរកជនរងគ្រោះ ដល់ហើយប្រញាប់ចាប់ប្រតិបត្តិការជាបន្ទាន់ ។ អស់មួយបំពង់ថែមមួយបំពង់ទៀត ។

ឯចំណែកនាងស្រីភ័យស្លន់គិតតែយំហៅឪពុក :

- លោកប៉ា ! លោកប៉ា ! លោកអើយជួយខ្ញុំផង ! យីម៉េច អីចឹង ជួយខ្ញុំផងលោក !

- មិនជាអ្វីទេអ្នក ! គាត់នឹងដឹងខ្លួនឥឡូវនេះហើយ ។

ខ្ញុំនិយាយទៅកាន់នាង ជួយបំបាត់សេចក្តីភិតភ័យ ។ នាងទ្រក្បាល ឪពុក និយាយតបនឹងខ្ញុំដោយសម្លេងទប់តែញាប់ :

- លោកអាណិតជួយសង្គ្រោះឪពុកខ្ញុំផង ! យីមានឈាមសន្ធឹកណាស់ លោកអើយ ។

- មិនអីទេ ចាំខ្ញុំរុំមុខរបួសថ្វាសនេះជូនគាត់ ។

និយាយបណ្តើរ ខ្ញុំបើកហិបបណ្តើរយកស្បៃនឹងថ្នាំមករុំ។ ពេលនោះ ជនរងគ្រោះបានកម្រើកខ្លួនហើយថ្ងូរ ។ នាងស្រីក៏ស្រែកហៅទៀត :

- លោកប៉ា ! ម៉េចលោកប៉ា !

- កុំអាលហៅគាត់អ្នក ! គាត់កំពុងអស់កម្លាំងខ្លាំងណាស់ ! មិនអីទេ កាលណាខ្ញុំរុំរបួសថ្វាសហើយ ខ្ញុំនឹងចាក់ថ្នាំលើកកម្លាំងនោះគាត់នឹងអាចក្រោក អង្គុយបាន និយាយបាន !

ខ្ញុំឃាត់នាង ហើយប្រញាប់ចាត់ចែងបិទថ្នាំ នឹងរុំរបួសយ៉ាងត្រឹមត្រូវ តាមក្បួនពេទ្យផង ។

បន្ទាប់ពីកិច្ចនេះខ្ញុំក៏ប្រញាប់រើរកថ្នាំលើកកម្លាំងបូមតាមបំពង់ ហើយ ចាក់ឱ្យអ្នកជម្ងឺថែមទៀត ។

មនុស្សអ្នកនៅជុំវិញ មានបីបួននាក់ចូលជួយរិតច្របាច់ឱ្យអ្នករង គ្រោះ ខ្លះឱ្យយោបល់ថា នាំទៅពេទ្យ ខ្លះថាអស់អីហើយយកទៅផ្ទះទៅ ។ ខ្លះ ក៏បែរជាសួរថា : គាត់វាយ៉ាងម៉េចពីដំបូងនោះ ? សំដីរបស់គេសុទ្ធតែរាងម្លើយ ៗ ទោះជាថាញាប់យ៉ាងណាក៏ដោយស្តាប់ទៅពិរោះម្យ៉ាងដែរ ។ ក្នុងពេលនេះ បុរសមានរបួសថ្ងូរ ហើយប្រឹងងើប ។ ខ្ញុំនិងនាងនារីជួយទ្រស្មាគាត់លើកឡើង ។ គាត់អង្គុយបានហើយមើលទៅមនុស្សដែលឈរព័ទ្ធជុំវិញរួចមើលមុខខ្ញុំ និង កូនស្រីគាត់ ។ នាងប្រញាប់សួរថា :

- លោកប៉ា ! លោកប៉ា បានស្រួលវិញហើយឬ ?

- បានស្រួលហើយកូន ! ហើយក្មួយនេះជាអ្វីកូន ?

- ជាលោកគ្រូពេទ្យប៉ា គឺលោកនេះហើយដែលចាក់ថ្នាំជូនប៉ា រុំមុខ របួសជូនប៉ា មើលប៉ាទាល់ជា ! កូនភ័យណាស់ប៉ាអើយ ។

- អ៎, ខ្ញុំអរគុណហើយលោកគ្រូពេទ្យ ! បាទ ! បាទ !

ខ្ញុំតបនឹងវាចាអ្នករបួសជាប្រញាប់ ។ ខ្ញុំចង់និយាយប្រាប់គាត់វិញថា : ខ្ញុំពុំមែនជាគ្រូពេទ្យទេ ។ តែខ្ញុំត្រូវខាននិយាយនាំឱ្យរឿងវែងដូច្នោះខ្ញុំបែរជា និយាយពីរឿងគាត់ទៅវិញ ។

លោកអ៊ំអាចអញ្ជើញទៅផ្ទះបានហើយ

ខ្ញុំមើលមុខឆោមនារីដែលនៅជិតខ្ញុំ ។

- អ្នកគួរនាំគាត់ទៅផ្ទះពេលនេះ, អ្នកដាក់រ៉ឺម៉កទៅក៏បាន ដាក់ឡាន នេះទៅក៏បាន ! ឡាននេះជារបស់អ្នកឬ ? (ខ្ញុំចង្អុលទៅឡានដែលនៅក្បែរ នោះ) ។

- ចាស ! តែគ្មាននរណាបើក, បងប្រុសខ្ញុំគាត់នៅឯផ្ទះឥតដឹងហេតុ នេះទេចាស ។

- ចុះកាលដែលមកនរណាបើក ? (ជនចំណាស់ម្នាក់សួរឡើងពី ក្រោយខ្នងនាង)

- ចាស មកនេះ លោកពុកខ្ញុំគាត់បើកខ្លួនឯង . . .

- គាត់មករកអ្វី គាត់មិនដឹងជាមិនស្រួលខ្លួនទេឬនាង !

- ចាស គាត់ដឹងដែរ ត្បិតល្ងាចមិញគាត់ឈឺក្បាលវិលមុខ កោស ខ្យល់ក្រហមពេញខ្លួន ។ តែគាត់នឹកថា : មិនអីទេ គាត់ចង់ពិសាគុយទាវពោះ គោ គាត់បើកឡាននាំខ្ញុំមកទីនេះតែម្តង ខ្ញុំធានានឹងជិះរ៉ឺម៉កមកទិញម្នាក់ឯង តែគាត់មិនព្រមចាស . . .

- ផ្ទះអ្នកនៅឆ្ងាយឬ ?

ខ្ញុំបានសួរនាងឡើងក្នុងគោលបំណងចង់សង្គ្រោះ ។

- ចាស ឆ្ងាយគ្រាន់ដែរលោក !

- អ្នកប្រញាប់នាំគាត់ទៅភ្លាមទៅ ថ្ងៃក្ដៅណាស់ !

- មែនប្រញាប់នាំគាត់ទៅភ្លាមទៅ ! ហាកយើងបើកផ្លូវឱ្យគាត់ចេញ ផង ! ។ (មនុស្សម្នាក់ពោលដោយទឹកចិត្តឈឺឆ្អាល ) ។ អ្នករ៉ឺម៉កខ្លះដែលជា អ្នកបានដឹងហេតុនេះដែរប្រញាប់ចូលមក ។

- សូមដាក់រ៉ឺម៉កខ្ញុំនេះមក !

- ឯណេះក៏បាន រ៉ឺម៉កខ្ញុំនេះជិតស្រាប់ ។ ម្នាក់ទៀតនិយាយ ហើយម្ទី ម្នាអូសយានមក ។ ខ្ញុំនិងនាងគ្រាហ៍បុរស ដែលមានរាងកាយទ្រែមទ្រមដាក់លើ យាន ។ ពេលដែលគ្រាហ៍ទប់ខ្លួនឪពុក នាងដៃនាង នឹងខ្ញុំប៉ះគ្នា ។ ដៃរបស់នាង និងខ្ញុំ ប្រហែលជាបានប៉ះពាល់គ្នាតាំងពីពេលឪពុកនាងដេកស្ដូកស្ដឹងនោះផង ត្បិតការលូកត្រកងលើកគាត់នោះ យើងធ្វើការនេះដោយស្និទ្ធស្នាលណាស់ ។ កាលនោះដោយរវល់នឹងភយារម្មណ៍ ក៏គ្មានអ្វីជាសំគាល់បានសម្រាប់មនោ សញ្ចេតនាដូចគ្រានេះទេ ។ ពេលនេះខ្ញុំមានអាការរំភើប ព្រោះបរិយាកាសធូរទូលាយហើយ ។ ចំណែកនាងវិញ ខ្ញុំយល់ថា នាងពុំដូចខ្ញុំទេ ត្បិតស្មារតីនាងគឺ មូលតែទៅលើរូបឪពុករបស់នាង ។ តែទោះជាយ៉ាងណាក៏ដោយហោចណាស់ នាងក៏គង់ដឹងខ្លួនថា ហត្ថដ៏ទ្រលុកទ្រលន់របស់ នាងត្រូវមានគេសម្ផស្សដែរ ហើយ ។

ឡើងរ៉ឺម៉កស្រួលបួលហើយ នាងងាកមកគួរសមនឹងខ្ញុំ

- ជំរាបលា លោកសិនហើយចាស !

- បាទអញ្ជើញអ្នក ! អ្នកកុំភ្លេចលាងមុខរបួសជូនលោកអ៊ុំផង ។

- ខ្ញុំអរគុណលោកគ្រូពេទ្យហើយ ( បុរសចាស់និយាយកាន់ខ្ញុំ) ខ្ញុំ ជំរាបលាលោកគ្រូពេទ្យសិនហើយ ចាំល្ងាចខ្ញុំឱ្យកូនប្រុសខ្ញុំមកអញ្ជើញលោកគ្រូ ពេទ្យទៅឱ្យស្គាល់ផ្ទះខ្ញុំម្ដង ។ លោកសំណាក់ឯណា ?

- បាទ ខ្ញុំជាអ្នកចម្ងាយទេលោកអ៊ំ ! ល្ងាចនេះសំណាក់នៅសណ្ឋាគារ បាទ !

- បាទ ល្ងាចនេះចាំឱ្យកូនប្រុសខ្ញុំមកអញ្ជើញលោកគ្រូពេទ្យ ?

រ៉ឺម៉កភោទីម៉ាស៊ីនងោងឡើង ហើយបើកបរទៅចោលមនុស្សមួយហ្វូង ឱ្យឈរតាមមើលពីក្រោយ ។ ខ្ញុំឈរមើលទាល់តែយាននោះបត់ទៅបាត់ទើប យួរហិបត្រឡប់មកកន្លែងបាយវិញ ។

ថៅកែផ្ទះលក់បាយ គាត់មានចំណាស់បន្តិចហើយ មុខមាត់ជាកូនចៅ ចិន តែចេះខ្មែរយ៉ាងច្បាស់លាស់ហើយម្ល៉ើយ១ ដូចអ្នកសៀមរាបសុទ្ធសាធ ។ គាត់អង្គុយនឹងតុខ្ញុំសំដែងសេចក្ដីគួរសម :

- លោកគ្រូពេទ្យនៅភ្នំពេញ អញ្ជើញមកលេងសៀមរាបឬ ?

បាទ ថៅកែ ! ខ្ញុំចង់ស្គាល់អង្គរនឹងគេម្ដង ។

បាទ សប្បាយណាស់លោកគ្រូពេទ្យ ។ អូ ! លោកចង់ ពិសាអីទៀត ខ្ញុំបង្គាប់ឱ្យគេធ្វើ ។

- បាទ បានហើយ ខ្ញុំដូចជាបាត់ឃ្លានទៅហើយព្រោះតែហេតុ អម្បាញ់មិញនោះ ។

លោកគ្រូពេទ្យចិត្តល្អណាស់ កុំតែបានលោកកុំអីអ្នកនោះឯង វីវរតែ ម្ដងហើយ ។

ក៏ជាឱកាសសម្រាប់ខ្ញុំចង់ដឹងពតិមានខ្លះ ។

- អត់ទោសថៅកែ ថៅកែស្គាល់អ្នករងគ្រោះអម្បាញ់មិញនេះទេ ?

- បាទ ស្គាល់ដែរ គាត់ឈ្មោះសួន ជាចៅហ្វាយស្រុក ពីដើមផ្ទះគាត់ នៅមុខអង្គរឯណោះ ។ គាត់មានកូនប្រុសពីរនាក់ និង កូនស្រីម្នាក់ដែលមកជា មួយនេះ ។

ខ្ញុំស្គាល់ហើយចង់ឱ្យគាត់បន្តទៅទៀត ។ ខ្ញុំលើកប៉ាន់បំរុងចាក់ តែ តែលោកថៅកែរហ័សឃាត់ថា :

ឈប់លោក ! កុំពិសាតែនេះ វាត្រជាក់ហើយ ចាំខ្ញុំឱ្យគេយកប៉ាន់ថ្មី មកជូន ។

គាត់ងាកទៅក្រោយខ្នង ។ ស្រីម្នាក់អាយុប្រមាណជាង ៣០ឆ្នាំ រាង ស្គម ប្រជឹតអង្គុយក្បែរនោះ គាត់បង្គាប់ថា :

- វ៉ាន- ទៅយកប៉ាន់ថ្មីមកជូនលោក !

ស្រីនោះចូលទៅក្នុង ចេញមកវិញបានប៉ាន់ថ្មីមកឱ្យខ្ញុំ ។ ខ្ញុំទទួល ហើយថ្លែងអំណរៈ

- អរគុណ !

- ចាស !

ស្រីបំរើទទួលចាស ! ដោយញញឹម រួចថយខ្លួនចូលក្នុងបាត់ទៅវិញ ។

កំបាំងពីមុខស្រីនោះហើយ ខ្ញុំចាប់សួរពតិមានតទៅទៀត ។

- អត់ទោសថៅកែ នាងនោះមានប្ដីហើយឬនៅ ?

ថៅកែសម្លឹងមុខខ្ញុំហើយតបភ្លាមថា :

- បាទលោក នាងនេះមានប្ដីហើយ ហើយមានកូនពីរផង ។

ឮតែមានប្ដីមានកូនដូច្នោះ ខ្ញុំកើតខកចិត្តយ៉ាងខ្លាំង ។ ទឹកអស់សង្ឃឹម រលីងធេង ដកដង្ហើមធំយ៉ាងវែងឱ្យធូរបន្តិច ទើបបន្ទប់អាការៈនេះដោយ និយាយនឹងអ្នកផ្ទះទៀត :

- យី សាច់នាងនៅចាំណាស់ហ្ន៎ ! នៅដូចក្រមុំស្មោះ ។ ខ្ញុំមិនដែល ឃើញស្រីណាសាច់ល្អដូចនាងនេះទេថៅកែ !

គ្រានោះទឹកមុខអ្នកម្ចាស់ផ្ទះ ប្រែពីរីករាយបែរជាចងចិញ្ចើមជាសញ្ញា ងឿងឆ្ងល់ សួរមកខ្ញុំ :

- វាស្គមតឹតរខីតដូចកើតរបេងយ៉ាងនេះ ម្ដេចលោកគ្រូពេទ្យមើល ទៅឃើញថា ដូចក្រមុំទៅវិញ លោកគ្រូពេទ្យចង់សួរពីនាងឯណា ?

ខ្ញុំក៏បែរជាឆ្ងល់នឹងពាក្យអ្នកផ្ទះដែរ ត្រឡប់សួរវិញ :

- លោកថៅកែចង់ថាពីនាងណា ? ឯខ្ញុំ ខ្ញុំសួរពីនាងកូនចៅហ្វាយ ស្រុកនោះទេតើ ។

អ្នកផ្ទះសើចយឺកឡើងនិយាយថា :

- អឺចុះទេអី ខ្ញុំស្មានតែលោកគ្រូពេទ្យសួរពីនាងដែលវាយកប៉ាន់តែ មកជូនអម្បាញ់មិញ !

- ទេ ខ្ញុំមិនមែនសួរពីមីងសំគមអម្បាញ់មិញនេះទេ ខ្ញុំមើលគាត់មិន យល់ឬ រាងរៅគាត់ដូច្នេះ ។

- លោកគ្រូពេទ្យមិនគិតថាឱ្យច្បាស់ ។

គាត់សើចម្ដងទៀត ខ្ញុំក៏សើចតាមទាំងសោះកក្រោះ ។ គាត់លើក ប៉ាន់តែចាក់ទៅក្នុងពែង ហើយនិយាយយឺត១ ធ្វើឱ្យខ្ញុំតឹងចិត្តនឹងស្ដាប់ :

- លោកគ្រូពេទ្យ ! តាមខ្ញុំដឹង (គាត់វាលើកពែងផ្ដុំទឹកក្ដៅ ហើយ ដាក់ទៅវិញ )តាមខ្ញុំដឹងនាងកូនលោកចៅហ្វាយ ស្រុកអម្បាញ់មិញនេះ នាងនៃ . . .

នាងនៅមិនទាន់មានប្ដីទេឬ ថៅកែ ? (ខ្ញុំសួរគាត់ដោយចង់ដឹងលទ្ធ ផលជាបន្ទាន់ ) ។

- បាទ នាងនៅក្រមុំទេ លោកគ្រូពេទ្យ

ខ្ញុំដកដង្ហើម ឃូ . . . ម្ដងទៀត ហើយផ្អែកខ្នងទៅកៅអី ។ ដើមទ្រូង ដូចជាធូរទៅវិញ ។ ហើយដើម្បីកុំឱ្យអ្នកផ្ទះដឹងថាខ្ញុំមានគំនិតលាក់បាំងអ្វីម្យ៉ាង នោះ ខ្ញុំចាប់និយាយថា :

- មិនមែនជាការធំដុំទេលោកថៅកែ ខ្ញុំសួរគ្រាន់តែជាពាក្យនិយាយ លេងនឹងថៅកែតែប៉ុណ្ណោះ ។ ហើយឥឡូវខ្ញុំគិតសូមលាលោកថៅកែសិនហើយ !

ខ្ញុំលូកកាបូប ហៅអ្នកបំរើមកគិតលុយរួចងើបឡើង ។ ថៅកែម្ចាស់ ផ្ទះក៏ឈរដែរ ។

កាលបើឱ្យលុយទៅអ្នកបំរើហើយ ខ្ញុំក៏ចាប់ហិបស្បែកយួរចេញមក ។ លោកថៅកែជូនដំណើរជាការគួរសម ។

- លោកគ្រូពេទ្យគិតទៅសំណាក់ឯណា ?

- បាទ គិតទៅសំណាក់ឯសណ្ឋាគារ ! តើសណ្ឋាគារណាស្រួលលោក ថៅកែ ?

- ណាក៏ស្រួលដែរលោកគ្រូពេទ្យ ប៉ុន្តែបើសណ្ឋាគារឈ្មោះ សន្តិភាព ស្រួលម្យ៉ាង ត្បិតនៅក្បែរផ្លូវទៅអង្គរស្រាប់ ។

- នៅឯណាទៅ សណ្ឋាគារនោះលោកថៅកែ ?

- បាទ លោកគ្រូពេទ្យសួរតែពួករ៉ឺម៉ក វានាំទៅដល់ហើយ បាទ !

កាលនោះអ្នកធាក់រ៉ឺម៉កម្នាក់ ប្រហែលជាដឹងថា យើងកំពុងនិយាយ ផ្ទាពីដំណើរទៅណាមកណា ក៏ប្រញាប់អូសយានចូលមកដោះមួកសួរខ្ញុំ :

- លោកអញ្ជើញទៅណាទាន ?

ថៅកែឆ្លើយកាត់ឡើង :

- ជូនលោកគ្រូពេទ្យទៅសណ្ឋាគារសន្តិភាព !

- បាទ សូមអញ្ជើញ !

ខ្ញុំលើកហិបដាក់លើយាន អង្គុយស្រួលបួលហើយ ក៏និយាយគួរសម ទៅនឹងថៅកែទៀត :

- ខ្ញុំជំរាបលាលោកសិនហើយលោកថៅកែ !

- បាទ អញ្ជើញចុះលោកគ្រូពេទ្យ !

រ៉ឺម៉កដែលខ្ញុំជិះនេះធាក់ដោយជើង ។ អ្នកធាក់មុនដំបូងគាត់ចំកោង ខ្នងយ៉ាងប្រឹង ។ លុះយានមានល្បឿនបន្តិចហើយ គាត់ធាក់ដោយធម្មតាវិញ ។ គាត់នាំខ្ញុំតាមផ្លូវមួយវែង ដែលមានផ្ទះថ្មអមសងខាង ។ មើលទៅមិនអន់ថយ ជាងភាគខ្លះនៃព្រះរាជធានីទេ ។

មួយសន្ទុះក្រោយមក គាត់នាំខ្ញុំទៅដល់អាគារមួយយ៉ាងធំដ៏មានជាន់ កណ្តាលសរសេរអក្សរមូលជាភាសាខ្មែរថា : សណ្ឋាគារសន្តិភាព ។ យីហោ នេះមើលទៅសែនសង្ហាណាស់ ។

ខ្ញុំចុះពីយាន លូកលុយឱ្យកម្មករធាក់រ៉ឺម៉ក :

- ប៉ុន្មានរៀលពូ ?

- បាទ សុំ ៤ រៀលលោក !

- ណ្ហើយ ខ្ញុំជូន ៥ រៀល ព្រោះឃើញពូឯងធាក់នឹងជើង មើលទៅដូច ជាវេទនាភ្នែកណាស់ !

- បាទ ខ្ញុំអរគុណលោកច្រើនហើយ !

ទទួលលុយហើយ ពូរ៉ឺម៉កជួយលើកហិបខ្ញុំ :

- ខ្ញុំសូមជូនដំណើរលោកដល់ក្នុងទាន !

- បាទ មិនអីទេពូ ស្រាលទេ ខ្ញុំយួរបានហើយ ពូត្រឡប់ទៅវិញចុះ ។

ខ្ញុំយកហិបពីដៃអ្នកធាក់រ៉ឺម៉កមកវិញ ហើយយួរដើរចូលទៅក្នុង កន្លែងចូលបន្ទប់ ។

មនុស្សពីរបីនាក់កំពុងសាកសួរថ្លៃបន្ទប់ដែរ ប្រហែលគេជាអ្នក ដំណើរដូចខ្ញុំដែរ ។ ខ្ញុំឈរចាំបន្តិចលុះអ្នកអស់នោះរួចរាល់ហើយ ខ្ញុំចូលទៅ :

- មានសល់បន្ទប់ទំនេរទេហ៊ា ?

ខ្ញុំសួរទៅអ្នកលក់សំបុត្រ ដែលមានមុខមាត់ជាកូនចៅចិន ។ គេឆ្លើយ ថា :

- មានលោក ជាន់ទី២ នៅសល់បីបន្ទប់ លោកអញ្ជើញមើល ( គេ បង្ហាញតារាង)

នែ, នៅសល់បន្ទប់លេខ ១៧ លេខ ២០ លេខ ២២

- ដាក់ឱ្យខ្ញុំមួយបន្ទប់មក លេខប៉ុន្មានក៏បាន !

- បាទ បើអីចឹងលេខ ១៧ ចុះត្បិតនៅក្បែរជណ្តើរស្រាប់ ស្រណុក លោកឡើងចុះ ! បាទ លោកគិតសំណាក់ប៉ុន្មានថ្ងៃទាន ?

- ថ្ងៃនេះនិងយប់នេះសិនចុះ ថ្ងៃស្អែកសឹមគិតគ្នាទៀត

- បាទ បើអីចឹងសុំកាតឌីដង់ទីតេលោកបន្តិច !

ខ្ញុំលូកហោប៉ៅយកអត្តសញ្ញាប័ណ្ណ ហុចទៅឱ្យអ្នកលក់ ។ គេយកទៅ កត់ត្រារួចរាល់ក៏ហុចមកខ្ញុំវិញ ម្នាក់ទៀតគេនាំខ្ញុំឡើងទៅលើ, ដល់បន្ទប់នោះ ហើយ អ្នកនោះចាប់ផ្តើមបើកទ្វាររួចនាំខ្ញុំចូលទៅក្នុង ។ ក្រោយពេលដែលណែ នាំខ្ញុំឱ្យស្គាល់បន្ទប់សំអាង និង កន្លែងបាំងគន(១០) ព្រមទាំងបន្ទប់ទឹកហើយ គេឱ្យកូនសោមកខ្ញុំ រួចលាខ្ញុំចេញទៅវិញ ។

បន្ទប់នេះមានផាសុកភាពណាស់ មិនខុសពីបន្ទប់សណ្ឋាគារទំនើប១ នៅភ្នំពេញទេ ។

ខ្ញុំផ្តើមផ្លាស់សំលៀកបំពាក់ រួចចូលទៅកាន់បន្ទប់ទឹកងូតទឹក ដែល

---

(១) ក្លាយមកពីបង្គន់

---

រោយសាចពីលើមកដោយប្រអប់ទន្លេប៉ែន ។ រួចពីនោះ ខ្ញុំស្លៀកពាក់ខោអាវ ដំណោកដើរទៅបើកកង្ហារឱ្យវិលមួយ១ ទើបមកប្រះដេក លើពូកដ៏ទន់ល្មើយ វិញ្ញាណខ្ញុំស្រមើលស្រមៃទៅតាមអារម្មណ៍ផ្សេង១ ជាពិសេសរូបារម្មណ៍របស់ ស្រីក្រមុំនោះឯង ។ ប៉ុន្តែនាទីក្រោយមក ដោយការអស់កម្លាំង នឹងក្តៅមុខក្តៅ មាត់ ក្នុងដំណើរដ៏វែងឆ្ងាយមកនេះ ខ្ញុំក៏លង់លក់ស្រួលទៅតែម្តង ។

ខ្ញុំពុំប្រាកដថា លក់បានប៉ុន្មានម៉ោងទេ ភ្ញាក់ឡើងក៏ស្រាប់តែសែងអគ្គិ សនីភ្លឺព្រាតតែម្តង ។ ខ្ញុំលើកនាឡិកាដៃមើល ឃើញម៉ោង ៧គត់ ។ ឱចូលយប់ ហើយ យីខ្ញុំដំណេកស្រួលណាស់តើ ! ដេកមួយកំណាត់ថ្ងៃតែម្តង តែមកពីហត់ នឿយពេក ពេលនេះទើបនឹកឃ្លានបាយ ។ ឯការងងុយនៅតែមានពិសនៅ ឡើយ ខ្ញុំស្ទាបហ៊ាមយ៉ាងវែង ដោយឥតក្រែងនរណា ។ ស្រាប់តែងើបអង្គុយ ឡើងខ្ញុំភ្ញាក់ព្រើត ព្រោះឃើញនាងក្រមុំនោះនៅឈរប្រេបជញ្ជាំងទូ ។ ខ្ញុំងើប ឈរជូតភ្នែកពិនិត្យឱ្យច្បាស់ក្រែងស្រវាំងមមើមមាយអី ប៉ុន្តែមិនមែនច្រឡំទេ គឺជាមនុស្សមែន គឺជារូបនាងមែន ។ នាងស្លៀកសំពត់ខ្មៅដូចមុន តែអាវពណ៌ ផ្កាឈូក ត្រូវនឹងពន្លឺភ្លើងទៅក៏ចាំងស៊ីសម្បុរយ៉ាងស្រស់ ។ ខ្ញុំមើលភាំង នឹក អស្ចារ្យនឹងសំណាងខ្ញុំ ដែលបានឃើញនាងទាំងឥតព្រាងយ៉ាងនេះ ។ ខ្ញុំមើល ទៅទ្វារ ដែលប្រហែលជាខ្ញុំភ្លេចបិទ ទើបនាងអាចចូលមកដល់ទីនេះដោយសេរី ។ ខ្ញុំងាកមកនាងវិញ :

- អ្នកអញ្ជើញមកដល់យូរហើយឬ អត់ទោស

នាងឆ្លើយទ្រង់អៀនថា :

- ចាស ! ខ្ញុំទើបមកដល់ទេ ប្រហែលជា ១០ មីនុតប៉ុណ្ណោះ ចាស ។

- ១០ មីនុតហើយ យូរដែរ ម៉េចអ្នកមិនដាស់ខ្ញុំភ្លាម ? ហើយម៉េច ទៅ លោកអ៊ំគាត់យ៉ាងណាទៅ ?

- ចាស លោកប៉ាខ្ញុំបានស្រួលហើយ គាត់ឱ្យខ្ញុំនិងបងខ្ញុំមក តាមអញ្ជើញលោកទៅលេង ។ ខ្ញុំឃើញលោកសម្រាន្តបែបលក់ស្រួល ណាស់មិនហ៊ានដាស់ ទើបសុខចិត្តឈរចាំបន្តិចទៅ ។

- ដូច្នោះបងអ្នកគាត់នៅឯណា ?

- គាត់ចុះទៅវិញបាត់អម្បាញ់មិញ ត្បិតគាត់យល់ថា លោកពុំងាយ នឹងភ្ញាក់ទេ ឥឡូវប្រហែលជាគាត់នៅចាំងដឹងណោះហើយ ចាស ។

នាងតបរួចដាក់មុខមើលក្រឡាអិដ្ឋ ។ ខ្ញុំនឹកពេញចិត្តនឹងទឹកសម្លេង នាងមិនតិចទេ ។

- ចុះអ្នកម៉េចក៏មករកខ្ញុំឃើញ ?

- ចាស មុនដំបូងខ្ញុំសួរថៅកែហួតលក់បាយនៅផ្សារ គាត់ប្រាប់ខ្ញុំថា លោកមកសំណាក់នៅទីនេះ ទើបខ្ញុំមករកឃើញនេះចាស

បន្ទាប់និងបានឆ្លើយ ហើយនាងដើរសន្សឹម១ទៅកាន់មាត់ទ្វារ ។ ឯខ្ញុំ ចូលទៅបន្ទប់ទឹក ។ ខ្ញុំពុំហ៊ានងូតទឹកទេ ព្រោះខ្លាចនាងចាំយូរ គ្រាន់តែលុបមុខ ហើយចេញមកវិញភ្លាម ។ ពេលនោះនាង ចេញផុតបាត់ទៅហើយ ប្រហែលជា នៅចាំខ្ញុំឯក្រៅ ឬឯក្រោមឯណោះ ។ ខ្ញុំប្រញាប់សិតសក់ ស្លៀកពាក់ហើយ ចេញមកមើលទៅ ឃើញនៅឯក្រោមមែនជាមួយប្រុសម្នាក់ ។ បុរសនោះ មើលទៅ មិនមែនបងខ្ញុំប៉ុន្មានទេ ប្រហែលជាស្របាលខ្ញុំ ឬក៏បើថាបង បងពីរ បីឆ្នាំប៉ុណ្ណោះ ព្រោះសាច់ឈាមនៅជាយុវជននៅឡើយ ។ ដោយសំគាល់ថា គេ ជាបងរបស់នាង ខ្ញុំក៏តោងតែរហ័សគួរសមមុខ :

- ជំរាបសួរលោក

- បាទ

គេលើកដៃសំពះតបវិញ រួចឈោងដៃមកចាប់ដៃខ្ញុំតាមរបៀបអឺរ៉ុប ថែមទៀត ។

- ខ្ញុំពុំហ៊ានដាស់លោកគ្រូពេទ្យ ទើបខ្ញុំចុះមកឈរចាំឯណោះ ជជែក លេងនឹងសម្លាញ់ម្នាក់ ដែលទើបជួបគ្នាអម្បាញ់មិញនេះ ។ ឥឡូវគេទៅផ្សារ បន្តិចគេនឹងត្រឡប់មកវិញឥឡូវហើយ ។ គេចង់ស្គាល់លោកគ្រូពេទ្យដែរ ។

- បាទ ខ្ញុំមិនស្គាល់មិត្តលោកដែរ បើអីចឹងយើងចាំគេបន្តិចទៅ ។

- បាទ ហើយគេក៏នឹងទៅផ្ទះខ្ញុំដែរ ដើម្បីសួរជម្ងឺប៉ាខ្ញុំ ។

កំពុងសន្ទនានោះនាងស្រីក៏ឧទានឡើង :

- ហ្នំ ! លោកសុវណ្ណមិនអីនុះ . . .

ខ្ញុំនិងបងប្រុសនាងមើលទៅ ក៏ឃើញមិត្តនោះឯងឆ្លងថ្នល់មកមែន ។ ខ្ញុំទៅជាស្រឡាំងកាំងបន្តិចព្រោះស្គាល់ច្បាស់ជាសុវណ្ណ មិត្តរបស់ខ្ញុំ ។ យី អញ ដូចយល់សប្តិទេឬអី បានជាផ្លាស់ប្តូរតួភ្លាម១ដូច្នេះនេះ ។ គេមកដល់នាំទាំងទឹក មុខរីករាយមកផង :

- យើ ចរណៃតើ ! ឯងមើលមកស្មានតែពីណា ក្នាឯងសោះ . . .

យើងចាប់ដៃរលាក់គ្នាបន្តិច សុវណ្ណនិយាយត :

ឯងទើបមកដល់ឬចរណៃ ? ឯងមានឃើញសំបុត្រគ្នាទេ ? ហើយឯង ម៉េចមិនឱ្យដំណឹងគ្នាដឹងមុនផង ?

- គ្នាយល់ថា ជាការរំខានដល់ឯង ទើបគ្នាមកស្ងាត់១អីចឹង ! សុវណ្ណងាកទៅកាន់បងរបស់នាងស្រី :

- នែ វង្ស, នេះជាមិត្តជិតស្និទ្ធរបស់ខ្ញុំកាលរៀននៅលិសេ្យ ស៊ីសុវត្ថិ ជាមួយគ្នា ។ គេឈ្មោះចរណៃ ។ សូមឯងទទួលរាប់អានទៅ គ្នាយើងទេ សម្លាញ់ ។

- អើ យើងក៏បានស្គាល់គ្នាហើយដែរសុវណ្ណ ! បើអីចុះ ស្រួលហើយ ស្គាល់នៅឯណា ?

- ស្គាល់នៅនេះតែម្តង ! ល្ហើយចាំទៅផ្ទះសឹមនិយាយទៀត ឡើង ឡានមក ! ប៉ាយើងទន្ទឹងល្ហោចហើយ ។ លោក (គេនិយាយមកកាន់ខ្ញុំ) សុំ អញ្ជើញខាងក្រោយ ។ អារី ! (គេនិយាយបង្គាប់ ទៅនាងស្រី ) នៅខាងក្រោយជាមួយលោកចុះ ។ ខ្ញុំនិងនាងក្រមុំ ប្រតិបត្តិតាមភ្លាម ។ តែខ្ញុំ មិនហ៊ានជិតនាងទេ នាងក៏ដូច្នោះដែរ យើងអង្គុយឃ្លាតពីគ្នា ទុកចន្លោះពូក កណ្តាល ។ ឯខណៈនោះសុវណ្ណ នៅវារវែកមិនទាន់ឡើងឡានទេ គេមើលទៅ លើសណ្ឋាគារ :

- នែវង្ស ! ក្រែងឯងថាមកទទួលលោកគ្រូពេទ្យឬ ? ឥឡូវលោក គ្រូពេទ្យនោះភ្ញាក់ហើយឬនៅ ម៉េចមិនដាស់គាត់ !

នាងស្រីដែលនៅក្បែរខ្ញុំសើចឡើង ឯបងប្រុសនោះក៏សើចដែរ :

- គ្រូពេទ្យឯណាទៀត ? គ្រូពេទ្យនៅក្នុងឡាននេះហើយតើ មក ឡើងមក !

- អូ គេនេះជាគ្រូពេទ្យឬ ? ឯងស្មានគ្រូពេទ្យណា យី ចរណៃជាគ្រូ ពេទ្យផង ។

ថាហើយទើបព្រមចូលរថយន្ត ។ ខ្ញុំគ្មានតបអ្វីទេ នឹងថាចាំអញទៅ និយាយឱ្យគេស្គាល់ផ្ទះឯណោះតែម្តងទៅ ។ រថយន្តរំកិលខ្លួនចេញពីមុខសណ្ឋាគារ ទៅតាមវិថីមួយដ៏មានសែងអគ្គិសនី ខ្ញុំរំពៃមើលគេហស្ថាននានា ឃើញដូច ជាទីក្រុងណាមួយដែរ ។ ផុតពីភ្លើងច្រើនដល់ភ្លើងតិច ។ នៅខាងមុខភ្លើងឡាន សាចពន្លឺសព្រាតទៅលើថ្នល់ ។ មួយរំពេចនោះរថយន្តបង្អង់ រួចបត់ចូលទៅតាមទ្វាររបងដែលចំហស្រាប់ ទៅឈប់នៅក្បែរជណ្តើរនៃគេហដ្ឋានមួយ ។ ខ្ញុំ មើលទៅមាត់ជណ្តើរក៏ឃើញប្រុសម្នាក់និងស្រីម្នាក់ព្រមទាំងក្មេងតូចៗជា ច្រើនផង ។ ខ្ញុំចាប់យល់ថា ប្រុសស្រីនោះ ជាកូនលោកចៅហ្វាយស្រុកហើយ ឯក្មេងទាំងនោះគឺជាចៅគាត់ ។ មែនហើយព្រោះវាបានស្រែកមករក វង្ស និង នាងវី លោកមា លោកមីងមកវិញហើយ ! ឯអ្នកទាំងពីរនោះក៏និយាយមកដែរ ថា : ម៉េចអូនវង្ស និងអូនវីទៅយូរម្ល៉េះ ។

ខណៈនោះខ្ញុំបានទទួលនូវសេចក្តីរាប់អានរាក់ទាក់ពីអ្នកទាំងពីរនេះ គេនាំខ្ញុំចូលទៅក្នុងផ្ទះ ។ ស្រីដ៏មានចំណាស់អាយុប្រមាណជា ៥០ ផ្លាយ នៅ អង្គុយលើក្តារជឿប្រេបនឹងអ្នកជម្ងឺ ដែលខ្ញុំបានសង្គ្រោះពីថ្ងៃ កាលបើឃើញខ្ញុំក៏ ម្ទីម្នាងើបទទួល ។ ឯខ្ញុំត្រូវតែប្រញាប់គួរសមទៅគាត់មុន :

- សូមក្រាបប្រណិប័តន៍លោកអ៊ំ !

- ចាស លើកដៃថ្វាយព្រះលោកគ្រូពេទ្យ !

- បាទ លើកដៃថ្វាយព្រះ ។

គេហជនទាំងពីររហ័សតបមកខ្ញុំវិញ ស្ទើរតែស្របគ្នា ។ សុវណ្ណ មិត្ត ខ្ញុំក៏ជំរាបសួរគាត់ភ្លាមដែរ ។ អ្នកផ្ទះពេលនោះពោរពេញដោយសេចក្តីរីករាយ និងរាក់ទាក់ ។ នាងកញ្ញាលើកកៅអីឱ្យខ្ញុំ ។ មុននឹងខ្ញុំ ក៏ចាប់ពិនិត្យអ្នកជម្ងឺ អង្គុយ ។

- បានស្រួលមែនទែនហើយឬលោកអ៊ំ ?

- បាទនៅបែបធេងធោងបន្តិចលោកគ្រូពេទ្យ ។

ខ្ញុំអង្គុយស្រួល ហើយស្រីចាស់ម្ចាស់ផ្ទះសួរខ្ញុំ :

- មានថ្នាំអ្វីទៀតទេលោកគ្រូពេទ្យ ? សូមលោកជួយព្យាបាលឱ្យ ទាន់ផងទៅចុះ ព្រោះខ្ញុំវាមិនយល់ថ្នាំចាក់ថ្នាំចុកអីទេចាស ។

- បាទ គ្មានទេលោកអ៊ំ ! ព្រោះខ្ញុំក៏មិនមែនជាលោកគ្រូពេទ្យធំដុំ ណា ហើយដែលចាក់ឱ្យលោកអ៊ំប្រុសនោះ គឺធ្វើតាមតែទម្លាប់ដែលធ្លាប់ឃើញ លោកគ្រូពេទ្យ គេធ្វើមកតែប៉ុណ្ណោះ នឹងចេះជាងនេះអត់ទេទាន ។

- ចុះលោកពុំមែនជាលោកគ្រូពេទ្យទេ ? បុរសបងដែលទទួលខ្ញុំនៅ យ៉ខាងក្រៅអម្បាញ់មិញបានសួរខ្ញុំ ។

- បាទទេ ខ្ញុំគ្រាន់តែធ្លាប់ធ្វើជាលេខាធិការពេទ្យប៉ុណ្ណោះ ។ ឯការ ដែលកាន់ថ្នាំកាន់ម្ជុលជាមួយគិលានុបដ្ឋាក ឬលោកវេជ្ជបណ្ឌិត យូរៗទៅ ក៏ខ្ញុំចំ ណាំមុខថ្នាំខ្លះបាននឹងស្គាល់របៀបសង្គ្រោះខ្លះៗដូច្នេះ ។

- បើអីចុះសព្វថ្ងៃនេះលោកជាអ្វីទៅវិញ ?

- បាទ ខ្ញុំបាទជាលេខាធិការសមាគមអ្នកនិពន្ធខ្មែរលោក ។

- លោកអញ្ជើញមកលេងទេឬអី ឬមានបងប្អូនឯណាដែរនៅសៀម រាបនេះ ។

- បាទប្រាថ្នាស្គាល់អង្គរនឹងគេម្តង ខ្ញុំគ្មានញាតិសន្តានឯណានៅនេះទេ តែខ្ញុំមានមិត្តម្នាក់ ( ខ្ញុំងាកទៅរកមិត្តសុវណ្ណ ដែលគេអង្គុយក្បែរនោះ) គឺមិត្ត សុវណ្ណនេះ គេសរសេរសំបុត្រហៅជាច្រើនសាឱ្យមកលេងទីនេះម្តង មើលអង្គរ ផង ។

- ត្រូវជាមិត្តនឹងក្មួយសុវណ្ណផង ?

(ស្រីជាម្ចាស់ផ្ទះ ក៏ចាប់និយាយដោយងាកទៅរកសុវណ្ណ) មិត្ត សម្លាញ់យូរហើយឬក្មួយសុវណ្ណ ?

- បាទ លោកអ៊ំ ! ចរណៃជាមិត្តរបស់ខ្ញុំតាំងពីរៀននៅលិសេភ្នំពេញ ម្ល៉េះ ។ គេមិនដែលមកខេត្តយើងសោះ ។

- អីចុះម៉េចមិនប្រាប់អ៊ុំផងបើគ្នាឯងទេ ?

- ប្រាប់ឯណា បើខ្ញុំមិនទាំងដឹងថាគេមកពីថ្ងៃវមាណផង ។ កាលដែលវង្សទៅទទួលលោកគ្រូពេទ្យនោះខ្ញុំស្មានតែលោកគ្រូពេទ្យឯណាផ្សេង មិនដឹងជាលោកគ្រូពេទ្យនេះអី (និយាយលាយនិងសើចផង) ខ្ញុំគិតថាលាកគ្រូ ពេទ្យដេកលក់វាល់ល្ងាចអីចឹង គឺពិតជាខ្ជិលទ្រមកណាស់ហើយ ។

- អូកាលដែលទៅនោះ លោកក្មួយឯណេះសម្រាន្តឬ ?

បុរសមានជម្ងឺចាប់ផ្លាស់ស័ព្ទនាម លោកគ្រូពេទ្យទៅជាលោកក្មួយ សម្រាប់ហៅខ្ញុំ ។ ស័ព្ទនាមនេះខ្ញុំសប្បាយជាងមុន ។ គាត់សួរមិនប្រាកដជាទៅ លើឈ្មោះណាទេ តែនាងក្រមុំកូនគាត់រហ័សឆ្លើយជំរាបគាត់ :

- ចាសលោកប៉ា ខ្ញុំឃើញគាត់សម្រាន្តលក់ស្រួលណាស់ ខ្ញុំពុំហ៊ានដាស់ ឈរចាំទើសតែគាត់ភ្ញាក់ ។

- បើដូច្នោះ លោកក្មួយពិតជាពុំទាន់បាយនៅឡើយ ។ ត្រូវចាត់ចែង ម្ហូបម្ហារជាមួយគ្នាទៅក្រែងវង្សឯង (គាត់និយាយទៅកាន់កូនប្រុស) និងអារី (ងាកទៅកូនក្រមុំ) នៅមិនទាន់បាយទេឬ ?

- បាទ, នៅទេ ! ត្បិតទៅដឹកមិត្តហ្នឹងមកបាយទាំងអស់គ្នា ។

វង្សបានផ្លាស់ស័ព្ទនាមគ្រូពេទ្យមកជាមិត្តវិញ ។ ដូច្នោះវេលានោះ គឺ នាំឱ្យមានមិត្តភាពដ៏ស្និទ្ធស្នាល ដែលខ្ញុំអាចសន្មត់នឹងទុកចិត្តខ្លួនឯងបានថា : ខ្ញុំ មិនមែនជាជនឯកាអានាថាទេ ។ ល្ងាចនោះ ខ្ញុំទទួលទានបាយនៅផ្ទះលោកចៅ ហ្វាយស្រុកដោយរីករាយ ។

បន្ទាប់ពីពេលបាយនោះ គេគ្រប់គ្នាបានសាកសួរសន្ទនានឹងខ្ញុំ ដោយ បោរីភាព ។ ដោយការរាប់អាន លោកអតីតចៅថ្វាយស្រុកបានប្រាប់កូនប្រុស គាត់ថា :

- វង្សឯង មើលជូនដំណើរលោកក្មួយដើរលេងអង្គរផង ឡានយើង មានស្រាប់ ។

- បាទលោកប៉ា ! វង្សទទួល ។

លុះម៉ោង ៨ កន្លះយប់ ខ្ញុំលាគេហជនត្រឡប់មកផ្ទះសំណាក់វិញ ដោយមានមិត្តវង្សជូនដំណើរផង ។

អង្គរ ! អស្ចារ្យណាស់ ! ខ្ញុំមកយល់ហើយ ។ កំពូលដោលទៅលើទីរ អាកាស បង្ហាញនូវថ្នាក់ប្រកបដោយក្បាច់ ។ កំពូលនេះមើលមួយភ្លែតទៅនឹក ស្មានថាជាវិមានប្រាក់អណ្តែត លយលេងលើពពក ។

ស្របនឹងហ្វូងមនុស្សប្រុសស្រីចាស់ក្មេងឯទៀតដែរ ខ្ញុំសន្សឹមដំណើរ ជាមួយនឹងវង្សព្រមទាំងវីប្អូនស្រីគេ កាត់តាមផ្លូវដែលក្រាលដោយថ្មបាយ ក្រៀមទៅកាន់វិមាននេះ ។ ផុតពីក្លោងទ្វារមួយ ដ៏ប្រកបដោយក្បាច់រំលេចភ្ញី នោះ រូបប្រាសាទស្អាតប្រណិតក៏កាន់តែច្បាស់ឡើង ។ ឱយ៉ាងនេះតើបានជាគេ ថា ទេវតាលោកប្រតិស្ឋាន ឡើងទុកជាកេរ្តិ៍ឱ្យខ្មែរ. . .។ ជួនជាពេលចូល អស្តង្គតការស្មីនៃព្រះអាទិត្យក៏ស្រោបគ្របពីលើកំពូលប្រាង្គទាំងនោះ ញុំាងឱ្យ កើតពណ៌មាសលឿងគួរីករាយដល់ភ្នែកក្រៃលែង ។ ដើរទៅជិតក្បាច់ដ៏ល្អ វិចិត្រឥតផ្ទឹមបានក៏អណ្តែតចេញគ្រប់ពីជញ្ជាំងច្បាស់ឡើង បញ្ជោក់ដល់នេត្រ អ្នកទស្សនា នាំឱ្យអត់ទ្រាំមិនជញ្ជក់មាត់សរសើរពុំបាន ។

គួរសរសើរត្រង់ផ្ទាំងថ្មតម្រៀបជិតគ្នា ហើយចេះឆ្លាក់ជារូបរឿងរ៉ាវ បំភាន់ភ្នែកឱ្យមើលទៅឃើញតែភាពមួយដូចគេលាតត្រដាង ។ ឱបុព្វបុរសដ៏ អស្ចារ្យអើយ ស្នាដៃលោកអ្វីក៏សម្បើមដល់ម្ល៉េះ ។ រូបផ្កាភ្ញីប្រទាក់ទង សមនឹង រូបទេពអប្សរដ៏ល្អតលៃ្វ តើលោកអ្នករចនាចង់និយាយដោយពិស្តារពីអ្វីហ្ន៎។ ឱ ជំនាន់ដ៏រុងរឿងអើយ ថ្ងៃនេះការយល់សប្តិរបស់ខ្ញុំបានក្លាយទៅជាភាពពិត ហើយ ។ ខ្ញុំបានមកផ្ទាល់ឃើញកេរ្តិ៍តំណាងមួយដែលប្រាកដនិមិត្តរូបនៃសតវត្ស មួយដ៏ពោរពេញដោយអានុភាពហើយ ។ អ្នកទេសចរឯទៀត ដែលដើរច្រវាត់ ច្រវែង ខ្លះឡើងលើប្រាសាទ ខ្លះចុះមកវិញនោះ គេមានដួងចិត្តរំភើបស្ញើច អស្ចារ្យដូចខ្ញុំទេ ? អ្នកដែលស្ទាបអង្អែលក្បាច់ក្បូរនឹងរូបទេពអប្សរហើយជញ្ជក់មាត់ឬក៏គ្រវីក្បាលនិយាយថា : អស្ចារ្យ ! តើអ្នកទាំងនោះមានបន្ទាត់ មនោគតិឱ្យនឹកដល់អតីតកាលដ៏រុងរោចន៍របស់ជាតិខ្មែរដូចខ្ញុំទេ

? ពេលដែលខ្ញុំ បានមកប្រាកដខ្លួននៅទីស្ថានដ៏ជាទីប្រវត្តិសាស្ត្រនេះ ទោះណាជាមានភ្នែករាប់ រយពាន់ក៏ដោយ ក៏ពុំអាចគយគន់ឱ្យសព្វគ្រប់នូវក្បាច់ចម្លាក់នេះបានដែរ ហើយ ទោះណាជាយើងមានអណ្តាតរាប់រយរាប់ពាន់ដូចគ្នា ក៏ពុំអាចពោលសរសើរឱ្យបានចប់អំពីលំអដ៏វិចិត្រនេះបានដែរ ។ អច្ឆរិយភាពនេះអាចបំពេញសេចក្តីត្រូវ ការរបស់ពួកចិន្តកវីបានយ៉ាងឯក ។ ដូច្នេះឯង ខ្ញុំក៏បាននឹកឃើញដល់កំណាព្យរបស់ លោកអាចារ្យមៀវ នន្ទ ដែលបានសរសេរក្នុងសៀវភៅព្រះបាទ ជយវរ្ម័ទី ៧ និងប្រទេសកម្ពុជា និង កំណាព្យនិរាសនគរវត្តរបស់លោកអាចារ្យសុត្តន្តប្រី ជាឥន្ទ ដែលកវីទាំងនេះសឹងបានសរសេរអំពីសេចក្តីរំភើបរបស់លោកចំពោះ ភាពដ៏សំបើមនេះ ។ ហើយខ្ញុំក៏មិនភ្លេចដែរ នូវសេចក្តីបំភ្លឺរបស់លោកអ្នកប្រាជ្ញ ខាងប្រវត្តិសាស្ត្រ ម្យ៉ាងវិញទៀតភាពនេះបានផ្តិតចំនឹងនាមស័ព្ទ ដែលយើង រមែងសូត្រជារាល់ដងជាមួយនឹងការបង្ហូតឡើងនៃទង់ជាតិរបស់យើង ដែល មានសេចក្តីថា : ប្រាសាទសិលា កំបាំងកណ្តាលព្រៃ គួរឱ្យស្រមៃ នឹកដល់យសសក្តិមហានគរ ជាតិខ្មែរដូចថ្មគង់វង្សនៅល្អរឹងប៉ឹងជំហរ យើងសង្ឃឹមពរ ភ័ព្វ ព្រេងសំណាងរបស់កម្ពុជា មហារដ្ឋកើតមាន យូរអង្វែងហើយ ។ ចម្រៀងនេះ មានន័យសែនច្បាស់លាស់ បង្ហាញនូវប្រវត្តិមួយដ៏សែនថ្កើងរបស់ខ្មែរ ។ បើ ខេមរជនណាម្នាក់រំលឹកឡើងនូវចម្រៀងនេះក្នុងពេលដែលស្រមោលគេចាំង ជាប់ទៅលើផ្ទាំងសិលា ពេលនោះឯងហើយ ស្បែកគេនឹងព្រឺដោយវិសារទភាព ដ៏ក្លៀវក្លា ចំពោះខ្លួនខ្ញុំដើម្បីជាអនុស្សាវរីយ៍ ខ្ញុំមិនភ្លេចទេត្រឡប់ទៅវិញខ្ញុំនឹង សរសេរកំណាព្យមួយ ដោយឱ្យចំណងជើងថា : វិមានសិលា ។ ព្រោះខ្ញុំឃើញ ថ្មទាំងដុលនោះមានភាពជាវិមានឯកមួយគ្មានអ្វីផ្ទឹម ។

កំពុងតែលឿនលយស្មារតី ទៅតាមសេចក្តីពិចារណាស្រាប់តែ វង្ស កេះខ្ញុំថា :

- មកមិត្ត យើងទៅផ្ទះវិញ ព្រលប់ឥឡូវហើយ

ឯនាងក្រមុំក៏ផ្ទួនថា :

- លោកប៉ាបែបទន្ទឹងហើយ ។ មិនអីទេលោកស្អែក ខានស្អែក មក ទៀតក៏បាន ។ ហើយមិនខ្វះកន្លែងមើលទេចាស ដូចជានៅអង្គរធំមានបាយ័ន ព្រះខ័ន នាគព័ន្ធ មេបុណ្យ ប្រែរូប តាព្រហ្មអីៗទៀតចាស ។

- បាទអ្នក តែថាថ្ងៃនេះខ្ញុំអាចចាត់ថា ជាវាសនាធំមួយ ដែលខ្ញុំបាន មកឃើញអង្គរនេះ ។

- លោកមិនដែលឃើញក្នុងរូបថតទេឬអី ?

- ដែលដែរ តែវាមិនស្តែងដូចយើងមកដល់មែនៗយ៉ាងនេះ អូ អត់ ទោសខ្ញុំដូចជាចង់បានរូបថតជាអនុស្សាវរីយ៍នៅកន្លែងនេះ តើមានអ្នកណាគេ ជួលថតដែរ ?

- អ្នកថតរូបមានគរគោក បើត្រូវការហៅថតបានភ្លាម ថ្ងៃស្អែកបាន រូបភ្លាម ។

ខ្ញុំឃើញអ្នកកាន់ប្រដាប់ថតរូបជាច្រើន ស្មានតែពួកទេសចរ។ វង្ស មិត្តខ្ញុំគេស្គាល់ជាងខ្ញុំ ក៏ហៅម្នាក់មកថតរូប ។ នៅចំពីមុខអង្គរវង្សដើរកណ្តាល ខ្ញុំនឹងនាងក្រមុំដើរអម យើងឱ្យគេច្រចាប់បីភាព ។ រួចហើយអ្នកថតរូបសរសេរ បង្កាន់ដៃឱ្យយើងយករូបថតនេះថ្ងៃស្អែក ។

ម៉ោង ៦ ហើយ យើងទាំងបីនាក់ឡើងរថយន្តនិវត្តមកលំនៅវិញ ។ គេជូនដំណើរខ្ញុំដល់សណ្ឋាគារទើបវង្សនិងប្អូនស្រី គេត្រឡប់ទៅផ្ទះ ។

ខ្ញុំចូលទៅបន្ទប់ជំរះកាយ រួចផ្លាស់សំលៀកបំពាក់ប្រុងប្រៀបទៅ ផ្សារទទួលអាហារ ។ ប៉ុន្តែអង្គុយជញ្ជឹងសិន ។ ខ្ញុំមានអារម្មណ៍គឺប្រាង្គអង្គរ ដែលបានឃើញមកហើយនោះគឺម្យ៉ាង ម្យ៉ាងទៀតលំអរបស់នារីដែលខ្ញុំទើប ស្គាល់នេះក៏នាំឱ្យខ្ញុំពិចារណាខ្លាំងណាស់ដែរ ។

- យី នាងស្រីនេះល្អចំឡែកណាស់ ធ្វើម៉េចហ្ន៎នឹងបានជាគូស្រករអញ អេះ តើនាងមាននឹកសង្ស័យថាអញស្រឡាញ់នាងទេ ឱ បើអញមានសំណាង បាននាងធ្វើជាប្រពន្ធ ម្ល៉ោះអញនឹងថ្នាក់ថ្នមនាងមិនឱ្យរង្កៀសចិត្តទេ ។

កំពុងគិតនោះស្រាប់តែស្បែកជើង កុប កុប លាន់ពីជណ្តើរមក ។ ខ្ញុំ នឹកព្រួចថា : នាងមករកខ្ញុំហើយ ។ ខ្ញុំលូកកន្សែងជូតមុខជូតមាត់ក្រែងមាន មន្ទិល ។ ទ្វាររបើកឡើងពុំមែនសោះ គឺជា សុវណ្ណទៅវិញ ។ ខ្ញុំនឹកខកចិត្តបន្តិច ។ គេដើរចូលមកបែបរីករាយ :

- ឯងទើបមកពីណាចរណៃ ? គ្នាមករកឯងពេលរសៀលនេះមិនជួប ។

- អំ គ្នាទៅលេងអង្គរណាសុវណ្ណ

ឯងទៅជាមួយវង្សនិងប្អូនក្រមុំគេមែនទេ ? គ្នាទៅរកឯងផ្ទះឯណោះ លោកអុំស្រីប្រាប់គ្នារួចទៅហើយ (និយាយដោយញញឹម)

- បើអីចុះសុវណ្ណឯងចាំបាច់សួរគ្នាធ្វើពីអីទៀត ។

- អើគ្នាសួរដើម្បីសួរតែប៉ុណ្ណោះទេតើ ម៉េចនាងនោះគួរសមទេ ហើយឯងពេញចិត្តទេ !

ខ្ញុំនឹកអៀននឹងសំនួរនេះជាខ្លាំង មិនតបវិញទេ ខ្ញុំបែរជាសួរវិញថា :

- នែសុវណ្ណ ឯងស្គាល់ពូជពង្សគេច្បាស់ឬ ទើបគេរាប់រកឯងខ្លាំងម្ល៉េះ ?

- ហ្នឹងហើយ ឪពុកគ្នានិងចៅហ្វាយស្រុកនោះជាជន្លងនឹងគ្នាបងប្រុស បង្អស់ដែលគាត់ទទួលយើងមុនដំបូងនោះត្រូវជាបងថ្លៃរបស់គ្នា ឯស្រីនោះគឺជា បងស្រីរបស់គ្នាបង្កើត ។ ចំណែកវង្សវិញ គេត្រូវជាមិត្តនឹងរូបគ្នាតាំងពីនៅរៀន សាលាបឋមភូមិវត្តដំណាក់ម្ល៉េះ ។

- អ៊ីចឹងបានជារាប់អានគ្នាដូចជាបងប្អូនអ៊ីចឹង ។ ចុះនាងនោះឈ្មោះ អី ? គ្នាឮតែ វី វី ។

សុវណ្ណសើចបែបដឹងបំណងខ្ញុំយ៉ាងណាហើយ :

- គ្នាមិននិយាយទេ ទាស់តែឯងឆ្លើយមកសិនថា តើឯងត្រូវភ្នែកទេ ?

- ចុះសុវណ្ណឯងចង់ដឹងចិត្តគ្នាធ្វើអី គ្នាដូចជាឆ្ងល់ដែរហ្នឹងនែ៎

- មិនជាចង់ដឹងប៉ុន្មានទេ ប៉ុន្តែគ្នាត្រូវការតែរឿងណាមានប្រយោជន៏ ហើយពិតតែប៉ុណ្ណោះ បើនិយាយគ្រាន់តែនិយាយទេនោះ គ្នាមិននិយាយទេ ។

- ចុះឯងចាំឆ្ងល់ធ្វើអី គ្នាដែលមកពីនាយធ្លាក់អាយនេះ តើនឹង ឧស្សាហ៍ស្តាប់រឿងដែលគ្មានប្រយោជន៍ឬ យើងជាប្រុសដូចតែគ្នា មិនគួរដេក ឆ្ងល់ដល់ណាទៀតទេ ។

- បើដូច្នោះ បានសេចក្តីថា ចរណៃឯងពិតជាចូលចិត្តនាងមិនមែនឬ ?

សុវណ្ណនិយាយសើចយ៉ាងជោគជ័យ ។ ខ្ញុំពោរពេញដោយក្តីខ្មាស ព្រោះធ្លាយពាក្យខាងដើមនោះ ដូចជាឱ្យគេយល់ដល់ក្រយៅចិត្តឯងតែម្តង ។ កាលបើសុវណ្ណសើចជាសញ្ញាថា គេបានដេញខ្ញុំទាល់ជើងហើយនោះ ខ្ញុំដូចជា នឹកតូចចិត្តបន្តិចដែរ នឹកថាមិនគួរសុវណ្ណ វាដេញដោលខ្ញុំធ្វើអ្វីសោះ ។

- មិនបាច់ដេញដោលគ្នាទេសុវណ្ណ បើឯងមិនប្រាប់ក៏វាហីទៅចុះ ។ គ្នាទៅផ្សារស៊ីបាយសិនហើយ ។

ខ្ញុំងើបពីគ្រែឈានចេញទៅ ។ សុវណ្ណស្ទុះតាម

- ឈប់សិនលោកគ្រូពេទ្យ

- កុំនិយាយលេងច្រើនសុវណ្ណ

- ឈប់សិនចាំគេប្រាប់ អីក៏រហ័សងរជាងស្រីទៅទៀតម្ល៉េះ...

- និយាយប្រាប់មកគ្នាមិនងរទេ ប៉ុន្តែទាស់ចិត្តនឹងសុវណ្ណឯងបន្តិចដែរ ការអីគ្នាចង់ដឹងឯងចាំធ្វើកលឱ្យគ្នាអង្វរ ។

សុវណ្ណសើចទៀត ធ្វើឱ្យខ្ញុំញញឹមទាំងខ្មាសទៅដែរ សុវណ្ណ និយាយ ដោយច្បាស់លាស់ថា :

- នែ ចរណៃ ! នាងឈ្មោះទេវី ប៉ុន្តែគេហៅកំបុតថា វិ វី ដូចឯងឮ មកហើយ !

ខ្ញុំងក់ក្បាលបន្តិច សុវណ្ណបញ្ជាក់ថែមថា :

- នាងនេះមានកិរិយាសុភាពរាបសា នឹងទន់ភ្លន់ល្អណាស់ សមតែបាន ប្តីជាមនុស្សស្លូតបូតទេ ។ គ្នាយល់ថានាងនេះហើយនិងចរណៃឯងសមគ្នាណាស់ ទាំងឈ្មោះក៏ជូនគ្នាទៀត : ចរណៃ-ទេវី ។ ទាំងរាងរៅក៏សមគ្នាដែរ អើគ្រាន់តែឯងស្គមជាងនាងបន្តិចប៉ុណ្ណោះ គ្នាចង់ឃើញឯងនឹងនាងនៅជាមួយគ្នាណាស់ . . .

ពាក្យពេចន៍របស់សុវណ្ណនាំឱ្យខ្ញុំយល់ថា គេពោលជាបទកំប្លែងក៏ថា បាន ព្រោះគេឧស្សាហ៍និយាយលេងណាស់ ថាគេនិយាយមែនទែនក៏ថាបាន ព្រោះនេះវាស្របនឹងដំណើររឿងមែន ដូច្នេះខ្ញុំមិនអាចវិនិច្ឆ័យឱ្យដាច់ស្រឡះ បានទេ ។ ប៉ុន្តែយ៉ាងណាក៏ដោយ ពាក្យពេចន៍នេះក៏នាំឱ្យខ្ញុំសប្បាយចិត្តយ៉ាង ខ្លាំងណាស់ដែរ ហើយចិត្តគំនិតខ្ញុំហាក់ឡើងចាងអស់មួយរឹងទៅ . . . ។ ដើម្បី បញ្ចប់រឿងនេះ ខ្ញុំចាប់និយាយឡើងថា :

- ណើយ ! ស្លេះទុកសិនទៅកុំអាលចាប់ផ្លូវផ្គងអី គ្នាមិនមែនសួរពី រឿងនេះទេ សួរតែឈ្មោះប៉ុណ្ណោះ ឥឡូវបើដឹងឈ្មោះនាងហើយ គ្នាក៏សូម អរគុណឯងដែរ ។ ហើយឥឡូវឯងគិតទៅណា ? ឯគ្នា គ្នាគិតទៅផ្សារព្រោះមិន ទាន់បាយផង ។

- គ្នាមកបបួលឯងទៅមើលកុនសៀមរាបនេះម្តង បាយរួចទៅដល់ ម៉ោងល្មម ។

- មានប៉ុន្មានរោងនៅទីនេះ ហើយរោងណាល្អមើល ?

- មានតែពីរទេ ហើយមិនជាជាងគ្នាប៉ុន្មានទេ

- គ្នាដូចជាមិនសូវចំណូលប៉ុន្មាន ប៉ុន្តែទៅមើលក៏ទៅ !

ខ្ញុំនិងសុវណ្ណកាន់ដៃគ្នាចុះពីសណ្ឋាគារ ហើយក៏ឡើងជិះរ៉ឺម៉កមួយ ។ សុវណ្ណប្រាប់រ៉ឺម៉កឱ្យនាំទៅភោជនីដ្ឋាន ដែលនៅមុខមន្ទីរឃោសនាការ ។ មួយ សន្ទុះប៉ុណ្ណោះយើងទាំងពីរនាក់បានទៅដល់ទីនោះ ។ សុវណ្ណនាំខ្ញុំឡើងទៅជាន់ លើ ។ អង្គុយរៀបរយ ហើយអ្នកសៀមរាបនេះបញ្ជាក់ទៅចិនថា :

- ធ្វើបាយ ! ហើយសម្លម្ជូរមួយមុខ ឆាសាច់គោមួយមុខ ! សាច់ទា ខ្វៃមួយចាន !

គេងាកនិយាយមកខ្ញុំ :

- ចរណៃឯងចូលចិត្តយ៉ាងនេះដែរ

- អឺ . . .

ខ្ញុំងក់ក្បាលផង់ទៀត ព្រោះមិនចង់ឱ្យសុវណ្ណរើរុះមុខម្ហូប តែតាមពិត សម្លម្ជូរហើយនឹងខ្ញុំគឺពុំត្រូវធាតុគ្នាទេ ក្រែងតែសម្លស្រុកគេនេះវាឆ្ងាញ់យ៉ាង ម៉េចនោះមិនដឹង ។ សុវណ្ណឱ្យចិនយកបីយែរស៊ិន តាវ ហើយងាកសួរខ្ញុំ :

- ចរណៃឯងដែរឬ ?

- ទេ គ្នាទឹកក្រូចបានហើយ ! គ្នាមិនចូលចិត្តភេសជ្ជៈ បីយែរបីយ៉ាំងអីនេះទេ ផឹកទៅភើមកធុំជូរយ៉ាងនេះ ។

- រវល់តែចង់ផ្អែមយ៉ាងហ្នឹងបានជាស្គមកំព្រឹងយ៉ាងអ៊ីចឹង ! ឱមែនគេអាចារ្យ !

កុំនិយាយលេងច្រើនពេកគ្នាស្អប់ណាស់ !

ខ្ញុំងាកទៅអ្នកលក់ !

- យកទឹកក្រូចមួយដបមក !

- ធុនណាលោក ?

- ឯងមានម៉ាកណាខ្លះ ?

- បាទ មាន វីតា គ្រិនស្ប៉ត សើរឹងអាប់ បៀរឡោរ ប៉ិបស៊ី បេសេអ៊ី បាទ . . .

- យកអីមកក៏បានដែរ !

ចិនបានសម្រេចបំណងយើងដោយរួសរាន់ ។ ហើយក្រោយនោះអា ហារក៏មកដល់ទៀត យើងទាំងពីរចាប់បរិភោគដោយរីករាយ ក្សេមក្សាន្ត ។ ក្នុងពេលអាស្រ័យបាយនេះ សុវណ្ណនៅតែនិយាយរឿងនាងទេវីទៀត ដែលធ្វើ ឱ្យខ្ញុំនឹកព្រួចក្ដួចចិត្តរិតតែស៊ប់ ។

ក្រោយអាហាររួចហើយ សុវណ្ណប្រញាប់ហៅចិនមកគិតលុយ រួចនាំ ខ្ញុំចេញមករកកីម៉ក ។ ហៅរ៉ឺម៉កជិះសុវណ្ណ ប្រាប់ថា ទៅភាពយន្តអង្គរ ។ រថសណ្តោងបានដឹកដំណើរយើងកាត់វិថីពីរបី ។ ខ្ញុំមិនដឹងជាទិសណា តំបន់ណាទេ ។ ស្រាប់តែទៅដល់កន្លែង ដែលមានហ្វូងមនុស្សមួយដុំ ។ នៅមុខអាគារនោះ មានតាំងរូបភាពធំៗ គឺជារោងភាពយន្ត សុវណ្ណ និងខ្ញុំចុះពីយាន បន្ទាប់ពីបាន ឱ្យឈ្នួលអ្នកធាក់រ៉ឺម៉កហើយ ក៏នាំគ្នាត្រសងចូលទៅក្នុងចំណោមមនុស្សនោះ ដែរ ទៅទិញសំបុត្រ ។ សុវណ្ណដើរចូលឯខ្ញុំក៏ងើយមើលរូបភាពផ្សេងៗ ហើយមើលចំណង ជើងរឿងដាក់ថា : **អាឡាដាំងនិងចង្កៀងទិព្វ** មិនទាន់ដាក់ ភ្នែកមកវិញផងស្រាប់តែសុវណ្ណកេះហើយចង្អុល :

- នែ ចរណៃ ទេវីមកមើលកុនដែរវើយ

ខ្ញុំមើលទៅ ក៏ឃើញនាងមើលមកខ្ញុំនឹងសុវណ្ណដែរ នាងញញឹមមក ផង ។ នៅក្បែរនាងកញ្ញាម្នាក់ទៀតឈរផង ប្រហែលជាមិត្តរបស់នាងហើយ ។ សុវណ្ណញែកគេឯងដើរទៅកាន់នាង ខ្ញុំក៏តាម សុវណ្ណទៅដែរ ។ ដួងចិត្តខ្ញុំ ពេលនេះញាប់ញ័រចំឡែក មិនអាច នឹងថាមក ពីអ្វីបានទេ ។ សម្រស់របស់នាង សែនឆើតឆាយណាស់ ល្អដាច់គេក្នុងចំណោមស្រីដែលនៅក្បែរនោះ ។ សំលៀក បំពាក់តាមរបៀបសម័យនិយម សំពត់ហ៊ុបពណ៌ប្រផេះ អាវវ៉ាលក ទុកសាច់ ដើមទ្រូងម៉ដ្ឋខៃឱ្យលេចឡើងទទួលពន្លឺភ្លើងពណ៌នៃអគ្គិសនី ។ សមនឹងភួងថ្គាល់ ដែលមានខួចខាងស្តាំបន្តិច បបូរមាត់ពណ៌កូលាបរបស់នាងក៏បង្ហើបរីក រាយឡើង ព្រមទាំងលើកហត្ថទាំងគូដែលសត្រសូលដូចភ្ញុកនោះគួរសមនឹងខ្ញុំ :

- ជំរាបសួរលោក

- បាទ លើកដៃថ្វាយព្រះអ្នក !

ខ្ញុំលើកដៃតបទៅវិញដោយពេញចិត្ត ។ ឯមិត្តនាងក៏បានជំរាបសួរខ្ញុំ ដែរ ខ្ញុំក៏បានតបទៅវិញដែរ ។ សុវណ្ណមិត្តខ្ញុំចាប់ផ្ដើមសួរ :

- អ្នកវី អញ្ជើញមកមើលដែរឬ ? ទិញសំបុត្របានហើយឬនៅ ?

- ចាស មិត្តខ្ញុំ (ងាកទៅកាន់មិត្តនាង ) គេទៅបបួលខ្ញុំពីផ្ទះមក មើល ថារឿងល្អមើលទើបខ្ញុំមកនេះចាស ។ ឯសំបុត្រទិញឯណាបានបើមនុស្ស សន្ធឹកម៉េះ ឃើញតែទៅផ្ទះវិញចាំយប់ក្រោយទៅទើបកើត ។ ឯលោកសុវណ្ណ ឯងមកមើលដែរ ទិញសំបុត្របានហើយឬនៅ ?

- បាទ នៅទេ ! ទើបមកដល់អម្បាញ់មិញនេះឯង អាល័យតែចូល ហៅចរណៃឱ្យគេមកមើលផង ។ គេអង្គុយសំកុកមិនដឹងជាភ្លឹកទៅណាទេ ពុទ្ធោអើយទំរាំតែដាច់ចិត្តមក ខាតពេលសន្ធឹក !

សុវណ្ណនិយាយនេះគឺពន្លើសទាំងស្រុង ។ តាមពិតកាលដែលទៅហៅ ខ្ញុំមកនោះ មិនមែននិយាយពីរឿងកុនទេ គឺនិយាយពីរឿងនាង។ ប៉ុន្តែគួរត្រេក អរដែលសេចក្តីពន្លើសនេះ ព្រោះខ្ញុំយល់ថានាង គង់យល់សេចក្តីប្រាថ្នារបស់ខ្ញុំ ខ្លះ កាលបើឮថាខ្ញុំសំកុក ខ្ញុំភ្លឹកយ៉ាងនេះ ។ ត្រង់នេះគួរសរសើរនឹងអរគុណដល់ សុវណ្ណមិនតិច ។ សុវណ្ណ មើលនាឡិកាដៃ ហើយនិយាយថា :

- នៅ ១៥ មីនុតទៀតលេងហើយ ! បើអ្នកវីមើលខ្ញុំនឹងទៅទិញ សំបុត្រជូនបាន ។

មិនតបទៅនឹងសំដីសុវណ្ណទេ នាងងាកទៅមិត្តនាង :

- ម៉េចទៅផ្ទះវិញឬក៏មើល ? គ្នាដូចជាចង់វិលមុខ វិលមាត់ហើយ មនុស្សច្រើនអ៊ីចេះផង !

មិត្តនោះតបភ្លាមដោយខិនហួតលុយពីកាបូបយួរ :

- មកហើយត្រូវមើល ទៅវិញឥតប្រយោជន៍ដែរ តាមខ្ញុំ ចុះវី!

សំដីមិត្តរបស់នាងនាំឱ្យខ្ញុំសប្បាយចិត្តឥតឧបមា ព្រោះស្មានតែនាង នាំគ្នាទៅផ្ទះវិញនាំឱ្យខ្ញុំខកចិត្ត ។ នាងនោះហុចលុយ ១០០ រៀល ទៅឱ្យមិត្តខ្ញុំ :

ណេះលោក សូមអញ្ជើញទិញឱ្យផងចាស !

- បាទ មិនអីទេ អ្នកទុកវិញចុះ ខ្ញុំទិញទាំងអស់ចុះ ខ្ញុំបាវ អ្នកវីម្តង !

ថាហើយសុវណ្ណប្រញាប់ចូលទៅជ្រៀតទិញសំបុត្របាត់ទៅ ។ មួយ សន្ទុះឃើញគេបោយដៃហៅឱ្យយើងទៅ ។ មិត្តនាងនាំមុខ នាងដើរកណ្ដាល គឺដើរខាងមុខខ្ញុំ ។ បានឱកាសនឹងគន់ត្រគាកដ៏មូលក្លំរបស់នាង និងគន់ចង្កេះ ដែលហាក់មានផ្ចិតដោយជាយអាវ មានរឹមជរ ក្លិនទឹកអប់ក៏សាយចេញពីកេ សាដ៏ខ្មៅរលើប មកប្រសព្វនឹងនាសារបស់ខ្ញុំ រិតតែនាំឱ្យខ្ញុំជ្រះថ្លារីករាយចិត្ត ខ្លាំងឡើង ។ សាច់ស្នាសស្អាត ម៉ដ្ឋរលីងគ្មានរោម ស៊ីសម្បុរនឹងអាវវាលកពណ៌ កូលាប ។ នាងមានកំពស់កំពរប្រហែលខ្ញុំ ហើយខ្ញុំជឿថា នាងនឹងខ្ញុំសមគ្នា ណាស់ ដូចពាក្យផ្ដាំផ្ញើរបស់សុវណ្ណមិនខុស ។ ពេលនេះខ្ញុំសង្កេតបានថា មានបុរសជាច្រើនមើលមកខ្ញុំនឹងនាងដោយលួចលាក់ ។ ខ្ញុំក៏ដូចជាឡើង ជំនោរក្នុង ចិត្តរិតតែដើរកៀកនាងខ្លាំងឡើង ក្នុងទំនងប្រាប់គេឯងថា នាងនិងខ្ញុំជាប្រពន្ធប្ដី រួចទៅហើយ ។ ទៅដល់សុវណ្ណ នាងងាកមកខ្ញុំ ហើយនិយាយតិចៗ :

- ទំរាំតែបានដល់ ខ្ញុំសឹងតែខ្យល់ចាប់ លោកយ៉ាងម៉េចដែរ ?

- បាទ មិនអីទេអ្នក ។

ខ្ញុំឆ្លើយគួរសមទៅរកនាងដោយញញឹមផង ។ សុវណ្ណ នៅក្បែរទ្វារ ហុចសំបុត្រទៅអ្នកយាមរួចចូលទៅ ។ មនុស្សពេញរោង ជាស្រេច ។ ខ្ញុំមិនដឹង ជាសុវណ្ណទិញថ្នាក់ណាទេ តែសុវណ្ណរហ័សប្រាប់ទាំងអស់គ្នាថា :

- ថ្នាក់ក្រោយបង្អស់ ជាប់គ្នាទាំង៤ លេខ ។ សំណាងដែរនៅតែបន្តិច ទៀតឥតបានជាប់លេខគ្នាទេ ។

ខ្ញុំមិនតបអ្វីទាំងអស់ ។ ខណៈនោះអ្នករកកន្លែងបានមើលសំបុត្រ យើង ហើយនាំចង្អុលកៅអីជួរក្រោយ ។

- សូមអញ្ជើញចូលជួរនេះទាំង៤កន្លែងទាន !

សុវណ្ណចូលមុន បន្ទាប់មកនាង រួចមិត្តនាង ។ ដូច្នោះទៅជានាង ហើយនិងខ្ញុំនៅជិតគ្នា ឯសុវណ្ណនិងមិត្តនាងបែរជានៅអមឆ្វេងស្ដាំ ខ្ញុំនិងនាងទៅ វិញ ។ ខ្ញុំមិនយល់ថានាងគិតយ៉ាងណាទេ ។ តែខ្ញុំដឹងថា បើនាងមិនពេញចិត្ត និងអង្គុយជិតខ្ញុំ ក៏នាងរកបន្ទោសខ្ញុំពុំបានដែរ ត្បិតនាងចូលក្រោយខ្ញុំ ។ ផ្ទុយទៅវិញ ប្រហែលជានាងមិនស្អប់ខ្ញុំទេ ឬក៏គិតដល់សុជីវធម៌ផង ទើបសុខចិត្ត ចូលមកអង្គុយជិតខ្ញុំ ដែលនាងធ្លាប់ ស្គាល់មកនេះ ។

- អ្នកមិនសូវស្រួលខ្លួនមែនឬ ?

ខ្ញុំសួរនាងដោយសម្លេងស្រាលយកគួរសម ដោយបានស្ដាប់នាង និយាយពីក្រៅមកថាមិនសូវស្រួលខ្លួន ។

ចាសទេ មិនអីទេចាស បានមកត្រូវខ្យល់កង្ហារក្នុងរោងអីចឹងទៅ វា ស្រួលទៅវិញ ចាស ។

ឆ្លើយយ៉ាងធម្មតា ឯដួងនេត្រមើលទៅពិតាន មើលទៅជញ្ជាំងបែប វាហិ ។ ទឹកអប់នៅតែផ្សព្វផ្សាយ ប៉ុន្តែខ្ញុំយល់ដោយឥតភាន់ ច្រឡំថា ខ្ញុំទទួល ក្លិននេះច្រើនជាងអ្នកឯទៀតទាំងអស់ ។ ចិត្តខ្ញុំពេលនេះសែនរំភើបពិសម័យ ក្រៃលែង ត្រូវនឹងសម្លេងតន្ត្រីនៃភាពយន្ត ប្រគំរងំមកផង ក៏រិតតែមនោរម្យផុត ពណ៌នា ។ ភ្លើងភាពយន្តបានបិទងងឹតឈឹង ហើយរូបរស់រវើកនៅលើផ្ទាំង សំពត់ក៏មានសកម្មភាពឡើង ។ គេបញ្ចាំងរឿងលេងថ្ងៃក្រោយ ក្រៅពីនោះ មានបញ្ចាំងឃោសនាពាណិជ្ជកម្ម ។ ខ្ញុំមិនដឹងជារឿងអីជាអីទេ ចិត្តគំនិតវា ទ្រង់រវើយមិន ប្រាកដប្រជាសោះ ។ រំពេចនោះភ្លើងស្រទន់បានបើកឡើង : គោរពព្រះបរមឆាយាលក្ខ័ណ៏ព្រះមហាក្សត្រិយានី ទើបខ្ញុំងើបឈរឡើងគោរព ដូចគេដូចឯង ។ ចប់ភ្លេងជាតិ ភ្លើងក៏បិទទៅវិញ ហើយនៅលើផ្ទាំងដដែលនេះ បញ្ចាំងជាពាក្យថា : ហាមមិនឱ្យជក់បារី ។ នាងកញ្ញាសួរ ខ្ញុំតិចៗ :

- លោកចេះពិសាបារីទេចាស ?

- បាទ ចេះដែរ តែតិចតួច ។ ជក់តែពេលដែលពួកម៉ាកអីគេឱ្យតែ ប៉ុណ្ណោះ ឯថាទិញមួយកញ្ចប់ជក់នោះឥតដែលទិញទេ មិនធ្លាប់ព្យាយាមទេអ្នក ។

បើអីចឹង មិនគឺលោកមិនចេះទៅហើយ ?

- បាទ ដូចជាអត់ចេះអីចឹងមែន !

- អីចឹងស្រួលម្យ៉ាងដែរ វាមិនសូវខាតលុយផង វាមិនសូវរំខានដល់ គេឯងផង ។ ខ្ញុំស្អប់ណាស់អ្នកខ្លះជក់បារីបង្ហុយផ្សែងលើគេជិតខាងគ្នាស្គាល់អី ទេ ។ ខ្ញុំមិនទាន់តបទៅនាងជាម៉េចផង សុវណ្ណ និយាយតទៅនឹងនាងថា :

- អ្នកវីអើយ ចរណៃ អាចារ្យស្មោះហើយ ស្រាបីយែរអី១ ឥតចេះទេ ។ បាយជាមួយខ្ញុំអម្បាញ់មិញលេងទឹកក្រូចតែម្តង ធ្វើឱ្យខ្ញុំខកចិត្តយ៉ាងខ្លាំង ។

- ហ្នឹងឯងគាត់ជាអ្នកត្រឹមត្រូវ

- ងឺ. . . កាន់ជើងលោកគ្រូពេទ្យហើយតើអ្នកវីខ្ញុំ !

សំដី របស់សុវណ្ណធ្វើឱ្យនាងអៀនលែងនិយាយទៅទៀត ។ ភាពយន្ត ចាប់ផ្តើមរឿងអាឡាដាំងនិងចង្កៀងទិព្វ ។ ខ្ញុំមើលហៅតែមើលប៉ុណ្ណោះ ពុំមាន ជំពាក់អារម្មណ៍ឡើយ ជួនកាលអ្នកទស្សនាជញ្ជក់មាត់ស្ញើបសរសើរដូច្នោះ ជួន កាលគេសើចគិលឡើង ។ ឯខ្ញុំឃើញតែរូបភាពនោះ រត់ឆ្លេឆ្លាចុះឡើង ម្តងខ្មៅ ម្តងស ម្តងភ្លឺ ម្តងងងឹត ម្តងជិត ម្តងឆ្ងាយតែប៉ុណ្ណោះ មិនឃើញជាអារម្មណ៍អ្វី សោះ ។ ចិត្តគំនិតខ្ញុំផ្តុំប្រមូលតែនឹងរឿងនាងកញ្ញានិងខ្ញុំទៅវិញ ។ ខ្ញុំប្រាថ្នា អង្គុយជិតនាងយ៉ាងនេះឱ្យបានយូរតទៅ ។ ខ្ញុំមិនចុញទ្រាន់ នឹងរូបភាព ដែលរត់ឆ្លេឆ្លាទៅវិញ ទៅមកនោះទេព្រោះវាបើកឱកាស ឱ្យនាងបាននៅជិតខ្ញុំ ។

ខ្ញុំដាក់ដៃសណ្តូកទៅលើភ្នាក់ដៃកៅអីខ្ញុំ ។ សម្ផស្សត្រជាក់មក ប្រសព្វនឹងដៃនេះតែមិនយូរសម្ផស្សនោះក៏ដកដៃទៅវិញ : គឺជាដៃរបស់នាង ដែលនាងក៏ដាក់មកដែរ ហើយប៉ះនឹងដៃខ្ញុំ ។

យូរ១ម្តងខ្ញុំតែងបានទទួលការពាល់ដូច្នេះ ។ ខ្ញុំមិនព្រមដកដៃ ហើយ ថែមលូកខិតចូលទៅលើភ្នាក់ដៃកៅអីរបស់នាងថែមទៀតជាហេតុនាំឱ្យនាង ពិបាកនឹងដាក់សណ្តូកមកទៀតផង ។ កាលបើខ្ញុំបានប៉ះសម្ផស្សនាង ខ្ញុំសែន រំភើបក្រៃលែង ។ ខ្ញុំជឿថាអំពើនេះ នាងមិនអាចចោទប្រកាន់ថា ជាចេតនា របស់ខ្ញុំទេ ព្រោះភ្នាក់ដៃកៅអីវាជាប់គ្នាយ៉ាងនេះ ។ ប៉ុន្តែតាមយល់គឺថានាង ដូចជាមិនរវល់នឹងការប៉ះពាល់នេះប៉ុន្មានទេ ត្បិតខ្ញុំសង្កេតឃើញថានាងនៅ ព្រងើយមើលតែទៅកុនដោយតុណ្ហី ហើយយូរ១ម្តងនាងសើចតិច១ ជាមួយនឹង សម្លេង គឹលឡើងនៃទស្សនិកជនឯទៀត ។ មិនតែប៉ុណ្ណោះ ខ្ញុំសង្កេតបានទៀត ថានាងទ្រង់ឆ្មៀងម្តងមកខ្ញុំក្នុងទំនងចង់ដឹងថា តើខ្ញុំមានសើចដូចគេដូចឯងទេ ។ ខ្ញុំកាលបើដឹងថានាងសង្កេតមកក៏តាំងព្រាងញញឹមឡើងមើលទៅមុខដែរ ទោះជាគេរាល់គ្នាឈប់សើចទៅហើយក៏ដោយ ។ កិរិយាមិនស្របតាមគេឯង យ៉ាងនេះ ខ្ញុំនឹកខ្មាសនាងយ៉ាងខ្លាំង ។ ប៉ុន្តែធ្វើម៉េចបើឯងវាមិនបានជាដឹងរឿង អីជាអីយ៉ាងនេះ ។ ឥឡូវបើមិនធ្វើទៅក្រែងនាងយល់ថា ខ្ញុំមានការកង្វល់អ្វី ម្យ៉ាង ក្រែងនាងចាប់ពិរុទ្ធច្បាស់ថាខ្ញុំកំពុងគិតផ្តេសផ្តាសចំពោះនាង នឹងនាំឱ្យ រិតតែខ្មាសនាងខ្លាំងទៀត ។ ជួបគ្នាគ្រាខ្លីសោះយ៉ាងនេះអីក៏ដល់ទៅរវើរវាយ ដល់ថ្នាក់នេះ ក្រែងនាងលបសើចក្នុងពោះ ។ ប៉ុន្តែប្រហែល ជានាងមិនយល់ ដល់ជម្រៅនេះទេយ៉ាងមើល ទើបនាងបែរមកខ្ញុំ ដោយទំនងយឺតហើយសួរថា :

- លោកមិនសប្បាយទេ ?

- បាទ ធម្មតាទេអ្នក !

- លោកមិនស្រួលខ្លួនទេ ចាស !

- បាទ ឥតអីទេអ្នក

- ណេះ ប្រេងខ្យល់ លោកឈ្លីមុខមាត់ទៅ។

- បាទ អរគុណហើយមិនអីទេ ។

- ទេ លោកយកទៅ ក្រែងខ្យល់ចាប់ !

និយាយព្រមទាំងហុចដបតូចមកផង ។ ជួនជាពេលនោះឆាករឿងវា ត្រូវរូបខ្មៅងងឹតសូន្យ ខ្ញុំមើលដៃនាងមិនឃើញ នាងក៏ដូច្នោះដែរ ម្លោះហើយ ដៃនាងនិងខ្ញុំប៉ះពាល់គ្នាដូចស្និទ្ធស្នាល ។ ខ្ញុំចាប់ម្រាមដៃនាងដោយចេតនានឹង បន្លំ ។ តែប្រហែលនាងឥតចាប់ភ្លឹកទេ ក្រោយមកនាងសើចចំពោះហេតុនេះ ។ ខ្ញុំឈ្លីមុខឈ្លីមាត់តាមបង្គាប់ នាងរួចហុចទៅនាងវិញ ម្រាមដៃបានប៉ះពាល់គ្នា តែមិនច្រវាត់ច្រវែងដូចមុនទេ

ត្បិតឆាករឿងវាត្រូវរូបសចោលពន្លឺភ្លឺមក ។ ពេលនេះខ្ញុំបានសន្មតតែម្នាក់ឯងថា នាងនិងខ្ញុំគឺជាប្រពន្ធប្ដីព្រោះយើងអង្គុយ ទឹមគ្នាហើយដឹងទុក្ខធុរៈគ្នា ។ កាលណាខ្ញុំសន្មតដូច្នេះ ក៏នឹកឃើញទៀតថា : ពេលយើងចេញពីរោងកុនទៅយើងនាំគ្នាទៅញ៉ាំបង្អែម ឬយើងនាំគ្នាដើរកំសាន្តសួនច្បារ រួចហើយយើងត្រឡប់ទៅផ្ទះវិញ យើងងូតទឹកជំរះកាយ យើងចូល និទ្រា ។ សេចក្ដីរិះគិតគឺវាទៅជាហូរហែលយ៉ាងនេះ ហើយរហូតដល់ទៅភ្លើងភ្លឺ ព្រាតឡើងតែម្ដង ។ កុនចប់ រឿងហើយ ។

មនុស្សគ្រប់គ្នា ក្រោកចាកកៅអីប្រជ្រៀតចេញទៅក្រៅវិញ ។ ខ្លះ ឡើងរ៉ឺម៉ក ខ្លះឡើងកង់ ខ្លះឡើងយានយន្ត ខ្លះដើរ រាល់គ្នាចេញពីកន្លែងនេះទៅ ។

ចំណែកយើងទាំង ៤ នាក់វិញក៏ត្រូវបែកគ្នាដែរ ។ មុនពេលដែលនាង និងមិត្តនាងបែកទៅ នាងក្រមុំមិនភ្លេចមិនលើក ដៃផ្គុំជំរាបលាខ្ញុំទេ ឯមិត្តនាងក៏ អីចឹងដែរ ។ ឡើងរ៉ឺម៉កហើយ នាងក៏មើលខ្ញុំដោយញញឹម ។ សម្រាប់ខ្ញុំសិត ការណ៍នេះដែលនាងសំដែងមកគឺជា សញ្ញានៃការរាប់អានលាយឡំទៅដោយ ទឹកចិត្តមេត្រីមកផង ។ ខ្ញុំញញឹមសងទៅនាងដែរមុននឹងឡើងលើរ៉ឺម៉កទៅនោះ ។ មិត្តសុវណ្ណ ជូនខ្ញុំដល់សណ្ឋាគារទើបគេលាខ្ញុំត្រឡប់ទៅផ្ទះគេវិញ ។

ខ្ញុំឡើងទៅកាន់វាសនដ្ឋានដោយស្ងប់ស្ងៀម ។ ទឹកចិត្តខ្ញុំពេលនេះ កក្រើករំជួលហើយខ្ញុំកើតសេចក្ដីត្រិះរិះហើយ ។

យីអញ ! មិនគួរចៃដន្យអីដល់ទៅម្ល៉េះ ។ តើអញនិងនាងនេះជាគូ សន្និវាសពីបុព្វេឬ តើនាងមានដឹងថា អញស្រឡាញ់នាងទេ ? ឱបើអញបានជា ស្វាមីនៃនាងក៏ប្រហែលជាអញនេះគេចាត់ទុក ជាអ្នកមានវាសនាធំហើយ ក្នុង ខណៈនោះអញនឹងទេវីត្រូវតែមានសេចក្ដីសុខ ។ សេចក្ដីសុខនោះនឹងស្ថិតស្ថេរ ចិរកាលទៅផង ដោយសារចិត្តស្រឡាញ់របស់អញទៅលើរូបនាងយ៉ាងគ្មានជិន ណាយ ។ តើមានទំនាស់អ្វីហ្ន៎ បើអំពើផ្ទាក់ផ្ទួមសឹងមានជាអលជ្ជីដល់រូបនាង តើអញខ្វះអំពើនេះកើតឬ បើរាងកាយល្អបណ្ដាច់ បូកនឹងចរិយារម្យទមសមជា ភរិយាប្រសើរយ៉ាងនេះទៅហើយ ។ ដូច្នោះហើយ គ្មានហេតុអ្វីឡើយមករំខាន ដល់ដំណើរសុភមង្គលរបស់យើងទេ ។

ឱ ទេវីមាសបង ! បងព្រមសារភាពហើយថា បងស្រឡាញ់ទេវីតែ មួយ ។ ស្រីដែលបងធ្លាប់ឃើញទាំងប៉ុន្មាន គ្រាន់តែជាស្រីប៉ុណ្ណោះ ពុំមានអនុ ភាពធ្វើឱ្យទឹកចិត្តទទួលរិះគិតដូចរូបទេវីទេ !

វាចានេះឮដល់ត្រចៀកខ្លួនឯង ទើបហាក់ភ្ញាក់ខ្មាសអៀន ក៏ប្រះដេក នន្ទៀលទៅ ។ ខ្ញុំខំបិទភ្នែកសំងំយកលក់ តែសេចក្ដីតប់ប្រមល់នៅតែបបួលខ្ញុំ ឱ្យនៅរិះគិតរឿងនេះដដែល ។ អស់កាលមិនដឹងជាប៉ុន្មានម៉ោងទេ ក្រោយមក នោះសេចក្ដីរិះគិតនេះក៏ស្រាប់តែកើតទៅជាទិស្សមានភាពមួយដ៏សែនមនោ រម្យទាំងឥតបានដឹងខ្លួន :

ខ្ញុំនិងទេវី យើងទាំងពីរអង្គុ នៅលើទែនសយនា ។ ខ្ញុំត្រកងកាយនាង យ៉ាងពេញចិត្ត :

- ទេវី !

- ចាសបង !

- បងស្រឡាញ់ទេវីណាស់ ទេវីគឺជាដួងជីវិតរបស់បង តើទេវីអូននាង មានលក្ខណចិត្តដូចបងទេ ?

- ចាសបង អូនក៏ស្រឡាញ់បងណាស់ដែរ បងក៏ជាពន្លឺនៃជីវិតរបស់ អូនដែរ អូនមានសេចក្ដីស្នេហាមិនតិចជាងបងទេ ចាស !

នាងរំកិលក្បាលដ៏មានសក់ទន់ល្មើយដូចសំឡីមកលើទ្រូងខ្ញុំ ។ ខ្ញុំថ្នាក់ ថ្នមចង្កេះនាងដោយដៃម្ខាង ហើយម្ខាងទៀត បរបោសផាត់សក់នាង ដែលពីរ បីសរសៃធ្លាក់មកគ្របលើភ្នួងថ្ពាល់នាង ។ ខ្ញុំឱនទាសាផ្ចិតផ្ចង់ក្រេបសម្ផស្សមុខ នាងដោយពិសម័យ ។ ដួងនេត្រយើងសំឡឹងគ្នាយ៉ាងជិត រូបខ្ញុំបានចាំផ្ចិតនៅ ក្នុងកែវកូនក្រមុំថ្លារបស់នាង ឯខ្ញុំក៏ស្មានមិនខុសថា កែវភ្នែកខ្ញុំក៏មានរង្វង់ភក្ត្រ ទេវីជាប់នៅផងដែរ ។ យ៉ាងនេះយើងប្រាថ្នាស្ដាប់ចង្វាក់ដង្ហើមគ្នាទៅវិញទៅ មក ។ យើងប្រឱបគ្នាយ៉ាងណែនដៃ ។ នាងមានសម្ផស្សក្រហមព្រឿងពោរពេញដោយស្នេហា តែចិញ្ចើមដែលកោងនោះបែរជាចងជ្រួញ ឡើងទ្រនុងទំនង ព្រួយ ហើយបបូរមាត់ពណ៌កូលាបក៏បន្ទាត់វាចា :

-បងចាស អូនប្រាថ្នាឱ្យចិត្តគំនិតបងនៅតែយ៉ាងនេះរហូតទៅ ។ បង ចាស អូនសូមឱ្យសេចក្ដីសង្ឃឹមរបស់អូន ដែលប្រាថ្នាសាងសុភមង្គលជាមួយ បងនោះ មានរូបរាងអស់កាលជាយូរអង្វែងទៅ ទល់នឹងមរណកាលរបស់យើង ។

ហើយសេចក្តីទៀងត្រង់របស់យើងនឹងផ្តល់នូវសុភមង្គលដដែលនេះ ដល់ជីវិត ថ្មីដែលយើងនឹងប្រាកដឡើងក្នុងអនាគតជាតិ ។ តើបងពេញចិត្តនឹងបំណងនេះ ទេ ចាស ។

វាចានេះសែនពិរោះផ្អែមល្ហែមបំផុត ខ្ញុំឱនថាសាជម្ពិតប្រាង្គនាង ដោយចិត្តស្នេហាដ៏លើស :

- ទេវីអូន ចិត្តគំនិតសេចក្តីប្រាថ្នារបស់អូនមានយ៉ាងណា បងក៏មាន យ៉ាងនោះដែរ ហើយបងក៏បានដឹងនិងទុកចិត្តជឿថា សេចក្តីសុខក្សេមក្សាន្ត របស់គូស្នេហា វាសឹងមានកំណើតមកអំពីការស្មោះត្រង់ចំពោះគ្នានិងគ្នា ។ រូប បង បងមានចិត្តស្រឡាញ់អូន បងនិងអូន យើងប្រាថ្នាជាពិសេសនូវសេចក្តីសុខ ក្សេមក្សាន្តឬថា សុភមង្គល ។ បើដូច្នោះ តើមានហេតុអ្វីនឹងនាំឱ្យបងនិរាសចិត្ត ពីអូន ដែលជាហេតុប្រហារបង់នូវសុភមង្គលរបស់យើងទាំងគូនោះ ។ ម្យ៉ាង វិញទៀត ប្រហែលជាយកមកនិយាយបានដែរថា ជីវិតយើងពិតជាប្រសូតមក ព្រមគ្នា អំពីព្រះឱស្ឋទិព្វរបស់ព្រះព្រហ្មនិងព្រះនាងឧមាភោគវតី បើដូច្នោះជីវិតយើងជាជីវិតមានន័យតែមួយរួមគ្នា យើងគ្មានបំណងអ្វីផ្សេងគ្នាទេ ទេវីអូន . . . !

នាងស្តាប់ដោយញញឹមពេញចិត្តហើយហត្ថទាំងគូក៏លើកឡើង ប្រឱប កខ្ញុំ ខ្ញុំបន្ទាបតាមដរាបដល់នាសាមកផ្ទាល់នឹងវង្វង់ភក្រ្តនាង ខ្ញុំរំកិលបង្ហូតមក លើល្វែងទ្រូងនាង ។ ក្លិនសម្ផស្សធម្មជាតិក្រអូប ប្រហើរសែនគាប់ចិត្តហួសថ្លឹង ថ្លែង ។ នាងនៅស្ងៀម ខ្ញុំក៏គេងផ្ទៀងលើទ្រូងនេះបន្តិច ខ្យល់ចង្វាក់បេះដូងនៃ នាង លោតតិច១ជាធម្មតា ហាក់បំពេរត្រចៀកខ្ញុំ ដែលផ្ទាប់នោះឱ្យពិរោះចង់ លក់ ។ ខ្ញុំងើបឡើងវិញដោយក្រែងនាងធុន់ ប៉ុន្តែមើលទៅភក្រ្តនាង នាង ញញឹម ដូចជាសប្បាយទៅវិញទេ ។ ប៉ុន្តែខ្ញុំក៏មិនបានគេងកើយរបៀបនេះទៀតដែរ ខ្ញុំដាក់ក្បាលទៅលើខ្នើយវែងជាមួយនាង ។ កើយខ្នើយមួយពីរនាក់ យើងគេងទល់មុខគ្នាដៃប្រឱបគ្នា ដោយទឹកចិត្តមនោរម្យនិងសមង្គី ។ ភក្រ្ត នាងក៏គឺ ជាទេពអប្សរសុទ្ធសាធដែល នៅប្រត្យក្សនឹងភ្នែកខ្ញុំ ខ្ញុំសម្លឹងនាងយ៉ាង ផ្ចង់ :

ទេវីអូន អូនល្អអីម្ល៉េះ ថ្ពាល់ផូរផង់មានខួចបន្តិចសមនឹងប្រអប់មាត់ ដែលមានបបូរស្តើងពណ៌កូលាប ចិញ្ចើមកោងដូចដងធ្នូ ដួងនេត្រខ្មៅថ្លាដូច គ្រាប់នីល. . . ដើមទ្រូងសាច់ម៉ដ្ឋដូចលំអង្កា . . .

- ឈប់ ! ( នាងយកដៃខ្ទប់មាត់ខ្ញុំ បង្អាក់សំដីហើយញញឹមផ្សំផង នាងនិយាយតប ) :

- បានហើយចាស បងវិញក៏ល្អណាស់ដែរ ច្រមុះស្រួចសមនឹងមុខ មាត់ . . . អា អីទៀតទេ ខ្ញុំពុំចេះសរសើរឱ្យបានហូរហែដូចបងទេ ចាស ។

បន្ទាប់ពីសំដីនេះនាងក៏បិទដួងនេត្រមមីទំនងងងុយមែនហើយ នាង និយាយតិច១ថា :

- បងចាស អូនងុយគេងណាស់ចាស

- គេងចុះអូន . . . បងនៅបំពេរ

នាងញញឹមទាំងបិទភ្នែកគួរស្នេហាក្រៃលែង ខ្ញុំចាប់ច្រៀងរហឹម១ នូវបទចម្រៀងលួងលោមដែលជារបស់លោកស៊ិនស៊ីសាមុត :

- ឱ ស្រស់ប្រិមប្រិយសូមស្រីងាកមក រៀមរកចម្រៀងដើម្បីនឹង ច្រៀងលួងលោម ស្រស់ណាស់នេត្រា ស្រស់ទាំងរូបឆោម ចិត្តចង់ ផ្ទាក់ផ្ទមបី បមកាយា ។

-ហត្ថា ដែលស្រាលរៀមអង្អែលស្រី សំដីពិរោះកួចចងដួងចិត្ត ស្នេហា ប្រាប់រឿងសម្ងាត់លាក់ក្នុងឱរា ដែលប្រាប់ស្នេហាចំពោះរូបស្រី ។

- ជាយូរអង្វែងមកហើយ ដែលចិត្តរៀមឥតស្បើយ ព្រោះតែចិត្តកួច បេតី ចិត្តលួចស្នេហ៍ប៉ុន្តែមិនហ៊ានស្រដី ឥឡូវបានមកជួបស្រី នេះគឺនិស្ស័យបង មាន ។

- មើលចុះព្រះចន្ទក៏ជួយញញឹម ប៉ប្រិមប៉ប្រិ ឃើញក្តីប្រាថ្នា បងបាន ជួបសង្សារ នឹងកែវកល្យាណ ស្នេហ៍ដល់អវសានឥតបីប្រួលប្រែ ។

ខ្ញុំច្រៀងបទនេះជាច្រើនសាដរាប នាងគេងលក់ទាំងញញឹមទៅ ។ ខ្ញុំ ពុំហ៊ានប៉ះពាល់នាងទេ ខ្លាចនាងចាកនិទ្រាឡើងវិញ តែដៃដែលដាក់គងលើស្មា នាងនោះ ខ្ញុំឥតបានដកវិញទេ ខ្ញុំសម្លឹងនាងប្រកបដោយទឹកចិត្តស្នេហា ជីពចរ ត្រង់បំពង់កលោតតិចៗ មើលទៅគួរអាណិតនិងរិតតែស្រឡាញ់យ៉ាងពោរ ព្រៀប ។ ដឹងថា នាងគេងលក់ស៊ប់ហើយ ខ្ញុំក៏ថ្នមថើបថ្ពាល់នាងដោយចិត្ត មនោរម្យ ។

ស្រាប់តែក្រិកៗ .. . ក្រិកៗ និងឮសម្លេងល្វើយមកប៉ះនឹងត្រចៀក : ចរណៃ ! ចរណៃ បើកទ្វារ ។ ខ្ញុំភ្ញាក់ក្រញាងឡើង បាត់រលីងនូចទិស្សមានភាព បាត់ភ្លាមនូវរូបកាយទេវី ដែលកំពុងគេងជិតខ្ញុំ ។ ខ្ញុំភាំងវិញ្ញាណបន្តិចទើបមាន ស្មារតីឡើងវិញ : យី អញយល់សប្តិទេតើ ខ្ញុំដកដង្ហើមធំព្រោះនឹកអស្ចារ្យក្នុងចិត្ត ។ ងើបដើរទៅកាន់ទ្វារ ពេលនោះកាំរស្មីព្រះអាទិត្យ ចាំងចូលមកតាម ចន្លោះត្រចៀកបង្អួច ដែលបើកបន្តិច ។ ថ្ងៃរះពេញពន្លឺទៅហើយ ។ មើលនាឡិ កាដៃឃើញម៉ោង ៧ និង១០ នាទី ។ សម្លេងហៅ និងមូលគន្លឹះទ្វារបានបន្លឺមក ទៀត : ចរណៃ បើកទ្វារដេកពុំទាន់ងើបទេឬ ? ស្តាប់ទៅស្គាល់ច្បាស់ជាសុវណ្ណ ខ្ញុំបើកទ្វារដោយកិរិយាធេងធោង ។ សុវណ្ណចូលមកដល់សួរខ្ញុំដោយញញឹម :

ម៉េចឯងដើរលេងឯណាទៀតល្ងាចម៉ិញ ទើបបានដេកទើសបែក អាចម៍អីចេះ ?

- ទេគ្នាឥតទៅណាទេ តែដេកមិនលក់ ទើបតែលក់ប្រហែលជារំលង អធាត្រនេះតែម្តង ។

- ឯងរវល់តែនឹកនាងទេវីឬ ។

ឮតែឈ្មោះនេះភ្លាម ខ្ញុំរំជួលចិត្តភ្លាម ព្រោះវាពិតជារឿងហ្នឹងមែន ។ ខ្ញុំសឹងតែដកដង្ហើមធំឱ្យឮតែម្តងដើម្បីបានធូរទ្រូងបន្តិច ។ ប្រហែលជាគេ សង្កេតទឹកមុខខ្ញុំបានយ៉ាងណាហើយ បានសុវណ្ណ និយាយចំៗថា :

- ចរណៃ ឯងមិនបាច់លាក់ដល់ណាទៀតទេ តោងឯងនិយាយពិតៗ មកវាប្រសើរជាង ក្រែងគ្នាអាចជួយជ្រោមជ្រែងឯងបាន ។

ពេលនេះដោយសារហេតុការណ៍ វាច្បាស់ពេកខ្ញុំសឹងតែរបូតមាត់សារ ភាពចំពោះសំនួររបស់មិត្តទៅហើយ ។ ប៉ុន្តែដោយនឹកឃើញដល់ក្តីខ្មាសអៀន ច្រើន ខ្ញុំត្រូវតែការពាររឿងអាថិកំបាំងនេះតទៅទៀត:

- សុវណ្ណឯងកុំដេញដោលគ្នាធ្វើអ្វី គេរាល់គ្នាដែលដេកបែកអាចម៍ថ្ងៃ ដែរនោះ តើមកពីគេគេងព្រួយនឹងស្នេហាដែរឬអី ។ ឯងកុំយល់ច្រឡំ គ្នាចិត្តរឹង ប៉ឹងណាស់ មិនចេះស្រឡាញ់ស្រីដូចគេដល់ទៅដេកមិនលក់នោះទេ ហើយទេវី ក៏មិនទាន់ធ្វើឱ្យគ្នាវង្វេងគំនិត ដល់ទៅម្លេ៉ះដែរ ។

- ហ៊ឺ នៅអាចារ្យទៀតទៅលោកអើយ ល្អយ៉ាងទេវីហើយនៅតែបដិ សេធទៀត ។ ឈ្លើយទៅលប់មុខទៅ ទៅលេងអង្គរធំ ។

ខ្ញុំដូចជាបានជោគជ័យពីលើសុវណ្ណវិញម្តង ។ ខ្ញុំចូលទៅបន្ទប់ទឹកជំរះ កាយ រួចចេញមកស្លៀកពាក់សួរសុវណ្ណ បណ្តើរពិមធ្មេញបាយទៅលេងនោះ :

- យើងទៅដោយអីសុវណ្ណ ?

យើងទៅរ៉ឺម៉កទៅ ! គ្នាវាគ្មានឡានអីដូចទេវីទេ ។

និយាយព្រមទាំងសើចមកផង ។ ខ្ញុំមិនចេញស្តីទេ ព្រោះនឹកថា សុវណ្ណ ចេះនិយាយបញ្ចិតបញ្ចៀងណាស់ និយាយរឿងឯណាក៏ដោយ សុវណ្ណ អាចឆ្លៀតបញ្ចូលរឿងដដែលនេះមកបានទៀត ។ ការបញ្ចូលរឿងដូច្នេះ ថ្វី ត្បិតតែខ្ញុំនឹកខ្មាសអៀន ក៏ខ្ញុំនៅតែពេញចិត្តនឹងស្តាប់ដែរ ។ កំពុងជជែកនោះ ស្រាប់តែសូរកុបៗ. . . ឡើងមក ។ ងាកទៅមុខ វង្សក៏ច្បាស់ឡើង គេសើចមក កាន់យើងទាំងពីរ ។ បន្ទាប់នោះលេចនាងទេវីពីក្រោយមកដែរ ។ ខ្ញុំចាំមើល ទៀតក្រែងមានអ្នកណាទៀត តែគ្មានទេមានតែទេវីនិងវង្សប៉ុណ្ណោះ ។ វង្ស ចាប់ដៃខ្ញុំរួចទៅចាប់ដៃសុវណ្ណទៀតព្រមទាំងនិយាយថា :

គ្នាខកដំណើរបន្តិច ដោយខំទៅរកសុវណ្ណឯផ្ទះ ឯណោះមិនជួប ។ សួរ អ៊ំម្តាយសុវណ្ណឯងទៅគាត់ប្រាប់ថា ឯងមកបបួលមិត្តឯណេះទៅលេងអង្គរធំ ទើបគ្នាមករកឯណេះឯង ។

- ចុះឯងរកគ្នាមានការអ្វី វង្ស !

គ្នាមកបបួលឯង និងមិត្តឯណោះទៅលេងអង្គរធំ ត្បិតឮគេថា មានគេ ធ្វើបុណ្យ សំពះព្រះពុទ្ធគោកធ្លកនោះផង ក្រែងឯងបានដឹងដែរឬ !

- ហ្នឹងឯង បានជាគ្នាមកអញ្ជើញលោកដុកទ័រនេះ (សុវណ្ណ ចង្អុល មកខ្ញុំ) ឱ្យទៅលេងផងទៅចុះព្រះអាណិតលោក ដែលមកពីឆ្ងាយម៉ង់ គ្មាន ស្គាល់នរណាម្នាក់សោះ ។

- គ្នាក៏មកអញ្ជើញមិត្តនេះដែរ ព្រោះគ្នាចង់ឱ្យមិត្តនេះបានសប្បាយ រីករាយនៅនឹងស្រុកយើងផង ម្យ៉ាងទៀតជាការតបស្នង ដល់គុណបំណាច់ដែល មិត្តនេះ បានជួយសង្គ្រោះលោកប៉ាគ្នានោះឯង ។ បើគ្នាដឹងថាសុវណ្ណនៅឯណោះ ស្រាប់នោះ គ្នាប្រហែលជាមកឯណោះ ទៅហើយ ពុំចាំបាច់ទៅរកមិត្តឯផ្ទះនាំ ខាតពេលទេ ។

- ចុះអ្នកទេវី មកធ្វើអ្វីដែរ ?

សុវណ្ណសួរទៅនាងក្រមុំដែលឈរធ្មឹងក្បែរវង្សជាបង ។ នាង ក៏តប បែបព្រងើយថា :

- ទៅលេងផងមិនបានឬ !

- រកតែគេហ៊ឺហាស្រីស្រាំងផងមិនបានទេ តាមឱ្យស្អិតដូចកូនក្មេងអី ចឹង ! ម៉េចខ្លាចវង្សផ្តេសផ្តាសហើយចាំជំរាបលោកអ៊ំប្រុស អ៊ំស្រីឬ !

វង្សក៏ឆ្លើយស្របនឹងពាក្យសុវណ្ណថា :

- មែនវ៉ី! វាតាមឯងរកតែកេរ៍នាយកេរ៍អាយមិនបាន ។ ឯងសង្ឃឹម ថាបានរាំកេរ៍ហើយលើកនេះ ស្រាប់តែវាមករំខានឯងទៀត បើឯងមិនឱ្យវាមក វាតាំងលំអុកប៉ាម៉ាក់ ហើយជំរាបអីចេះ អីចុះ ជូនកាលថាឯងបញ្ចិះឡានពួក លីសេស្រីៗអ៊ីៗទៀត . . . ហ៊ឺ ពិបាកណាស់គ្នា ។

វង្សថ្វូរទ្រង់ជូរចត់ ។ ទេវីក៏តបបែបខឹង តែសំដីស្តាប់ទៅបែរជាពិរោះ

- ឃើញមែនមិនឱ្យគេថា ! ហើយលោកវណ្ណឯងក៏មិនណយដែរ វា ត្រូវតែជើងគ្នាហ្នឹងឯង !

ឯងថាខ្ញុំរំខាន រំខានអីខ្លះ ចង់រាំ ចង់រែកអីធ្វើទៅ គ្រាន់តែតាមដោយ សារទៅលេងប៉ុណ្ណេះវាខានសប្បាយម៉េចខ្លះ ។ ហើយឥឡូវនេះ បើថាខ្ញុំរំខាន ព្រោះទៅតាមលេងបុណ្យនឹងគេនោះ ខ្ញុំក៏មិនខ្ចីទៅដែរ ខ្ញុំទៅផ្ទះវិញហើយ ។ ប៉ុន្តែចាំមើលតែដល់ផ្ទះហ្នឹងណា . . . ។

នាងឈានជំហានទៅរកទ្វារ ធ្វើឱ្យខ្ញុំនឹកស្តាយ ប៉ុន្តែពេលនោះនាង ផ្អាកដំណើរ ព្រោះសុវណ្ណម្នីម្នាឃាត់ :

- ឈប់សិនអ្នកវី ខ្ញុំថាលេងទេ កុំទៅប្រាប់លោកអ៊ំ អាណិតខ្ញុំទៅ ។

- ឃាត់ធ្វើអី ខ្លាចធ្វើអី ក្រែងខ្ញុំរំខានឬ អញ្ជើញទៅចុះ !

- ទេ ទេ ខ្ញុំថាលេងទេ ទៅយើងទៅទាំងអស់គ្នា

- ហ្នឹងហើយ ឱ្យតែមិនឱ្យវីទៅលមើល មិនវង្សត្រូវប៉ាម៉ាក់ចង្អុលមុខ ឱ្យលោកវណ្ណឯងឃើញឥឡូវហ្នឹង !

វង្សញញឹមហើយឆ្លើយបែបអង្វរ :

- ហ្នឹងហើយ អញខ្លាចលោកជំទាវឯងហើយ នាងអើយ ទៅជាមួយ អញទៀតចុះ អាណិតកុំទៅផ្ទះវិញ ឱ្យគាត់កិនអញទៀតនោះ ។

ការជជែករបស់អ្នកទាំងបី នាំឱ្យខ្ញុំដឹងថា ទេវីត្រូវមាតាបិតាស្រឡាញ់ ថ្នាក់ថ្នមជាទីបំផុត ។ ម្យ៉ាងទៀតនាំឱ្យដឹងថា នាងគ្មានដែលទៅជាមួយនរណា ក្រៅពីបងប្រុសនេះទេ ។ ពេលនេះកិរិយាងរងេចរបស់នាងធ្វើឱ្យខ្ញុំរឹតតែ ស្រឡាញ់ខ្លាំងឡើង : នាងងរឱ្យគេអង្វរ ។

កាលបើនិយាយចុះសម្រុងគ្នាហើយ សុវណ្ណ វង្ស ទេវី ហើយនិងខ្ញុំនាំ គ្នាចុះមកកាន់រថយន្ត ។ យើងបរសំដៅទៅផ្សារ ដើម្បីស្រស់ស្រូបអាហារពេល ព្រឹកមុននឹងចេញដំណើរទៅទៀត ។

នៅក្នុងរថយន្ត ខ្ញុំបានតាំងស្មារតីយ៉ាងខ្ជាប់ខ្ជួនដើម្បីនឹងចាំមើលអស់ ទាំងប្រាសាទនានា ដែលមុខជានឹងបានឃើញតាមពាក្យនាងទេវីនិយាយកាលពីថ្ងៃម្សិល ។ ចេញផុតពីមុខអង្គរវត្តដែលខ្ញុំបានឃើញរួចហើយកាលពីថ្ងៃម្សិល នោះ រថយន្តចេះតែទៅមុខជាលំដាប់ ជាញឹកញាប់

វង្សអ្នកកាន់ចង្កូតចេះតែឱ្យ សញ្ញា ទីន ទីន ! ដើម្បីឱ្យរ៉ឺម៉កដែលផ្ទុកអ្នកដំណើរ មានស្រី មានប្រុសនោះ ចៀស អែបទៅខាង ។ សុវណ្ណដែលនៅអែបនឹងវង្សខាងមុខនោះ ងាកមក ញញឹមរក ទេវី ដែលអង្គុយខាងក្រោយជាមួយខ្ញុំ ហើយគេសួរមកកាន់ខ្ញុំថា :

- ចរណៃ ! គ្នាភ្លេចសួរឯងឈឹង តើឯងគិតទៅវិញថ្ងៃណា ?

- គ្នាគិតថាទៅវិញ ថ្ងៃស្អែកនេះណា សុវណ្ណ ។

- បើអីចឹង យើងមើលប្រាសាទតាមវង់ធំតែម្ដងទៅ កុំចាំបាច់មើល តាមវង់តូចធ្វើអីក្រែងមើលពុំអស់ ។

- វង់តូវវាយ៉ាងម៉េច ហើយវង់ធំនោះវាយ៉ាងណា ?

ខ្ញុំសួរដោយមិនយល់ ។ សុវណ្ណសើចបែរមុខទៅវិញ ។ នាងក្រមុំបែរ ជាឆ្លើយជំនួសឡើងព្រមទាំងលើកដៃមករៀបរាប់ម្រាមផង

- វង់តូចនោះ យើងចេញពីប្រាសាទបាយ័ន ទៅកើតឃើញ ប្រាសាទ ចៅសាយ, ធម្មានន្ទ, តាកែវ, តាព្រហ្ម, បន្ទាយក្ដី, ស្រះ ស្រង់ ហើយបត់ទៅ អង្គរតូចវិញ ឬក៏បត់មកចូលប្រាសាទបាយ័នវិញក៏បាន ។

ឯវង់ធំនោះគឺ យើងបន្តដំណើរពីវង់តូច គឺថាយើងទៅពីស្រះស្រង់ទៅ ទៀត ទៅទិសឥសាន : ឃើញប្រាសាទប្រែរូប, មេបុណ្យ, តាសោម, បត់ទៅ លិចដើម្បីឃើញប្រាសាទនាគព័ន្ធ, ក្រោលគោ, បត់មកត្បូងមើលប្រាសាទ ព្រះ ខ័ន ទើបចូលមកអង្គរធំវិញ មើលប្រាសាទសួព្រ័ត្រ នឹងឃ្លាំង, ព្រះពិធូរ, បាលិ លេយ្យ, ព្រះទេពប្រណម្យ វិមានអាកាស, និងប្រាសាទបាពួន រួចទីបញ្ចប់ គឺ យើងជួបប្រាសាទ បាយ័នវិញ ។ ម៉េចទៅលោកស្ដាប់ទាន់ទេ ហើយអាចចាំទេ ចាស ។

- បាទ ! តែថាមិនងាយនឹងចាំឱ្យហួរហែទេ ទើបតែមកម្ដងយ៉ាងនេះ

- ចាស ! លោកឧស្សាហ៍មកលេងញឹកញាប់ទៅ គង់ស្គាល់ ហួរហែ មិនខាន ។ មិនពិបាកចំណាំទេ វង់ធំយើងចង់ចេញពីខាងជើង ហើយបត់ទៅខាង កើតវិញក៏បាន គឺថាយើងចាប់មើលបង្ហួតពីប្រាសាទ បាពួន, វិមានអាកាស, ទេពប្រណម្យ, បាលិលេយ្យ ព្រះពិធូរ, សួព្រ័ត្រ និងឃ្លាំង, ចេញទៅជួបប្រា សាទព្រះខ័ន, នាគពន្ធ័ បត់ទៅកើតមកត្បូងវិញទៀត ឃើញប្រាសាទតាសោម មេបុណ្យ, ប្រែរូប ហើយបត់មក លិចវិញ ជួបស្រះស្រង់និងបន្ទាយក្ដីដដែល ។ ត្រង់នោះ យើងចង់ទៅអង្គរវិញក៏បាន ចង់ត្រឡប់មកវង់តូចវិញក៏បាន បើចង់ ឃើញប្រាសាទ បាយ័នជាថ្មីទៀត ។ ដូច្នេះឃើញថា ដំណើរទៅមើល ស្រេចតែ ចិត្តយើងចង់ទេ ទៅខាងទិសណាមុនក៏បានដែរ លោកចាំ សង្កេតចុះចាស ! នំ .ឥឡូវឃើញក្លោងទ្វារអង្គរធំហើយ !

ខ្ញុំក៏ឃើញភាពសទទុងនៅពីមុខ ហើយនៅពីឆ្វេងដៃក៏ឃើញភាពស្ដឹម ស្ដែមួយដែរ ។ សុវណ្ណងាកមកប្រាប់ខ្ញុំថា :

- ប្រាសាទមួយនោះនៅឆ្ងាយពីផ្លូវបន្តិច ហើយខ្ពស់ផងឈ្មោះ ប្រាសាទបាខែង យើងរំលងប្រាសាទនោះទៅចុះ ព្រោះយើងគ្មានពេលគ្រប់គ្រាន់ ។

ហើយនៅមានប្រាសាទមួយទៀត ដែលខ្ញុំមើលទៅឃើញនៅដាច់តែ ឯង ប្រុងនឹងសួរសុវណ្ណ តែគេរហ័សនិយាយមុនថា :

- នេះឈ្មោះប្រាសាទបក្សីចាំក្រុង

- បក្សីចាំក្រុង ដូចក្នុងរឿងប្រលោមលោក របស់លោកប៊ីវ ឆៃលាង នោះឬ ?

- ទេ គ្នាមិនដឹងដល់ទៅ ប្រវត្តិបក្សីចាំក្រុងនោះទេ ប៉ុន្តែ ចរណៃ ចាំ តែឈ្មោះ បក្សីចាំក្រុងប៉ុណ្ណឹងទៅបានហើយ ។ ហក នំ, ឥឡូវយើងដល់មុខ ក្លោងទ្វារអង្គរធំហើយ ។

- អើរ៉ឺ ចំឡែកណាស់ហ្ន៎ គ្នាមិនដែលឃើញទេ សំបើម ណាស់ហ្ន៎ ។

ខ្ញុំបានឃើញនូវភាពចំឡែក នៅអមផ្លូវនោះ គឺរូបយក្សនិង មនុស្ស ពាក់មកុដកំពុងទាញនាគមួយ ។ នាគនោះងើបក្បាលមករកអ្នកដំណើរ ឯកន្ទុយនោះបែរទៅកាន់ក្លោងទ្វារ ។ អស្ចារ្យណាស់ ខ្ញុំពុំដែលឃើញក្លោងទ្វារ ណាធំសំបើមដូចក្លោងទ្វារនេះទេ ។ នៅពីលើកំពូលមានរូបព្រហ្មញញឹមទ្រ ដោយក្បាលដំរី ដែលមានប្រមោយទម្លាក់យ៉ាងសង្ហា ។ រថយន្តបរចូលផុតមក នាងទេវី និយាយប្រាប់ខ្ញុំថា :

- នេះហើយគឺទ្វារអង្គរធំៗមិនមែនមានតែទ្វារមួយនេះទេ មានទាំង អស់ ៥ ដែលសឹងតែដូចៗគ្នា នាំឱ្យយើងច្រឡំផង ។

ខ្ញុំទទួលងក់ក្បាលជំនួសពាក្យបាទ ! យ៉ាងគួរសម ។ ភ្នែកខ្ញុំ ក៏ចាំរំពៃ មើលទេសភាពឯទៀត ។ មិនយូរប៉ុន្មានរថយន្តបានទៅដល់ប្រាសាទមួយយ៉ាង ល្អឆើត មានកំពូលសុទ្ធតែក្បាលព្រហ្មញញឹមមករក ។ រថយន្តឈប់ ។ សុវណ្ណ ប្រាប់ខ្ញុំថា :

- នេះគឺប្រាសាទបាយ័ន ។ ប្រាសាទនេះនៅកណ្ដាលក្រុង អង្គរធំ ។ យើងនឹងឡើងមើលប្រាសាទនេះ ប៉ុន្តែឥឡូវនេះត្រូវយើងទៅថ្វាយបង្គំព្រះពុទ្ធ គោកធ្លកសិន ដែលមានមនុស្សកុះករឯណោះ ឯងឃើញទេ ។

- ខ្ញុំក៏ងក់ក្បាលជំនួសពាក្យ អឺ ! យើងចុះពីលើឡានទាំងអស់គ្នា ហើយឆ្ពោះទៅកន្លែងដែលមានមនុស្សមីរ ។ នៅអមផ្លូវនោះមានអ្នកលក់ភ្ញីផ្កា និងធូបទៀនដែលតាំងរបស់ទាំងនេះនៅលើកញ្ច្រែង ។ គ្រាន់តែឃើញយើងដៃ ទទេនោះ អ្នកលក់នោះ ស្រែកហៅឱ្យទិញជាពាក្យរជីនរជីន ។

- អញ្ជើញជួយទិញទៅអ្នកអើយ ផ្កានេះស្រស់ណាស់

- លោកប្រុសលោកស្រី មិនទិញធូបទៀនផ្កាភ្ញីថ្វាយព្រះទេឬ ? កន្លែងនេះឯងមានលក់ចាស ។

វង្ស និងសុវណ្ណមិនអាចទៅហួសកើត ក៏គោងតែឱនឈ្ងោករើសរកផ្កា និងធូបទៀននៅកញ្ច្រែងមួយនោះ ឯទេវីរើសនៅកញ្ច្រែងមួយទៀតដែរ ។នៅ តែខ្ញុំមិនដឹងទិញអ្វីនឹងគេ ក៏ឈរមើលគេព្រងើយ ទាល់តែនាងទេវីហៅខ្ញុំ :

- មករើសឯណេះលោក ។ លោកគោងជ្រើសរើសផ្កានិង ទៀនធូប យកទៅថ្វាយព្រះនឹងគេទៅ មកដល់ហើយដៃទទេ មិនគួរទេចាស ។

- បាទ បាទ !

ខ្ញុំក៏ចាប់ជ្រើសផ្កា និងធូបទៀនតាមបង្គាប់របស់នាង ។ តាមមើល ទៅមិនចាំជ្រើសរើសផងទេ ព្រោះគេដាក់លក់នោះមានដុំប៉ុនៗគ្នាទាំងអស់ ឯ លំអក៏ស្រស់ដូចគ្នាដែរ ។នាងក្រមុំដែលមានប្រាក់ កំពុងរាប់ឱ្យថ្លៃអ្នកលក់ ស្រាប់នោះនាងចេញថ្លៃជួសខ្ញុំ ។

កាលបើបានគ្រឿងទាំងនេះហើយ គេនាំខ្ញុំទៅកាន់កន្លែងដែលបាន និយាយ ។ ទីនោះមនុស្សណែន ដូចជាបុណ្យតាំងតុអុំទូកនៅភ្នំពេញអីចឹង ។ គឺគេទាំងនោះនាំគ្នាមកថ្វាយបង្គំព្រះពុទ្ធរូប ។ ព្រះពុទ្ធរូបនោះ គឺជាព្រះជីរមួយ អង្គ ដែលមាននៅកណ្ដាលវាល មានតែដំបូលប្រក់ពីលើ ។ មនុស្សណែនណាន់ តាន់តាប់មួយចេញ មួយចូល ។ ខ្ញុំនិងអ្នកទាំងបីក៏បានចូលទៅដល់ជិតបល្ល័ង្ក ដែលពោរពេញទៅដោយភ្ញីផ្កានិងធូបទៀន ។ ខ្ញុំចាប់អុជធូបនិងទៀន ព្រម ទាំងថ្វាយបាច់ផ្កានោះចំពោះព្រះពុទ្ធរូបដោយចិត្តជ្រះថ្លា ប៉ុន្តែខ្ញុំដូចជាលុះដោយ ជំនឿពេកក៏នឹកខ្សឹបៗថា :

- ឱព្រះពុទ្ធជាម្ចាស់ ! សូមលោកជួយឱ្យខ្ញុំបាននាងដែលនៅជិតខ្ញុំនេះ ជាភរិយាទៅអនាគតផងព្រះអង្គ !

នាងទេវីដែលនៅជិតខ្ញុំ ពេលនាងថ្វាយបង្គំនោះក៏ខ្សឹបដែរ តែខ្ញុំមិន ដឹងជានាងនិយាយថាម៉េចខ្លះ ។ ដៃនាងដែលប្រណមនោះ សែនសមអស់យ៉ាង ។ រួចរាល់ហើយយើងនាំគ្នាចេញមកវិញ កាត់ហ្វូងមនុស្សសំដៅរថយន្ត ខ្ញុំរៀប តែបើកទ្វារឡើងជិះ ស្រាប់តែវង្សប្រាប់ទាំងអស់គ្នាថា :

- នាំគ្នាចូលមើលកន្លែងខាងត្បូងនេះទៅ ខ្ញុំបើកទៅចាំឯជើងមុន ។

ខ្ញុំនឹកថា ម៉េចក៏គេចាំបើកឡានទៅចាំឯណាឯណោះមុន ទៅទាំងអស់ គ្នាមិនកើតឬ ?

សេចក្ដីឆ្ងល់របស់ខ្ញុំនេះ ត្រូវបាននាងទេវីជំរះ ដោយរីករាយថា :

- មិនអីទេលោក ! ឱ្យបងវង្សគាត់បើកទៅចាំឯជើងចុះ យើងមើល ប្រាសាទនេះពីខាងត្បូង ហើយឆ្លងទៅជើងទៅជួបនឹងគាត់ឯណោះបាន ចាស ។ នៅមានប្រាសាទឯទៀតដូចជាប្រាសាទ ព្រះខន័ជាដើម ដែលយើងអាចចូល ពីខាងកើតមកចេញខាង លិចបានត្បិតអីថ្នល់វាបត់កុងជុំវិញទេ ចាស ។

- បាទ អីចុះទេឬអ្នក ។

- ចាស អីចឹងឯង ។

វង្សបើកឡានទៅ ។ ខ្ញុំត្រូវសុវណ្ណ និងទេវីនាំចូលទៅកាន់ប្រាសាទដ៏ អស្ចារ្យនោះ ។

គ្មានទឹកចិត្តនរណាម្នាក់រំភើបជាងខ្ញុំឡើយ ទឹកចិត្តខ្ញុំពេលនេះ ស្ងប់ ស្ងែងក្រៃលែងចំពោះប្រាង្គដ៏វិចិត្រនេះ ។ កំពុងតែគយគន់ដោយយកចិត្តទុក ដាក់នោះ សុវណ្ណនិយាយដោយភ្ញាក់ផ្អើលថា :

- អុញនុំះ បាត់នាងទេវីទៅណាស្រេច !

យើងនាំគ្នាក្រឡេកក្រឡាប់ភ្នែករកមើលនាង ស្រាប់តែឮសម្លេងនាង យ៉ាងស្រួយស្រេះ មកពីខាងលើកំពូលមួយនោះមក :

- មកខាងលើឯណោះ ក្បាច់ចម្លាក់ល្អណាស់ ហើយមើលឃើញបាន សព្វគ្រប់ផង !

សុវណ្ណនឹងខ្ញុំនាំគ្នាឡើងតាមទៅ ។ ខ្ញុំនឹងថា ទេវីនាងដឹងថ្នាក់ថ្មមសព្វ ទាំងអស់ នាងពិតជាធ្លាប់បានមកឡើងជាញឹកញាប់ហើយ ។

ពេលនោះ កាំរស្មីនៃព្រះអាទិត្យចាំងធ្លុះសុសសាយមុខព្រហ្មទាំង ឡាយ ហាក់រីតតែញញឹមខ្លាំងឡើង ។ ទិដ្ឋភាពនោះបានច្រានភវង្គចិត្តឱ្យរសាត់ អណ្តែតអណ្តូងលន្លង់លន្លោច . . . មើលយូរទៅដូចស្រមៃឃើញ មេជាងដ៏ ជំនាញកំពុងតែឆ្លាក់រូបទាំងនោះដោយផ្ចិតផ្ចង់ ឃើញព្រះរាជាដ៏មានរិទ្ធព្រះអង្គ កំពុងប្រារព្ធក្បួនទ័ព ឃើញវង់ភ្លេងលេងប្រគំរងំល្វើយ . . . ឱ ! អ្នករស់នៅ កាលជំនាន់នោះបាន ហ៊ឹកហ៉ាក់យ៉ាងណាទៅហ្ន៎ ! មើលទៅអាកាសស្រឡះល្វឹង សត្វខ្លែង សន្ទឹងស្លាបហើរវិលវង់ទៅវិញទៅមកចោលសម្លេងចាក. . .យ៉ាង គ្រលួច ! ថ្ងៃក្តៅខ្លាំង ហើយបាយ័ននឹងខ្លួនខ្ញុំ ហាក់លូតដកកំពស់ទៅកាន់លំហ មេឃទទួលកំដៅ ។ ខ្ញុំសួរទៅមិត្តថា :

- សុវណ្ណ ប្រាសាទបាយ័ននេះខ្ពស់ជាងគេឬ ?

- ទេ ខ្ពស់ជាងគេនោះ គឺប្រាសាទភ្នំបាខែង ឯណោះទេដែលយើងមក ហួសមិនចូលនោះឯង ។

ហ្ន៎, នៅខាងត្បូង ដែលយើងមើលទៅឃើញខ្ពស់ទទុងនោះ គឺប្រា សាទនោះហើយ ។ បើយើងនៅពីលើប្រាសាទនោះ យើងអាចមើលឃើញទីង ទៀតបាន ដូចជាឃើញអង្គរតូច ឃើញបារាយទឹកថ្លា ឃើញទៅទៀត រហូត ដល់ភ្នំ គូលែន ភ្នំបូក នឹងជួរភ្នំដងរែក. . . ។ ឯប្រាសាទបាយ័នដែលយើងឈរ នេះ ក៏ខ្ពស់ដែរ តែវាកំបាំងនឹងព្រៃក្បែរខាង រកមើលទៅទីផ្សេងៗមិនឃើញ ។

សុវណ្ណនិយាយ ព្រមទាំងចង្អុលទៅព្រៃដែលនៅក្បែរនោះផង ។ រួច គេបែរមកមើលមុខនាងក្រមុំ ហើយញញឹមសួរ :

- ម៉េចអ្នកវី មិនក្តៅទេឬ ?

- ចាស ក្តៅណាស់លោកសុវណ្ណ ។

- បើអីចឹង យើងគិតចុះទៅវិញឬ ? ប្រហែលជាវង្សគេចាំយើងជាន់ ខាងក្រោមឯណោះហើយ ។

- ចាស ចុះក៏ចុះ ។ ហើយយើងគិតទៅសុំទឹកអណ្តូង ដែលនៅខាង ក្រោមនោះលុបមុខមាត់បន្តិច ខ្ញុំឮគេថា ទឹកអណ្តូងនោះលុបមុខទៅកាលណា មានសិរីសួស្តី ខ្ញុំធ្លាប់មកលុបម្តងពីរដែរ ។

នាងទេវី មានទឹកមុខក្រហមបន្តិចហើយ ឯថ្ពាសនោះមានដំណក់ ញើសល្អិតៗផង ។ នាងនាំចុះទៅក្រោមមុនគេ ឯសុវណ្ណហើយនឹងខ្ញុំក៏តាមនាង ។ នៅខាងណេះ នៅខាងណោះ ខ្ញុំឃើញជនខ្លះឈរ ពិនិត្យរូបចម្លាក់ ខ្លះលើក ប្រដាប់ថតរូបផ្ទៀងទៅរកភាពនេះម្តង នោះម្តង ។

យើងទាំងបីរូប បានមកដល់ទីមួយដែលមានសណ្ឋានជាឃ្លុប ។ ក្បែរ នោះ តាចាស់ម្នាក់មាឌស្គមសម្បុរខ្មៅនៅដៃ មានកាន់អំបោសមួយផង គឺ ប្រហែលគាត់ជាអ្នកបោសច្រាសកន្លែងនេះ ។ ហើយនៅជិតនោះមានកូនយោង មួយ ដែលមានទឹកសើមនៅឡើយ នាំឱ្យយល់ថា គាត់ទើបតែនឹងបានដងទឹក មុននឹងយើងមកដល់នេះទេ ។ ដូច្នោះ ខ្ញុំដឹងភ្លាមថា តានេះជាអ្នកដងទឹក អណ្តូង ដែលនាងទេវីនិយាយនោះហើយ ។ ប្រាកដមែន កាលបើឃើញយើង ទៅដល់ គាត់ក៏រប៉ាសដោះឆ្នូតក្បាលគួរសមមករក :

- លោកប្រុស លោកស្រីអញ្ជើញលុបមុខឬ ? ខ្ញុំដងជូន ។ នៅក្បែរ នេះជាអណ្តូងប្រេង ។ អណ្តូងនេះមិនចេះរីងទេ តាំងពីដូនតា តាតួត លួតលា ណាមកម្ល៉េះ ព្រោះទឹកនេះជាទឹករបស់ទេវតា ។ លោកប្រុស លោកស្រីលុបមុខ មាត់ទៅកាលណានឹងមានសិរីសួស្តី ហើយបាទ !

ចំពោះពាក្យនេះ តានោះហាក់ដូចជា និយាយមកកាន់ខ្ញុំ និង ទេវី ព្រោះសុវណ្ណនៅឆ្ងាយបន្តិចពីយើង ។ គាត់ពោលពាក្យនេះ ដោយញញឹមផង់រំផង ជាកិច្ចបញ្ចុះបញ្ចូល ។ ឯសុវណ្ណក៏និយាយមកដែរថា :

- អញ្ជើញលោកប្រុស លោកស្រី លុបមុខ លុបមាត់ តាមគាត់ទៅ ។

នាងទេវី ប្រហែលជានឹកអៀនខ្លាំងណាស់ហើយ នាងឡើងមុខ ក្រហម និយាយទៅកាន់សុវណ្ណវិញ :

- ដឹងជាស្អីទេ លោកសុវណ្ណឯង ចេះនិយាយច្រើនណាស់ ខ្ញុំស្អប់ ណាស់. . .

ហើយនាងបែរមើលមុខខ្ញុំបន្តិច ទើបមើលទៅទីផ្សេង ។ ចំណែកតា នោះវិញ គាត់ក៏កាន់យោងដើរឆ្វេងទៅតាមជញ្ជាំងម្ខាង ។ នាង និងខ្ញុំទើប តាមគាត់ទៅ ។ សុវណ្ណធ្វើមុខញឹម១ឈរចាំងក្រៅ ។

នៅក្នុងទីងងឹត តានោះគាត់គុសដែកភ្លើងឡើងអុជទៀនមួយ នាំឱ្យ មើលឃើញរនាំងឃាំងកន្លែងមួយនោះ ដែលគាត់ចង្អុលបង្ហាញប្រាប់យើងថា : នេះជាអណ្តូងប្រេង ! ខ្ញុំនិងទេវីឈរច្រត់ រនាំងនេះសម្លឹងមើលទៅក្រោម ។ ខ្ញុំ មើលពុំដល់ទឹកនៅបាតអណ្តូង នោះទេ ងងឹតណាស់ ។ តានោះ ទម្លាក់យោងទៅ ក្នុងដោយបន្លាយខ្សែប្រហែលជា ៣ ម៉ែត្រ ទើបទាញមកវិញ ។ ដោយពន្លឺ ទៀន ខ្ញុំឃើញ ទឹកភ្លឺព្រាត១ក្នុងយោង ។ តានោះនិយាយមកកាន់យើងថា : ទឹកអណ្តូងនេះជ្រៅណាស់ ជ្រៅដល់បាតទន្លេសាប បើកាលណាយើងទម្លាក់ដូង ទុំមួយក្នុងអណ្តូងនេះ យើងនឹងឃើញដូងនោះឯងអណ្តែតនៅឯទន្លេសាបឯ ណោះ ។

ទេវីយកដៃឱបទ្រូង មើលមុខខ្ញុំ ហើយបែរទៅនិយាយនឹងតានោះ :

- លោកតា ខ្ញុំឮតែគេថាយ៉ាងហ្នឹងដែរ តែគ្មានដែលនរណាសាក ទម្លាក់ដូងពីនេះ ហើយទៅចាំមើលនៅឯទន្លេសាបនោះសោះ ។ ប៉ុន្តែយ៉ាងណា ក៏ដោយ ខ្ញុំឮចាស់១ថា ទឹកអណ្តូងនេះសក្តិសិទ្ធិណាស់ បើអីចឹងហើយសូមឱ្យខ្ញុំ លុបមុខ លុបមាត់ទៅកាលណា មានសិរីសួស្តីដូចប្រាថ្នាណាតា ។

- បាទ ! តាដែលនៅថែរក្សាទឹកនេះ ក៏សូមឱ្យចៅប្រុស ចៅស្រីទាំង ពីរនាក់ លុបទៅកាលណា មានសិរីសួស្តីត្រជាក់ត្រជុំសុខសប្បាយទៅណា . . . ។

ហើយគាត់ហុចទឹកនោះមកឱ្យខ្ញុំ ។ ខ្ញុំពេលនេះព្រឺអស់ទាំងរោមព្រោះ នឹកសម្មើមនឹងពាក្យឱ្យពររបស់គាត់នេះ ។ លោកតានេះគាត់ពិតជានឹកថា ខ្ញុំ និងទេវីជាប្តីប្រពន្ធ ទើបគាត់មិនញញើតនឹងហៅយ៉ាងនេះ ។ ខ្ញុំនឹកខ្លាចណាស់ គិតឃើញថា នាងទេវីប្រាកដជាអៀនហើយ ហើយនាងគង់អន់ចិត្តនឹងខ្ញុំមិនតិច ទេ ព្រោះតែលោកតានេះគាត់យល់ច្រឡំខ្ញុំថាជាប្តីនាងដូច្នេះ ។ ប៉ុន្តែនឹងធ្វើម៉េច បើការនេះ វារំលងមកអីចេះទៅហើយនោះ ។ ខ្ញុំលើកយោងនោះ ជូនទៅនាង ដោយឥតស្រដី ។ ឯនាងក៏ទទួលយកទៅលុបមុខ ក្បិតសក់ រួចហើយ នាងហុច មកខ្ញុំវិញ ។ ខ្ញុំសម្រិតទឹកដែលនៅក្នុងនោះ មកលុបលាងមុខដូចនាងដែរ តែពុំ ដឹងជាអធិដ្ឋានដូចម្តេចទេ ចេះតែលុប១ទៅ ។ ខ្ញុំគ្រាន់តែគត់សំគាល់បានថា ទឹក នោះថ្លាណាស់ ហើយត្រជាក់ណាស់ផង ។ ខ្ញុំពុំក្រេបរសជាតិឱ្យដឹងសាបប្រៃទេ ក្រែងចាញ់ ។ ខ្ញុំជូនយោងនោះទៅតារក្សាទឹកនោះវិញ ព្រមគ្នានឹងពេលដែល នាង ទេវីលូកលុយ ១០ រៀលជូនទៅគាត់ដែរ ។

- សូមជូនលោកតា ១០ រៀល ចាស !

- បាទ តាសូមអរគុណចៅប្រុសចៅស្រីហើយ ហើយតាសូមជូនពរ ដល់ចៅទាំងពីរឱ្យបានសុខចំរើនជាអង្វែងតទៅ ។ ប្រាក់ចៅនេះតាគ្រាន់បាន ធ្វើបុណ្យទាននឹងគេចៅ ។

- ចាស ! ខ្ញុំសូមជំរាបលាលោកតាសិនហើយចាស

- អញ្ជើញចុះចៅ

ខ្ញុំក៏សិតសក់ឱ្យមានរបៀបរៀបរយ ហើយប្រញាប់ជំរាបលាគាត់ ចេញតាមនាងដែរ ។ នៅខាងក្រៅនោះខ្ញុំឃើញវង្ស និងវណ្ណព្រមទាំងទេវី កំពុងនិយាយគ្នា ។ ខ្ញុំទៅដល់វង្សសើចសួរឡើង :

- ម៉េចសប្បាយទេមិត្ត ?

- បាទ សប្បាយណាស់ ខ្ញុំពុំដែលឃើញវត្ថុអស្ចារ្យយ៉ាងនេះទេមិត្ត ។

នាងទេវីចាប់បន្តឡើង :

- ហើយអម្បាញ់មិញ ខ្ញុំនាំគ្នាទៅលុបមុខនៅអណ្តូងប្រេងនោះ ។

- ហឺ ! គួរហើយទៅជឿទឹកនោះ (វង្សសើចចំអកឱ្យប្អូន) នាំគ្នាទៅ មើលក្បាច់ចម្លែក១មិនគិតទេ ទៅគិតឯរឿងគ្មានប្រយោជន៍ទៅវិញ ។

- ហ៎ ! តាំងលែងជឿចាស់បូរាណទៀតហើយបងវង្សឯង ។

- ហ្អឹងឯង ជឿតែម្នាក់ឯងទៅចុះទឹកអណ្តូងអីគេនោះ ។

- បើមិនជឿអីម្តេចបាន បើខ្ញុំឮចាស់១ថាពូកែមែន ហើយលោកគ្រូ សំអនសាស្ត្រាចារ្យប្រវត្តិសាស្ត្រខ្ញុំក៏គាត់ថាដែរ ថាកន្លែងនោះជាកន្លែងបុរាណ ដែលកាលមុននោះគេជឿសំបើមណាស់ ។

សុវណ្ណបែបទ្រាន់យ៉ាងណាក៏កាត់សំដីឡើង ។

- ណ្ហើយ ! ខ្ជិលជជែកជាមួយអ្នកវី ទៅយើងគិតទៅណាទៀត ។ ថ្ងៃកាន់តែក្តៅណាស់ហើយ ។

ទេវីសម្លក់សុវណ្ណទ្រង់ខឹង បុរសនេះធ្វើព្រងើយ ហើយនាំមុខចុះទៅ ក្រោម ។ ខ្ញុំដើរក្រោយគេបង្អស់ ។ ដល់រថយន្តហើយ ខ្ញុំចាប់សួរសុវណ្ណ និង វង្ស :

- យើងគិតទៅណាមុនមិត្ត ?

វង្សឆ្លើយ :

- ទៅខាងណាមុនក៏បានដែរ ។ ចេញទៅជើងក៏បាន ចេញទៅតាមផ្លូវ ដែលនៅចំពីខាងកើតយើងនេះក៏បាន (វង្សចង្អុលទៅផ្លូវដែលបត់កុងទៅកើត ប្រាសាទ) ផ្លូវនេះត្រូវចេញតាមទ្វារមួយហៅថា ទ្វារខ្មោច ។ នៅខាងជើង ទន្ទឹមនឹងទ្វារខ្មោចនេះមានទ្វារមួយទៀតហៅថា ទ្វារជ័យ ។ ទ្វារជ័យនាំយើង ឱ្យចេញទៅតាមផ្លូវវង់តូច ។ ទ្វារជ័យនិងទ្វារខ្មោចនេះ ជាទិសសម្រាប់ចេញចូល ពីខាងកើតនៃអង្គរធំ ។ ហើយក្បាច់ក្លោងទ្វារនឹងរូបទេពតាទាញនាគអី១ដូចគ្នា នឹងក្លោងទ្វារដែលយើងចូលពីខាងត្បូងអម្បាញ់មិញនេះដែរ ។ រីឯផ្លូវទៅជើងវិញក៏ដូច្នោះដែរ គឺមានក្លោងទ្វារដូចផ្លូវនៅនាខាងត្បូង នឹងផ្លូវទ្វារខ្មោចទ្វារជ័យ ដែរ ។ យ៉ាងដូច្នេះបើមិត្តមិនដឹងទេ នឹងច្រឡំថាជាផ្លូវតែមួយដដែល១មិន លែង ។ យី ! ខ្ញុំស្តាយណាស់ ភ្លេចយកផែនទីមកតាម បើមានផែនទីងាយយល់ ណាស់ ។

សុវណ្ណចាប់និយាយបន្ថែម :

- ខ្ញុំភ្លេចទៅ ! នៅបណ្ណាគារឯផ្សារ មានកូនសៀវភៅនិយាយពីរឿង អង្គរនេះដែរ ហើយក្នុងនោះមានផែនទីផង ។ បើទិញសៀវភៅនោះមកមានអី !

ណ្ហើយ ខ្ជិលនិយាយ សៀវភៅនៅផ្សារឯណោះត្រដរនាំមកអួតដែរ ខ្ញុំជិនណាស់លោកវណ្ណឯង !

នាងទេវីនិយាយទ្រង់ផ្ចង់ឱ្យសុវណ្ណ ។ សុវណ្ណសើចហឹះ១ រួចនិយាយ ថា :

- ណ្ហើយ ខ្ញុំឈប់និយាយហើយ បើអីចឹងយើងគិតទៅណាទៀតអ្នកវី

- យើងទៅទិសខាងជើង ដើម្បីមើលចាប់ពីប្រាសាទបាពួនតទៅ ហើយចេញទៅវង់ធំមើលចាប់ពីព្រះខ័នរហូតមកចូលវង់តូចវិញ គឺចូលត្រង់ចៅ សាយនិង ធម្មានន្ទហើយបត់មកទីនេះវិញ ។

- អីចឹង ក៏ស្រួលម្យ៉ាងដែរ ចំណាយពេលមួយថ្ងៃនេះជូនដំណើរ ចរណៃទស្សនាឱ្យអស់តែម្តង ។ ប៉ុន្តែថាក្រែងមើលពុំបានសព្វគ្រប់ទេឬ ? វង្ស ។

សុវណ្ណងាកទៅសួរអ្នកកាន់ចង្កូត ដែលបញ្ឆេះរថយន្តជាស្រេច បុរស នេះឆ្លើយដោយរីករាយមកខ្ញុំ :

- យើងគ្រាន់តែបានឃើញ ហើយរំលងមិនបាច់ឡើងខ្លះទៅ ក៏មិនជា អ្វីដែរ ។ ដូចជាប្រាសាទបាពួន វិមានអាកាស ទេពប្រណម្យអី១ យើងគ្រាន់តែ ឃើញសិនទៅបានហើយ ពេលណាទំនេរស្រួល សឹមឡើងមើលឱ្យសព្វគ្រប់មែន ទេមិត្ត ?

- បាទ ខ្ញុំស្រេចតែមិត្តទេ ខ្ញុំមិនដឹងទិសតំបន់ណាទេ ។

ខ្ញុំឆ្លើយទៅកាន់វង្សដូច្នេះ សុវណ្ណសើចឡើង :

- បានតែយកចរណៃទៅ ប្រោសចោលឯបន្ទាយស្រីនោះទេ ។

ខ្ញុំសួរទៅវិញ :

- នៅឯណាទៅបន្ទាយស្រីនោះ ?

នាងទេវីឆ្លើយភ្លាម :

- នៅផ្លូវទៅប្រដាកឯណោះ ចម្ងាយពីនេះប្រហែលជា ២០ គីឡូ ។ ខ្ញុំមិនដែលទៅទេ ឮតែគេថាប្រាសាទនោះ នៅដាច់តែឯង កណ្ដាលទ្រូងព្រៃ ។

- ឱ អីចឹងអីអេះបានជាសុវណ្ណគេថា យកខ្ញុំទៅប្រោសចោល ណ្ហើយ សុវណ្ណអើយ មិនបាច់ទៅណាឆ្ងាយទេនៅតែទីនេះ ក៏ដូចជាវង្វេងទិសអស់ទៅ ហើយដែរ ។

សើចព្រមគ្នាឡើង ។ រួចសុវណ្ណមើលទៅទីមួយនោះដែលមានមនុស្ស គ្រេបគ្រាទើបឃាត់ថា :

- នែ ! វង្សលត់ម៉ាស៊ីនសិនទៅយើងទៅរកស៊ីផឹកសិន គ្នាដូចជារមួល ពោះហើយវ៉ឺយ ។ ហើយ នំ. ឯងឃើញទេ នៅចាំយើងឱ្យរហង់ឯណោះ គ្នាមិន ដាច់ចិត្តទៅចោលទីនោះទេវ៉ឺយ គ្នាធ្លាប់ផឹកស៊ីនៅនោះមានរសជាតិណាស់ ហើយស្រី១អស់នោះក៏ចេះគួរសមណាស់ផង ។

- ទៅក៏ទៅ គ្នាបែបឃ្លានណាស់ដែរ ម៉ោង ១២ ថ្ងៃត្រង់ទៅហើយ ។

វង្ស និងសុវណ្ណ នាំអាទិទៅមួយរំពេច ខ្ញុំញឹម១តាមគេទៅដែរ ខ្ញុំឮ នាងទេវីរអ៊ូថា :

- នៅផ្ទះផឹកស៊ីមិនសូវឆ្ងាញ់ទេ គ្មាននរណាវាម៉ិកម៉ូក់ ។ នៅឯណោះ ចេះតែឆ្ងាញ់ទាំងអស់ ។

- វង្ស និងសុវណ្ណ មិនរវល់នឹងពុំនោលរបស់នាងទេវីទេ ដើរធ្វើ ព្រងើយ ។

ជាមួយនឹងជនខ្មែរ និងបរទេសជាច្រើន ដែលខ្ញុំដឹងថា ទាំងអស់គ្នា នោះសុទ្ធតែជាជនទេសចរ យើងបាននាំគ្នាចូលទៅកាន់ភោជនីយដ្ឋានមួយ ។ ភោជនីយដ្ឋាននេះតាំងនៅកណ្ដាលវាលតែម្ដង ។ អង្គុយពីនេះ ខ្ញុំមើលឃើញ ប្រាសាទនៅជ្រងោតតកំបាំងនឹងអ្វីទេ ។ ពេលនោះអ្នកបំរើស្រី១ រូបរាងស្អាត បាត ។ ស្លៀកពាក់តាមទំនើបនៅដៃ មានកូនកន្សែងមួយផងមឹម្នាមកគួរសម នឹងយើង ។

- លោកអញ្ជើញពិសាអី ចាស ?

វង្សមិនឆ្លើយទេ ងាកមកសួរសុវណ្ណ :

- ស៊្ហីយើង ប្រាប់ទៅ ?

- ឱ្យយកប៊ីយែរអាមេរិកមក !

វង្សងាកសួរខ្ញុំ :

មិត្តខាងណេះចូលចិត្តដែរ ឬ ?

សុវណ្ណរហ័សកាត់ភ្លាម :

មិនបានទេ ដាច់សីលគេ យកទឹកក្រូចមកបានហើយ គេអាចារ្យណ៎ា ឯងមិនទាន់ដឹងទេ ។

ពេលនេះ នាងទេវីសម្លឹងមុខសុវណ្ណទ្រង់ក្នាញ់ជំនួសខ្ញុំ តែសុវណ្ណ ធ្វើ ព្រងើយនិយាយថា :

- ឯអ្នកទេវីក៏ប្រហែលជាទឹកក្រូចដែរហើយ យ៉ាងមើល ?

- ហ្នឹងឯង ខ្ញុំមិនចេះអាគ្រឿងស្រវឹងដូចលោកសុវណ្ណឯងទេ ពិសាតែ ម្នាក់ឯងចុះ ។

សុវណ្ណ និងវង្សមើលមុខគ្នាហើយសើចឡើង ។ នាងទេវី និងខ្ញុំ គ្រាន់ តែញញឹម១ ។

វង្សបង្គាប់ឱ្យធ្វើម្ហូបមក ។ វង្សប្រាប់ឱ្យយកមាន់អាំង បន្ថែមលើសម្ល ម្ជូរម្នាស់ ។ ខ្ញុំនឹកឆ្ងល់ណាស់ : អ្នកសៀមរាបម៉េចក៏ចូលចិត្ត សម្លម្ជូរម្ល៉េះ ។ អា ហារមកដល់យើងនាំគ្នាបរិភោគដោយក្តីរីករាយ ។

ខ្ញុំនឹកសរសើរវាសនាខ្លួនឯងយ៉ាងខ្លាំង ត្បិតថាសេចក្តីសប្បាយរបស់ខ្ញុំ វាលើសពីគំនិតផ្តងមុនរបស់ខ្ញុំនោះឆ្ងាយណាស់ ។ កាលនៅភ្នំពេញគ្រាន់តែគិត ថា ដំណើរមកលេងសៀមរាបនេះ ខ្ញុំនឹងសប្បាយតែទៅលើភាពចំឡែកនៃក្រុង ថ្មី និងអង្គរវត្ត ដែលខ្ញុំមិនធ្លាប់ស្គាល់ប៉ុណ្ណោះទេ ។ ឥឡូវនេះវាសនានេះ លាត សន្ធឹងរហូតដល់ទៅមានគេទទួលស្គាល់យ៉ាងបវរភាព ។ អ្នកសៀមរាបនេះ ដូចជាគ្រួសាររបស់ខ្ញុំទៅហើយ ។ ពេលបរិភោគនោះ យើងជជែកគ្នាពីនេះពី នោះគ្មានដាច់។ ប៉ុន្តែខ្ញុំពុំសូវនិយាយច្រើនទេ ឯសុវណ្ណវិញនិយាយគ្មានឈប់ ហើយច្រើនតែធ្វើឱ្យនាងទេវីប្រឆាំងផង ។ លុះលែងបរិភោគហើយ វង្សហៅ អ្នកបំរើមកគិតលុយ ទើបនាំគ្នាចេញមកវិញដើរមករករថយន្ត។ យើងរាល់គ្នា នៅក្នុងឡាន ។ ខ្ញុំមិនភ្លេចនឹងសង្កេតសភាពអ៊ូអរនៅទីនោះឡើយ ។ តាមថ្នល់ រថយន រ៉ឺម៉ក និងមនុស្សបើកបរ និងដើរទៅវិញទៅមក ។ សុទ្ធតែជាអ្នក ដំណើរដូចខ្ញុំ ហើយអ្នកដំណើរខ្លះងើយស្ញើនមើលទៅប្រាសាទ ខ្លះនិយាយ ដោយចង្អុលបង្ហាញគ្នីគ្នា នូវរូបភាពខាងណេះខាងណោះ ខ្លះឱ្យគ្រួសារឈរ តម្រៀបគ្នាបែរខ្នង ទៅរកប្រាសាទ ហើយក៏លើកបរិធានថតរូបដាក់ផ្ដងឡើង ដើម្បីថត ។

- រាល់ថ្ងៃប្រហែលជាអ៊ូអរយ៉ាងនេះហើយ ។ ខ្ញុំនិយាយទៅកាន់ សុវណ្ណ ។

- មិនសូវជាអ៊ូអរទេ អ្នកទេសចរមានដែរ តែមានមិនច្រើនដូចប៉ុន្មាន ថ្ងៃនេះ ។ ប៉ុន្តែថ្ងៃនេះមនុស្សច្រើនព្រោះមានអ្នកខេត្តឯទៀត១ ដែលគេមិន ធ្លាប់ស្គាល់អង្គរ ឬក៏ធ្លាប់ស្គាល់ដែរ តែចង់មកមើលទៀតនោះគេក៏នាំគ្នាទាំង គ្រួសារ១មកលេង ម្យ៉ាងទៀតត្រូវពេលនឹងឈប់សម្រាកបុណ្យចូលឆ្នាំយើង ផងនោះ ក៏អ្នកទាំងនោះបានឱកាសនឹងមកលេងដោយស្រួលទៅ ។

- អ្នកសៀមរាបគេមិនសូវរវល់និងដើរលេងទេយ៉ាងមើល ?

- ម៉េចក៏ថាមិនសូវរវល់ ។ ដូចយ៉ាងរូបគ្នានេះអី បានថ្ងៃនេះហើយ ដែលនឹងបានឃើញមុខក្រមុំប្លែក១មកពីខេត្តនានា ។ គេមើលក្រមុំស្រុកឯង ឯងមើលក្រមុំស្រុកគេ មើលទៅមើលមកសប្បាយភ្នែក គឺក្នុងប៉ុន្មានថ្ងៃនេះឯង ។

សុវណ្ណនិយាយទាំងសើចមើលមុខនាងទេវី ដែលទ្រង់ខ្មាសឡើងក្រហម ។

កំពុងសន្ទនានោះ ខ្ញុំក៏ឃើញក្លោងទ្វារមួយទៀតដូចក្លោងទ្វារដែលខ្ញុំ ឃើញកាលពីចូលមក ។ ខ្ញុំចំណាំក្នុងចិត្តថា នេះក្លោងទ្វារដែលខ្ញុំឃើញកាលពី ចូលមក ។ ខ្ញុំចំណាំក្នុងចិត្តថា នេះក្លោងទ្វារខាងជើង ព្រោះវង្ស និងទេវីបាន ពន្យល់មកហើយ ។ ផុតពីនោះមកក៏ដល់ទីមួយទៀត ។ វង្សបញ្ឈប់រថយន្ត ហើយបង្គាប់ថា :

- ដល់ប្រាសាទព្រះខ័នហើយ ចូលមើលពីខាងលិចនេះទៅ ចុះខ្ញុំទៅ ចាំឯកើតមុន ។

លោកវណ្ណឯង នាំលោកខាងណេះចូលទៅមើលចុះ ខ្ញុំដូចជាក្តៅណាស់ ខ្ញុំចាំកើតមុនជាមួយបងវង្ស ។

- បាទ អញ្ជើញ !

នាងទេវីឡើងទៅអង្គុយទន្ទឹមវង្សហើយឡានបរចេញទៅ ។

ខ្ញុំត្រូវសុវណ្ណនាំចូលទៅមើលប្រាសាទ ដែលគេហៅថាព្រះខ័ននោះ ខ្ញុំ ចាប់ភ្នែកឥតឧបមាចំពោះរូបមនុស្សដែលធំធាត់យ៉ាងសំបើម ឈរជាជួរអមផ្លូវ ។ ខ្ញុំនឹកឃើញថា មនុស្សជំនាន់នោះប្រហែលជាធំមាំមួនដូច្នេះហើយ ។ រូបទាំង នេះគឺជាអ្នកក្លាហាន ខ្លាំងពូកែ ឬក៏ជាអ្នកកីឡាយ៉ាងចំណាប់ ។

ក៏មិនអន់ថយជាងប្រាសាទដែលខ្ញុំបានមើលមកហើយនោះដែរ ប្រាសាទថ្មីនេះ ពោរពេញដោយចំឡាក់គ្រប់សសរ គ្រប់ជញ្ជាំងទាំងអស់ ។ មើលយូរទៅលង់ស្មារតី ស្រមៃដល់រឿងព្រេងអារ៉ាប់ ឈ្មោះមួយពាន់មួយយប់ ដែលមានមួយកណ្ឌនោះនិយាយអំពីលំអប្រាសាទដ៏អស្ចារ្យមានរូបមនុស្សក្លាយ ជាថ្មគ្រប់ទីវាំងទាំងមូល ។ ឯរូបមនុស្សដែលឈរយាមទ្វារដ៏មានមាឌមាំ សម្បើមនេះ ក៏ដូចជាមនុស្សដែលគេនិទាននោះណាស់ សោតឯ និងសុវណ្ណក៏ដូច ជាអ្នកដើរតួក្នុងរឿងនោះដែរ យើងគឺជាអ្នកទៅឃើញប្រាសាទដ៏អស្ចារ្យ ។

ប៉ុន្តែសេចក្ដីស្រមៃនេះលយលង់គំនិតពុំសូវបានយូរទេ ព្រោះមិនមែនតែយើង ពីរនាក់ឯណា មានបណ្ដាជនឯទៀត គេដើរចេញចូលមើលក្នុងទីនេះដែរ ។ តាម សង្កេតទៅ គេទាំងនោះខ្លះជាប្ដីប្រពន្ធ ខ្លះជាគ្រួសារ មានក្មេងមានចាស់ ហើយ ខ្ញុំឃើញព្រះសង្ឃផង ។ ព្រះសង្ឃមួយអង្គនោះលោកនិមន្តមើលដោយសង្កេត ជាមួយតាចាស់ម្នាក់ នូវរូបចម្លាក់គ្រុឌនៅល្វែងមួយ ។ បរិយាកាសពេលនោះ ក្ដៅហប់ ។ ខ្ញុំនិងសុវណ្ណនាំគ្នាឈប់សម្រាកត្រង់ល្វែងមួយនៃប្រាសាទ ដែល មានជញ្ជាំងប្រកបដោយបង្អួចសសរក្បាច់ ។ នៅក្បែរជញ្ជាំងនោះមនុស្សអ្នកមើលរមែងដើរទៅវិញទៅមក ។ យើងអង្គុយផ្អែកនឹងជញ្ជាំងនោះសម្រាកបន្តិច ។ តាមចន្លោះទ្វារខ្ញុំមើលឃើញកំពូលបាក់បែកនៃប្រាសាទនានាដែលនៅ ក្នុងបរិវេណនោះ ។ យូរក្រោយមក ខ្ញុំតឿនមិត្តឱ្យដើរទៅមុខទៀតតែគេថា : ចាំបន្តិចទៀតសិន ។ បន្តិចមកទៀត ខ្ញុំតឿនទៀតក្រែងវង្ស និងទេវីចាំយូរ ។ ម្ដងណេះសុវណ្ណឃាត់ថា : ឈប់សិន ! ហើយងាកមើលនាយអាយ ។ យល់ថា ស្ងាត់គ្មានមនុស្សនៅជិតក៏និយាយឡើងថា :

- ឈប់សិនចរណៃ ! គ្នាចង់និយាយរឿងដដែលឡើងវិញជាមួយឯង ។

ខ្ញុំទើបដូចជាភ្ញាក់អារម្មណ៍ នឹងសំដីរបស់មិត្តខ្ញុំនេះមិនតិច ។ ខ្ញុំមើល មុខមិត្តនេះដោយសង្កេតទឹកមុខគេបែបស្មើ មិនញញឹមលេងសើចដូចមុនទេ ស ឱ្យឃើញថា គេយកចិត្តទុកដាក់នឹងរឿងខ្ញុំយ៉ាងខ្ជាប់ខ្ជួនមែនៗ ។ ខ្ញុំមិនតបទេ នៅអង្គុយទៅទៀត សុវណ្ណមិត្តខ្ញុំ ចាប់បន្ត :

- ចរណៃ ! គ្នានិយាយម្ដងលេងម្ដងមែន ។ តែឥឡូវ គ្នាសូមប្រាប់ ឯងឱ្យត្រង់ថា : គ្នាចង់ឱ្យឯងដណ្ដឹងនាងទេវីណាស់ ។

ខ្ញុំមិននិយាយអ្វីទេ ដោយចង់ឱ្យសុវណ្ណគេបង្ហាញលក្ខណចិត្តគេពេល នេះ ។ សុវណមើលមុខខ្ញុំបន្ត :

- ចរណៃ ! ឯងគង់ឆ្ងល់ថា ហេតុម្ដេចក៏គ្នាចង់ឱ្យឯងបាននាងទេវីខ្លាំង ម្ល៉េះ ហើយម៉េចក៏គ្នាមិនឱ្យខ្លួនគ្នាទៅវិញ បើថានាងល្អនោះ ។ ត្រង់ណេះគ្នា សូមឆ្លើយថា ម្ដាយឪពុកគ្នាគាត់មិនគិតឱ្យគ្នាទេ ហើយតាមស្មាននាងទេវី គង់ មិនទទួលគ្នាជាប្ដីដែរ ថានាងមិនពេញចិត្ត នឹងគ្នាក៏ថាបាន ព្រោះគ្នាវាមានកិរិយា មិនសមរម្យល្មមឱ្យនាងស្រឡាញ់ ។ ឯរូបគ្នាវិញក៏ឥតប្រាថ្នានាងដែរ ត្បិតវា ទើសទាល់នឹង វង្ស ដែលជាមិត្តស្និទ្ធស្នាលពីក្មេងមក ម្យ៉ាងទៀតបងប្រុសរបស់ វង្ស គាត់យកបងស្រីរបស់គ្នា យើងជាសាច់ថ្លៃ គួរតែនៅជាសាច់ថ្លៃអីចឹងទៅវា ល្អជាង ។

- ចុះបានប្រយោជន៍អ្វីនឹងរឿងគ្នានេះ បានសុវណ្ណឯងខំគិតសំបើម ម្ល៉េះ ។ ខ្ញុំសួរដោយសុភាពទំនងយកចិត្តមិត្តនេះ ដែលគេឆ្លើយយ៉ាងច្បាស់ លាស់ថា :

- សូមចរណៃឯងជឿគ្នាចុះ គ្នាស្បថជូន គ្នាប្រាថ្នាឱ្យនាងបានជារបស់ ចរណៃឯងគឺមកពី : ទី១ គ្នាស្រឡាញ់ឯងដូចជាបងប្អូនបង្កើត នាងទេវីដែល មានរូបសក្ដិសមនឹងឯងណាស់នោះ នាងគួរតែបានឯង ។ ទី២ បើឯងបាននាង ទៅគ្រួសារឯងនិងគ្រួសារគ្នាក៏កាន់តែរាប់អានគ្នាខ្លាំងឡើង ។ គ្មានអ្វីជាអាថ៌ កំបាំងក្នុងរឿងនេះទេ សូមមិត្តជ្រាបចុះ ។

ខ្ញុំយល់ចិត្តសុវណ្ណហើយ សុវណ្ណពិតជាចង់ឱ្យខ្ញុំ និងទេវីបានគ្នា ជាប្ដី ប្រពន្ធមែន ។ តាំងពីដើមមកសុវណ្ណជាអ្នកនិយាយលេងសើចច្រើនមែន តែ សុវណ្ណមិនដែលនាំខ្ញុំខកខូចកិត្តិយសពីរឿងអ្វីឡើយ ។ ម្ដងនេះសុវណ្ណរឹតតែធ្វើ ឱ្យខ្ញុំស្រឡាញ់ទ្វេឡើង ដោយសារគេខំក្នុងរឿងជីវិតខ្ញុំនេះ ។ ដោយសារមិត្ត ស្រឡាញ់ នាងទេវីយ៉ាងធំធេងមកស្រាប់ ហើយពេលនេះសេចក្ដីខ្មាសអៀន របស់ខ្ញុំចំពោះសុវណ្ណក៏ដូចជារលាយទៅឯងៗ ម្យ៉ាងដោយនឹកថា សុវណ្ណ មិន អាចយករឿងនេះទៅនិយាយសើចលេងបានទេ ។ ដោយទុកចិត្តសុវណ្ណមែន ទែនហើយខ្ញុំស្ទើសេចក្ដីអស់សង្ស័យថា :

- គ្នាដូចជាមិនហ៊ានស្ដីសណ្ដឹងនាងទេវីទេមិត្ត ម្យ៉ាងទៀតគ្នាឥតមាន ស្គាល់នរណាផងដូចឯងដឹងស្រាប់ !

- ឱ្យតែថាឯងពេញចិត្ត ម៉ែឪរបស់គ្នាក៏ឯងអាចពឹងពាក់គាត់បានដែរ ។

- តែថាក្រែងនាងប្រកែក !

- ត្រង់ណេះគ្នាពុំអាចស្មានទេ តែតាមមើលទៅនាងដូចជា មានអធ្យា ស្រ័យចំពោះឯង ល្មមឱ្យគ្នាទុកចិត្តបានថានាងពុំប្រកែកទេ នាងពេញចិត្តនឹងឯង ហើយ . . . !

- ប៉ុន្តែបើនាងប្រកែកវិញ គ្នាមើលទៅអស់បានជាន់ដីសៀមរាប ទៀតហើយ ព្រោះគ្នាខ្មាសនាងខ្លាំងណាស់ ។

- ប៉ុន្តែ ឯងត្រូវតែសង្ឃឹមទៅ !

និយាយដល់នេះ ខ្ញុំឃើញស្រមោលអ្វីភ្លែតមកពីចន្លោះបង្អួចខាង ក្រោយខ្នង ប៉ុន្តែយើងយល់ថា គឺជាស្រមោលរបស់អ្នកដំណើរ ដែលគេទៅមក ជាធម្មតាទេ ។ យើងចាប់និយាយគ្នាបន្តទៅទៀត :

- សុវណ្ណសម្លាញ់ ! យើងឯងថាជួយឃើឆ្ងាលគ្នាហើយ គ្នាក៏សូម អរគុណឯងណាស់ ។

- បើដូច្នោះឆ្លើយថា ឯងពិតជាត្រូវការរូបនាងដោយប្រាកដហើយ មែនទេ ?

- មែនហើយសុវណ្ណ ! គ្នានិងទេវីប្រហែលជាគូពីបុព្វេក៏មិនដឹង ។ គ្នា មិនដែលស្រឡាញ់ស្រីណាផ្ដេសផ្ដាសទេ ដូចឯងនៅភ្នំពេញជាមួយគ្នាដឹងចិត្តគ្នា ស្រាប់ហើយ ។ ប៉ុន្តែចំឡែកស្រីមួយនេះគឺនាង ទេវីនេះ គ្នាជួបភ្លាមដូចជាមានចិត្តគួចទៅលើនាងយ៉ាងត្រង់ៗ តែម្ដងរហូតដល់ទៅយល់សប្តិឃើញយ៉ាងច្បាស់ ផង ។

- យល់សប្តិឃើញថាម៉េច ហើយយល់សប្តិពីថ្ងៃណា ?

- ពីយប់មិញនេះ ដែលឯងដាស់គ្នាហើយបន្ទោសនោះ ។ គ្នាយល់ សប្តិឃើញបាននៅជាមួយនឹងនាង ហើយបានច្រៀងបំពេនាងផង អស្ចារ្យ ណាស់ ! គ្នាមិនដែលយ៉ាងហ្នឹងទេសម្លាញ់ !

សុវណ្ណបែរសើចធ្វើឱ្យខ្ញុំនឹកអៀនបន្តិចឡើងវិញ

- ឃើញទេ គ្នាស្មានមានខុសឯណា ដេកលក់បែកអាចមិថ្ងៃនោះ គ្នា មកពីដេកនឹករលឹកនាង ។ ម្ដឹងហើយនៅតែប្រកែកថាទេទៀត!

- អើ ! មកពីគ្នានៅខ្មាសឯងពេក ។ ឥឡូវដោយយល់ថា ឯងមុខជា មិនសើចមិនយំនឹងគ្នាហើយ ទើបគ្នាដាច់ចិត្តនិយាយនេះ ។

- បើអីចឹងគ្នាគិតនាំរឿងកុសលនេះទៅប្រាប់នាងទេវី

- ទេ ទេ ! កុំសុវណ្ណ ។ ខ្ញុំប្រញ្ញាប់ឃាត់សុវណ្ណ ខ្លាចគេនាំទៅនិយាយ ប្រាប់នាងមែន នឹងនាំឱ្យកើតសេចក្តីអាម៉ាស់ ។ សុវណ្ណ សើចដោយរីករាយ :

- នែចរណៃ ! បើសិនជានាងទេវីមកលបស្ដាប់យើងនិយាយគ្នានេះ បានប្រហែលជានាងសប្បាយចិត្តណាស់ហើយមើលទៅ ។

- ទេ ប្រហែលជានាងជេរលខ្ញុំ ត្បិតខ្ញុំកោងកាចហ៊ានលួចស្រឡាញ់ នាងដរាបដល់ទៅយល់សប្តិអីៗ អើ គ្នាភ្លេចសួរសុវណ្ណឯង នាងរៀនដល់ថ្នាក់ ណា ?

- ដល់ថ្នាក់ទី ៤ ទំនើបនៅវិទ្យាល័យ សុរិយវ័ន្ន ក្រុងសៀមរាបនេះ តែនាងឈឺម្ដាយឪពុកក៏បញ្ឈប់រហូតមក ។ មកយើងចេញទៅរកវង្ស ត្បិតគេ រង់ចាំយើងយូរហើយ ។

- ទៅ ! យីស្រមោលអីមួយភ្លែតនោះ គ្នាដូចជាសង្ស័យថា នាងទេវី មកលបស្ដាប់យើង ! នាងទេដឹង ?

- ទេ នាងនៅឯវង្សរងណោះទេ ។

និយាយផងដើរផង យើងទាំងពីរនាក់ក៏ដល់ក្លោងទ្វារ ស្រាប់តែមើល ទៅឃើញនាងទេវីដើរពីខាងមុខ ឃើញឆ្ងាយបន្តិចជាមួយនឹងទេសចរឯទៀត ។ ខ្ញុំរឹតតែសង្ស័យឡើង :

- សុវណ្ណ ! នាងទេវីពិតជាមកលួចស្ដាប់យើងនិយាយគ្នាហើយ បាន ជានាងទើបតែចេញពីនេះទៅដែរ ។

- ទេ នាងទើបតែចេញពីឡានមកទេ នាងគ្មានទៅដល់កន្លែងយើង ទេ ។

- ប៉ុន្តែគ្នាដូចជាសង្ស័យ . . .

- វាឥតទៅអីទេ បើនាងលបស្ដាប់យើងមែននោះ ក៏រឹងរឹតតែល្អ ណាស់ទៅទៀត ព្រោះថាវាជាជោគជ័យរបស់ឯងមិនអីចឹងឬ ?

សុវណ្ណនិយាយព្រមទាំងសើច ។ យើងទាំងពីរនាក់ឆ្ពោះដំណើរទៅ ដល់ថ្នល់រថយន្ត ។ ឃើញនាងទេវីឈរចាំយើងជាស្រេចនៅក្បែរឡានដែលមាន វង្សនៅពីក្នុង ។

វង្សសើចញញឹមមករកខ្ញុំនិងសុវណ្ណ :

- សុវណ្ណឯង នាំមិត្តយើងទៅកន្លែងណា ក៏បាត់យូរម្ល៉េះ ?

- ហើយវង្សឯងឱ្យទេវីទៅតាមគ្នាឬ ?

- ហ្នឹងឯង ហើយទេវីថាឥតឃើញទេ !

ខ្ញុំឮពាក្យថាទេវីរកខ្ញុំនិងសុវណ្ណមិនជួប ក៏មានសេចក្ដីសុខក្នុងចិត្ត ឡើងវិញដោយគិតថា នាងគ្មានបានឃើញការសម្ងាត់របស់ខ្ញុំទេ ។ ប៉ុន្តែយ៉ាង ណាក៏ដោយខ្ញុំនៅតែរអៀសខ្លួនបន្តិចៗ ព្រោះថាការជំនុំគ្នានឹងសុវណ្ណអម្បាញ់ មិញមានស្រមោលអ្វីមួយនោះ ដែលខ្ញុំនៅតែយល់ថាជាស្រមោលអ្នកលបស្ដាប់ ។

- មកឡើងមក យើងទៅមើលនាគព័ន្ធទៀត ។ ប៉ុន្តែគ្នាដូចជាងងុយ គេងណាស់ ដល់ប្រាសាទនាគពន្ធ័គ្នានឹងសម្រាកបន្តិច តាមតែឯងនាំមិត្តយើងទៅ មើលចុះ ។

- ទៅបើអីចុះ ។

រថយន្តរអិលទៅបត់កុងទៅទិសដែលខ្ញុំស្មានថាខាងកើត ។ រំពេច នោះក៏ដល់ច្រកមួយនៅខាងស្ដាំដៃ ។ រថយន្តតាមបញ្ជារបស់វង្ស បត់ចូលទៅ តាមផ្លូវនោះ ។ ទៅទល់កើលនឹងកំពែងមួយទើបឈប់។ យើងនាំគ្នាចុះ ។ ទី នោះមានអ្នកលក់ផ្លែឈើគ្រប់មុខច្រើនគ្នា ។ ខ្ញុំឃើញទេសចរបរទេសចូលចិត្ត ទិញផ្លែគុយ ហើយខ្លះទៀត ទិញដូងខ្ចី ដែលអ្នកលក់កាប់ឱ្យអាស្រ័យភ្លាមនោះ ។ ដើមឡើយខ្ញុំមិនទឹកថាមានដូងខ្ចីទេ ឥឡូវមានលក់ជាច្រើនធ្លាយ ។ យើង ទាំងបួននាក់ឥតបានទិញអាស្រ័យទេ ព្រោះបាយទើបនឹងឆ្អែត ។ មានលក់ គ្រឿងភ្លេងដែរ ដូចជាអង្គួច និងខ្លុយ ជាដើម ឯកាំបិត, ផ្គាក់, ធ្នូ, ស្នា, ព្រួញ ក៏មានក្មេងតូចៗដើរលក់តែពាសនៅទីនោះ ។ ខ្ញុំសួរគេទៅ គេថារបស់ទាំងនេះធ្វើនៅដែននេះតែម្ដងឥតនាំមកពីណាទេ ។ បរទេសខ្លះចូលចិត្តទិញដែរ ។ បារាំងម្នាក់នោះទិញកាំបិតតូចមួយពីក្មេងខ្មែរម្នាក់ដោយញញឹម ។ ឯខ្ញុំក៏បាន ទិញខ្លុយមួយដែរ ដែលធ្វើឱ្យមិត្តប្រុសស្រីរបស់ខ្ញុំគេសើច ។

- មិត្តចេះផ្លុំខ្លុយផង (វង្សសួរខ្ញុំ) ។

- ចេះតិចៗទេ គ្រាន់តែឮៗ ប៉ុន្តែខ្ញុំទិញនេះ ទិញទុកជារបស់អនុស្សាវ រីយ៍ ព្រោះខ្ញុំបានមកដល់ប្រាសាទមួយថ្មីទៀត ។

- ល្អម្យ៉ាងដែរ ហើយឥឡូវសូមមិត្តអញ្ជើញទៅមើលប្រាសាទនេះ ទៀតចុះជាមួយនឹងសុវណ្ណ និងវី, ឯខ្ញុំ ! សូមទោសចុះ ខ្ញុំនៅចាំឯណេះព្រោះ ធ្ងន់ពោះ បានឆ្អែតដូចជាពិបាកដើរបន្តិច . . . ។ ថាហើយវង្សក៏ចូលទៅទំរេត ក្នុងឡានវិញ ។ សុវណ្ណ ទេវី នាំខ្ញុំទៅមុខ ផុតពីបាំងព្រៃបន្តិចក៏ដល់ឃើញប្រា សាទមួយនៅកណ្ដាលវាលមួយប្រឡង់ដូចជាស្រះ ។ ទៅជិតក៏ច្បាស់ជា ប្រាសាទដែលមានរាងមូល ពីក្រោមមានខ្លួននាគឆ្វាយរង្វេលព័ទ្ធជុំវិញ ឯក្បាល នាគនោះង ឡើងប្រឈមគ្នា ។ នៅមុខក្បាលនាគនោះមានរូបសេះមួយដូចជា មានដំណើរប្រុងហោះទៅ ។ ខ្ញុំជាមួយនិងទេសចរឯទៀតដែរដើរពុយនោះ បានសង្កេតមើលប្រាសាទដោយចិត្តស្ញប់ស្ញែង ។ ប្រាសាទនេះមានកំពែងព័ទ្ធជុំវិញបួនជ្រុងគ្រប់ទិស ទាំងបួនលើកំពែងមានកូនប្រាសាទតូច ដែលនៅពីក្រោម មានរន្ធជាទបង្ហូរទឹក ។

ខ្ញុំយល់ថារន្ធទាំងនេះសម្រាប់បញ្ចេញទឹកពីស្រះធំមក កាលណាស្រះធំនោះទឹកពេញព្រៀប ។ ខ្ញុំសួរទៅសុវណ្ណក្រែងគេដឹងរឿង ប្រាសាទ :

- ប្រាសាទនេះសុវណ្ណឯងយល់យ៉ាងណាដែរ ?

- គ្នាមិនមែនអ្នកសិក្សាប្រវត្តិសាស្ត្រឯណា ឯងសួរគ្នាយ៉ាងនេះ? បើ ដោយមើលឃើញគឺប្រាសាទនាគព័ន្ធវាមាននាគ មួយគូវាព័ន្ធគ្នាមែន ចរណៃឯង ម៉េចក៏មិនមើលទុំះ ? ប៉ុន្តែចរណៃឯងសួរអ្នកវីម្ដងមើល ក្រែងអ្នកវីដឹងប្រវត្តិ សាស្ត្រ ។

សុវណ្ណនិយាយចោលនូវញញឹមទៅរកនាងទេវីផង តែនាងមានទឹក មុខមាំ ហើយបដិសេធថា :

- ខ្ញុំមិនដឹងទេ ខ្ញុំមិនមែនអ្នកប្រវត្តិសាស្ត្រទេ . . .

សំដីនេះមានសំឡេង ដែលមិនសប្បាយចិត្តចេញមកផង ។ ខ្ញុំឃើញ ដូច្នោះក៏ចាប់ភ័យមួយរំពេច ។ ខ្ញុំចេះតែនឹកឃើញថា នាងពិតជាលបស្ដាប់ការ សន្ទនារបស់ខ្ញុំនិងសុវណ្ណ បាននាងមិនសប្បាយចិត្ត ។ នាងមិនត្រូវការរូបខ្ញុំ ឡើយ ខ្ញុំនិងសុវណ្ណមិនតបទៅនាងទេ ដើរទៅឡើងតួប្រាសាទនាគពន្ធ័ ឯនាងៗ នៅឈរបែបព្រងើយនៅលើកំពែង ខ្ញុំនិយាយទៅនឹងសុវណ្ណ :

- នាងពិតជាខឹងនឹងសំដីឯង ឬមួយក៏នាងខឹងនឹងគោលបំណងរបស់ គ្នា ដែលគ្នានិយាយនៅប្រាសាទព្រះខ័ននោះ បើពិតជានាងអន់ចិត្តនឹងរូបគ្នា ដែលគ្នាស្រឡាញ់នាង គ្នានឹងឡើងឡានទៅភ្នំពេញល្ងាចនេះឯង ។

- ម៉េចក៏ដូច្នោះ ?

- គ្នាអៀនខ្មាសនាងខ្លាំងណាស់ គ្នាមិនអាចនៅទីនោះឱ្យនាងឃើញត ទៅទៀតបានទេសម្លាញ់ !

- នែ ! កុំផ្ដាស់ វាមិនទៅជាអីទេ យើងនៅតែធ្វើមិនដឹងមិនឮទៅ ។ បើឯងទៅភ្នំពេញតឹងតាងដូច្នេះឃើញថានាំឱ្យខ្មាសគេច្រើនទៅទៀត ឯងនឹង ទៅជាមនុស្សមិនល្អទៅវិញ ។

សំដីពន្យល់របស់សុវណ្ណក៏ខ្ញុំស្ដាប់បាន ទើបស្ងៀមចិត្តទៅវិញ ។ យើង នាំគ្នាចុះពីលើប្រាសាទ ដើរត្រឡប់មករកនាងដើម្បីឱ្យដឹងថាមើលចប់ហើយ ហើយត្រូវត្រឡប់ទៅឡាន ។ ខ្ញុំពុំហ៊ានមើលនាងឱ្យចំទេ ខ្មាសនាងខ្លាំងណាស់ តែនាងនិយាយមករកខ្ញុំមុនថា :

- លោកមើលចប់សព្វគ្រប់ហើយឬ ?

- បាទ អ្នកបានហើយ !

- លោកបែបមិនសប្បាយទេឬ ?

សុវណ្ណឆ្លើយភ្លាមជំនួសខ្ញុំ :

- ដឹងជាយ៉ាងម៉េចទេ អម្បាញ់មិញស្រាប់តែទារទៅភ្នំពេញតែម្ដង !

នាងងាកមើលមុខខ្ញុំដោយយកចិត្តទុកដាក់ :

- លោកប្រញាប់ទៅភ្នំពេញធ្វើអី មិនសប្បាយ ឬនៅទីនេះ លោកខឹង នឹងខ្ញុំឬ ចាស . . . ?

ខ្ញុំថាខ្លាំង១តែឱ្យតែលោកសុវណ្ណទេ ឯលោកវិញឥតខឹងទេចាស លោកចង់ទៅភ្នំពេញមែនឬ ?

- បាទទេ ! ខ្ញុំឆ្លើយដោយដាក់មុខដំណាលគ្នានឹងអាការញញឹមរក នាង នាងបន្តថា :

- ន៎ លោកសុវណ្ណកុហកខ្ញុំទេ លោកខាងណេះឥតមានចង់ទៅភ្នំពេញ ទេ ។ ណ្ហើយ ! យើងទៅទៀត !

ថាហើយនាងបោះជំហានសន្សឹម១ទៅកាន់រថយន្ត ។ ខ្ញុំនិងសុវណ្ណដើរ តាមទៅ ។ សុវណ្ណទះខ្នងខ្ញុំតិច១ :

- ទេវីប៉ុនខាងនិយាយលួងណាស់ ចរណៃឯងជាអ្នកងទៀត ត្រូវគ្នា ម៉ាច់តែម្ដង ។

ខ្ញុំមិនបានតបទេ តែពេញចិត្តនឹងពាក្យបញ្ចុកបញ្ចៃងនេះដែរ ។ យើង ទៅដល់រថយន្ត ដែលវង្សបានបញ្ឆេះចាំជាស្រេច វង្សរីករាយមករកខ្ញុំ ។

- យើងត្រូវទៅមុខទៀត ប៉ុន្តែប្រាសាទខ្លះយើងគ្រាន់តែចូលមើល បានហើយ កុំបាច់ឡើងធ្វើអី ព្រោះថាក្រែងមើលប្រាសាទឯទៀតពុំអស់ ថ្ងៃ ជ្រៃណាស់ទៅហើយផង ម៉ោង ៧ ត្រូវទៅដល់ផ្ទះវិញ ។

- បាទ អីចឹងហើយខ្ញុំក៏គិតដូចហ្នឹងដែរ ។

យើងឡើងឡានធ្វើដំណើរទៅមុខ មួយសន្ទុះនោះ ក៏បានដល់ក្លោង ប្រាសាទមួយមានឫសជ្រៃចាក់ព័ទ្ធពន្ធ័ ។ ក្លោងទ្វារនេះនៅខាងឆ្វេងដៃ ។ នាង ទេវីនិយាយតិច១ថា :

- នេះគឺក្លោងទ្វារប្រាសាទតាសោម ។

រថយន្តបន្តដំណើរទៅមុខទៀត ក្នុងល្បឿនថ្នមតិច១ ប្រហែល ២គីឡូ ម៉ែត្រ ក៏ឃើញប្រាសាទមួយខ្ពស់ជ្រងោនៅកណ្ដាលវាល ។ វង្ស បញ្ឈប់ឡាន :

- នេះប្រាសាទឈ្មោះ មេបុណ្យ ! ទៅយើងនាំគ្នាចូលទៅមើល

ប្រាសាទនេះបន្តិច ។

- មែនហើយ គ្នាគ្មានបុណ្យ គ្នាចូលទៅសុំបុណ្យពីប្រាសាទនេះបន្តិច !

សុវណ្ណនិយាយកំប្លែងមើលទៅមុខនាងទេវី ដែលនាងបែបដូចជា ទាស់អធ្យាស្រ័យខ្លាំង ។ នាងងាកមករកខ្ញុំ :

- លោក ! ខ្ញុំនិងលោកសុវណ្ណមិនសូវត្រូវធាតុគ្នាទេ

លោកសុវណ្ណនិយាយគ្មានបានការអីសោះ ! លោកជួយស្ដាប់មើលចុះ ពីមុនមកសួរខ្ញុំឱ្យពន្យល់ប្រាសាទនាគព័ន្ធ ឥឡូវធ្វើចេះមកជឿប្រាសាទមេ បុណ្យ ថាឱ្យបុណ្យឱ្យអី ! ខ្ញុំដូចជាទ្រាន់ណាស់ ។ សូមលោកអត់ទោស, កាល នៅនាគព័ន្ធនោះ ខ្ញុំឥតខឹងនឹងលោកទេ ចាស ខ្ញុំខឹងតែលោកសុវណ្ណទេ . . .

- មិនអីទេខឹងចុះខ្ញុំ ឱ្យតែត្រូវភ្ញៀវទៅចុះ សុវណ្ណឯណេះត្រេកអរជា ទីបំផុត !

សុវណ្ណតបភ្លាមវិញ ធ្វើឱ្យនាងអៀនបែរមុខចេញលែងហ៊ានមើលមុខ ខ្ញុំ ។

ខ្ញុំមានសេចក្ដីស្ងប់ស្ងៀម មិនសំដែងអាការសប្បាយចំពោះពាក្យសំដី របស់សុវណ្ណទៅក្រែងនាងខឹង ។ ខ្ញុំមើលទៅប្រាសាទធ្វើវាហី ។ ដូចជាទីកន្លែង ឯទៀតដែរ ទីនេះទទួលអ្នកដំណើរយ៉ាងកុះករ ។ រូបរាងរបស់ប្រាសាទធ្វើឱ្យខ្ញុំ ជាប់ចិត្តជាខ្លាំង ខ្ញុំសង្កេតយល់ថា ស្នាដៃរបស ដូនតាខ្មែរយើងអាចធ្វើឱ្យជន បរទេស ក៏ដូចជាខ្មែរសម័យថ្មីនេះ មានសេចក្ដីកោតស្ញែងជាពិសេស ។ មើល ប្រាសាទដែលគេហៅថា មេបុណ្យហ្នឹងរួច រាល់គ្នាចាប់ចេញដំណើរទៅទៀត ។ ខ្ញុំពុំដឹងជាទៅណាមកណាទេ ស្រេចតែវង្សជាមគ្គុទេសក៏ទៅចុះ ។ រំលងមកមិន ជាឆ្ងាយប៉ុន្មានក៏ខ្ញុំបានឃើញប្រាសាទមួយទៀត ។ វង្សបញ្ឈប់យាន ។

- នេះជាប្រាសាទប្រែរូប យើងចូលទៅមើលឬ ? តែសុវណ្ណ ប្រញាប់ ឃាត់ :

- ទេ ទេ ! មើលតែពីចម្ងាយបានហើយ គ្នាខ្លាចណាស់ពុំចង់ចូលជិត ទេប្រាសាទប្រែរូប គ្នាមិនចង់ប្រែរូប រូបគ្នាសព្វថ្ងៃ ហ៊ឺហាស្រាប់ហើយ !

សំដីរបស់សុវណ្ណនេះធ្វើឱ្យនាងទេវីតបវិញយ៉ាងខ្លាញ់ :

- កាន់តែផ្ដេសផ្ដាស់ហើយលោកសុវណ្ណឯង ប្រាសាទនេះមិនមែន សម្រាប់លោកសុវណ្ណឯងប្រែរូបទេ ប្រហែលគេសាងសម្រាប់បូជាសពស្ដេចទេ ។ មនុស្សធុនដូចលោកសុវណ្ណឯង គេយកទៅចោលក្នុងព្រៃឯណោះទេ !

នាងសើចឡើងយ៉ាងជោគជ័យ ឯសុវណ្ណក៏សើចដែរឥតខ្មាស ។ ខ្ញុំមិន យកចិត្តទុកដាក់នឹងការជជែកនេះទេ អាត់តែមើលប្រាសាទ ។ ប្រាសាទដែល គេហៅថាប្រែរូបនេះ មានទ្រង់ទ្រាយសក្តិសមណាស់ដែរ ។

បន្ទាប់ពីនោះយានត្រូវរអិលចេញពីនោះទៅទៀត ។ វង្សអ្នកកាន់ ចង្កូតបាននិយាយរកខ្ញុំ :

- យើងទៅមុខទៀត នឹងឃើញស្រះស្រង់ និងបន្ទាយក្ដី ។ បន្ទាប់ពី នោះមានម្លប់ឈើត្រជាក់ណាស់មិត្តពិតជាសប្បាយមិនខាន ។

ក្រោយដែលពោលរួចមិនយូរ រថយន្តក៏បានដល់ទន្ទឹមនឹងវង់វាលមួយ ដែលមានទឹកបន្តិចនៅកណ្ដាល ។ វាលនេះនៅខាងឆ្វេងដៃ ។ នាងទេវីនិយាយ ប្រាប់ខ្ញុំថា :

- នេះហើយលោកគេហៅថា ស្រះស្រង់ ។ ន៎, នៅខាងលិចនោះមាន ជណ្ដើរចុះមករកទឹក ។ កាលពីរដូវវស្សាមានទឹកពេញ ឥឡូវរីងអស់ហើយ នៅ តែកណ្ដាលបន្តិចនោះ ។

- ខ្ញុំមើលទស្សនីយភាពនោះដោយប្រាមោទ្យ ។ នៅមាត់បឹងមាន ក្របី ២-៣ កំពុងបោចស្មៅ ។ តាមស្មានប្រហែលជាសត្វនោះវាទើបនឹងងើបពី ត្រាំទឹកនោះហើយ ។ វង្សនិយាយឡើង :

នៅកណ្ដាលស្រះស្រង់នោះពីដើមមានប្រាសាទមួយ តែឥឡូវបាក់ បែករលុបរលាយទៅហើយ ។ ខ្ញុំស្ដាប់ដោយដកដង្ហើមធំស្ដាយ ។

ហួសពីនោះទៅដល់កំពែងមួយ ឡានបត់ទៅស្ដាំ ហើយបន្តដំណើរ ទៅទៀត ។ នៅផ្លូវនោះម្លប់ឈើត្រឈៃត្រជាក់នាំឱ្យសប្បាយចិត្តណាស់ ។ ខ្ញុំ ពេលនេះសែនរំភើបចិត្តឥតថ្លឹងថ្លែង បរិយាកាសទីនេះជំរុញស្មារតីខ្ញុំឱ្យអណ្ដែត អណ្ដូង យ៉ាងណាយ៉ាងណីមិនប្រាកដ ។ នាងទេវីនៅអង្គុយជិតខ្ញុំដៃម្ខាងឱប ពោះ ដៃម្ខាងទ្រចង្ការភ្នែកមើលទៅមុខម្ដង មើលទៅចំហៀងម្ដង ។ ផ្សំនឹង ទេសភាពពេលនេះដែលមនោរម្យស្រាប់ផង រូបកាយនាងក៏ក្លាយទៅជាទេព អប្សរមួយ មិនមែនស្ថិតនៅក្នុងសេចក្ដីស្រមៃឡើយ ។ ក្ដីប្រតិព័ទ្ធរបស់ខ្ញុំ

ចំពោះរូបនាងក៏លាស់លេចឡើងជាលំដាប់ ។ ខ្ញុំគិតថា អញត្រូវតែបញ្ចេញ បំណងអញក្នុងពេលណាមួយដែលអាចបញ្ចេញបាន អញមិនត្រូវលាក់លៀមទេ អញត្រូវមានផងសេចក្ដីក្លាហានក្នុងរឿងនោះ បើអញនៅតែស្ងៀមរហូត ឃើញថានាងពុំយល់ចិត្តអញ ហើយគោលបំណងរបស់អញក៏មិនដឹងជាមានផល ឬគ្មាន ដូច្នេះដើម្បីឱ្យបានដឹងផលនេះ ត្រូវតែអញនិយាយ . . . ។ តើអញគិត និយាយអ្វីជាមុនឱ្យនាងយល់បំណងអញ ?

កំពុងគិតនោះ ខ្ញុំភ្ញាក់ព្រើតដោយនាងនិយាយថា :

- លោក ! ខ្ញុំភ្លេចជំរាបលោក នៃកំពែងដែលនៅឆ្វេងដៃយើងនេះ ជាកំពែងប្រាសាទ បន្ទាយក្ដី យើងមិនបានចូលមើលប្រាសាទបន្ទាយក្ដីនេះទេ យើងទៅមើលប្រាសាទតាព្រហ្មតែម្ដង ។ ប្រាសាទតាព្រហ្មមានម្លប់ឈើត្រជាក់ ណាស់ ទំ, ឥឡូវយើងមកដល់កំពែងខាងមុខប្រាសាទតាព្រហ្មហើយ :

ខ្ញុំងក់ក្បាលផ្ទំនឹងពាក្យបាទ ! ផងតែអារម្មណ៍ខ្ញុំដូចជាមិនទាន់ ស្រឡះពីការសល់វល់នៅឡើយទេ ។ ឡានបើកមិនជាលឿនប៉ុន្មាន ខ្ញុំមើល ព្រឹក្សព្រៃបានយ៉ាងហូរហែ ។ ខ្ញុំបង្វែវិញ្ញាណត្រិះរិះតទៅទៀត ។

ស្រាប់តែសុវណ្ណស្រែកយ៉ាងស្លន់ថា : ជ្រូកព្រៃ ! បន្ទាន់នឹងសម្លេង នេះ រថយន្តក៏គេចឃ្លោងទៅចិញ្ចើមថ្នល់ គ្រលែងខ្ញុំទៅប៉ះអែបនឹងជញ្ជាំងនាង ទេវី រអិលមកលើខ្ញុំដូចគេលើកមកដាក់ ខ្ញុំត្រកងនាងជាប់ មិនឱ្យជ្រុលទៅប៉ះ នឹងកញ្ចក់ រាងកាយរបស់នាងនៅលើរង្វង់ដៃខ្ញុំទាំងស្រុង ឡានរត់ទៅមុខតែ បន្តិចក៏លាន់ផ្ទុះផូស ! ហើយស្ងៀមនៅ. . . នាងប្រញាប់ងើបពីការប្រឱបរបស់ ខ្ញុំ ឯវង្ស និង សុវណ្ណក៏រហ័សបើកទ្វារចេញមកក្រៅ ខ្ញុំនិងនាងចុះមកដែរ ។ វង្ស ឈ្ងោកមើលក្រោមហើយគ្រវីក្បាល :

- ស្រេច ! បែកកង់ស្រេច ! ឯងភ្លេចយកមួយមកកំដរផង បានអី ទៅផ្ទះ ....

- វង្សឯងគេចទៅបុកថ្មស្រួចនោះខ្លាំងពេក បានជាដូច្នេះ, បើកបុក ជ្រូកនោះទៅមានអី !

- សុវណ្ណឯងស្រែកខ្លាំងពេក គ្នាវាំបែបស្លន់ទើបបែរជាបើកចៀស ប៉ុន្ដែបើបុកជ្រូកក៏ប្រហែលជាក្រឡាប់ផង ។

- ឥឡូវគិតយ៉ាងណា វីវរធំហើយ គ្នាដើរទៅផ្ទះមិនដល់ទេ ឆ្ងាយ ណាស់លោកអើយ ។

ខ្ញុំនិងទេវីមិនបញ្ចេញសំដីអ្វីទេ មើលទៅកង់រថយន្តដោយអស់សង្ឃឹម ព្រោះឃើញស្ពៀតនឹងដីទៅហើយ ។ ខ្ញុំមិនដឹងចម្ងាយផ្លូវទៅផ្ទះផង ដូច្នោះក៏ មិនដឹងជានឹងជូនយោបល់ថាយ៉ាងម៉េច ។ ឯទេវីនាងឈរស្ងៀមព្រងើយ នាង ផាត់សក់ឱ្យមានរបៀបរៀបរយឡើងវិញ ខ្ញុំមើលទៅនាង នាងងាកមុខចេញ ទ្រង់ខ្មាសខ្លាំង ដែលនាងធ្លាក់មកនៅក្នុងការប្រឱបរបស់ខ្ញុំអម្បាញ់មិញនេះ ។ ពេលនោះវង្សស្នើឡើង :

- មិនជាអីទេ ខ្ញុំគិតទៅផ្ទះវិញតែម្នាក់ឯងទៅយកកៅស៊ូកង់មកផ្លាស់ ឱ្យសុវណ្ណឯងនិងទេវីនៅចុះហើយមិត្តយើងឯណេះទៅមើលប្រាសាទតាព្រហ្ម ទៅកុំឱ្យខាតពេល គ្នាមកវិញដាក់កង់ដាក់អីហើយរួចល្មម ឯងក៏មើលប្រាសាទ រួចដែរ ។

- តើវង្សឯងទៅដើរឬ ? សុវណ្ណសួរ ។

- ទេ ! ឆ្លតសោះហើយនរណាងាយដើរនោះចម្ងាយ ៦-៧ គីឡូ ។ គ្នាចាំដោយសារឡានគេ ដែលគេទៅក្រុងសៀមរាបវិញ ។

ថាហើយវង្សក៏ដើរចេញទៅកណ្ដាលថ្នល់ ចាំមើលឡានសុំដោយសារ ។ ពេលនោះមានឡានជាហូរហែ តែឡានទាំងនោះផ្ទុកមនុស្សពេញៗទាំងអស់ ។ ឡានទាំងនោះបើកមកទន្ទឹមនឹងឡានយើង តែងបង្អង់ហើយមនុស្សក្នុងនោះ តែងអើតមើលមក រួចហួសទៅ។ វង្សមិនសុំដោយសារទេចាំមើលឡានទូលាយ ។ កាលបើឃើញខ្ញុំនៅរេរាជាមួយគេ វង្សក៏តឿនថា :

សុវណ្ណ នាំមិត្តខាងណេះទៅមើលប្រាសាទនោះទៅ គ្នាឯណេះ កុំគិត បន្ដិចនឹងមានឡាន ឬរ៉ឺម៉កមកដល់ហើយ ។ ទើបសុវណ្ណនិងទេវីហៅខ្ញុំដើរតាមទៅ ។

- យើងមើលបានតែប្រាសាទមួយនេះទេ ចំរាំវង្សមកវិញ ព្រលប់ល្មម ។ សុវណ្ណនិយាយផងដើរផងដល់ក្លោងទ្វារប្រាសាទ ។ រំលងពីក្លោងទ្វារហ្នឹងទៅ បានដល់ផ្លូវមួយស្អាត ។ នៅអមផ្លូវនោះ ដើមឈើធំៗលូតខ្ពស់ ខ្ញុំងើយសឹងបាក់ កទើបមើលដល់ចុង ។ ម្លប់មកក្រោមព្រមទាំងខ្យល់រំភើបផាត់មក ខ្ញុំសែន រំភើបចិត្ត គិតសប្បាយឥតមានសៅ ។ ផុតពីនោះក៏ដល់គំនរថ្មដ៏ប្រកបដោយ ក្បាច់រចនាដែលខ្ញុំអាច

យល់ថាថ្មទាំងនោះគឺជាបំណែកនៃប្រាសាទបាក់បែករលំ រលីង . . . ។ ស្ងើចអស្ចារ្យក្នុងចិត្ត ខ្ញុំសន្មត់ខ្លួនឯងថា ជាអ្នករុករកម្នាក់ឯង អ្នកឯទៀតដែលមកមើលដែរនេះ ក៏គឺជាអ្នករុករកដែរ ។ យើងរាល់គ្នាបានប្រទះ ឃើញទូរមហាប្រាសាទបាក់បែកនេះ . . . ។ ភាពនេះបាននាំឱ្យខ្ញុំឱបដៃរឹង មួយសន្ទុះ នឹកដល់អតីតកាលរបស់ខ្មែរ ។ ខ្ញុំនឹកឃើញថា ជំនាន់មុននោះពិតជា បរិបូរណាស់ខាងឫទ្ធានុភាព ។ រូបចម្លាក់ពាសពេញ ហាក់ដូចជានិយាយមក កាន់ខ្ញុំថា : ខេមរជន ! អ្នកមានវាសនាហើយ ដែលបានមកឃើញសំណាម អតីតកាលរបស់អ្នក ! សតវត្សមួយដែលពោរពេញដោយអានុភាពគឺជា សត វត្សដែលមានរូបខ្ញុំនៅត្រៀបត្រានេះជាតំណាង ។ តែកាលណាទៅហ្ន៎ ទើបខ្លួនខ្ញុំអាចនឹងទៅផ្គុំគ្នាជាប្រាសាទមួយដូចជំនាន់ដើមបាន ! ខ្ញុំ. កាលណាបើដូចជា ឮថ្មនិយាយមកដូច្នេះក៏ព្រឺសពិង្គកាយ . . . ខ្ញុំចង់និយាយទៅកាត់ថ្មវិញថា : អ្នកមិនអាចនឹងផ្គុំគ្នាជាតួប្រាសាទឡើងវិញក៏ពិតមែន តែរូបអ្នកនាំឱ្យគេនិងខ្ញុំ ជឿជាក់បានណាស់ទៅហើយ ជឿថាអ្នកពិតជាមហាវិមានមួយរបស់ខ្មែរក្នុង អតីតកាល ហើយវិមាននោះមានរូបរាងជានិច្ចក្នុងសេចក្ដីស្រមៃរបស់ខ្មែរ បច្ចុប្បន្ន . . . មនោគតិរសាត់មួយភាំងយ៉ាងនេះក៏ដូចជាភ្លេចនឹកដល់រូបារម្មណ៍ របស់ទេវីដែលនាងឈរជិតខ្ញុំ :

- លោក ! លោកគិតស្ងើចអ្វីខ្លាំងម្ល៉េះចាស ?

- បាទទេ ប្រាសាទនេះនាំឱ្យខ្ញុំអស្ចារ្យណាស់អ្នក !

ខ្ញុំពុំឃើញសុវណ្ណទើបសួរ

- អ្នក ! ឯណាសុវណ្ណ មិនឃើញ ?

- អម្បាញ់មិញគាត់ជួបពួកម៉ាកមួយហ្វូង និយាយគ្នាមួយម៉ាត់ពីរ ក៏ នាំគ្នាដើរទៅលបមើលស្រី១ ហើយលោកសុវណ្ណនេះខូចណាស់ ។

- គេមានផ្ដាំថាម៉េចដែរ

- ថាឱ្យខ្ញុំនិងលោកនៅចាំគេត្រង់នេះមួយភ្លែត តែបើយូរថាឱ្យយើង ទៅណាទៅចុះ ចាំជួបគ្នាឯឡាន ។ ខ្ញុំស្មានមើលទៅលោកសុវណ្ណពុំងាយមកទេ យើងមិនបាច់ចាំគេទេចាស ។

- បើអីចឹងយើងគិតទៅចាំគេឯឡានវិញ ក្នុងពេលនេះឬ យ៉ាងណា ?

- ស្រេចតែលោកទេ តែលោកមិនដែលស្គាល់ប្រាសាទ គួរណាស់តែ ដើរមើលទៅចុះ ហើយយើងមើលរួចទៅឡានតែម្ដង ។

បាទ !

ខ្ញុំនឹកឆ្ងល់នឹងសុវណ្ណមិត្តខ្ញុំ ។ គេទៅម៉េចមិនប្រាប់ខ្ញុំ ឬគេ ក្រែងខ្ញុំ ឃាត់ជំទាស់អ៊ីចេះអ៊ីចុះ គិតទៅសុវណ្ណខិលមែនគាត់នេះ។ ប៉ុន្តែខ្ញុំបែរជាយល់ ផ្សេងថា សុវណ្ណទុកឱកាសឱ្យខ្ញុំមានសេរីភាព នឹង និយាយរកទេវី ។ ការយល់ ឃើញក្រោយនេះ ខ្ញុំអណ្ដែតចិត្តដោយក្ដីសោមនស្សហើយចង់ថ្លែងអំណរគុណ ជាភិយ្យោភាពចំពោះមិត្ត សុវណ្ណ ។ ខ្ញុំនិងនាងទេវីតែពីរនាក់ គ្មានស្គាល់នរណា ហើយនរណាម្នាក់ក៏ឥតស្គាល់ខ្ញុំ ។ ខ្ញុំនិងនាងដើរមើលប្រាសាទតទៅទៀត ប៉ុន្តែ ខ្ញុំមិនបានយកប្រាសាទជាអារម្មណ៍ដូចមុនទេ ខ្ញុំជាប់ចិត្តក្នុងសេចក្ដីត្រិះរិះច្រើនជាង ។ ខ្ញុំដកដង្ហើមធំដូចឥតដឹងខ្លួន ទើលបមើលមុខខ្ញុំ ហើយងាកទៅទីផ្សេង ។ ខ្ញុំឃើញនាងលបមើលមុខខ្ញុំហើយងាកចេញនេះ ខ្ញុំក៏ដឹងថានាងគង់សង្កេតសេចក្ដីទុក្ខរបស់ខ្ញុំបាន ។ កាលបើដឹងថា នាងសង្កេតសេចក្ដីទុក្ខរបស់ខ្ញុំបាន ខ្ញុំ ក៏ដូចជាមានសេចក្ដីក្លាហាន ចង់តែសារភាពភ្លាម អំពីបំណងយ៉ាងណារបស់ខ្ញុំ ។ វេលានេះ ទឹកន្លែងនេះ មិនបានឱ្យខ្ញុំរក្សាសេចក្ដីខ្មាសអៀន ហើយលាក់លៀម ដូចវេលាមុន ទឹកន្លែងមុនទេ ។ ខណៈនេះខ្ញុំគិតថា ទោះជាបានសម្រេច ឬមិន បានសម្រេចក៏ដោយ ដោយដាច់ខាតត្រូវតែនិយាយប្រាប់នាងដោយលទ់តួថា សូមស្រឡាញ់នាងហើយសូមឱ្យនាងស្រឡាញ់ខ្ញុំវិញ . . . ។

ដើរទស្សនាប្រាសាទជាមួយនឹងគំនរសេចក្ដីត្រិះរិះ ខ្ញុំកន្លងថ្មបោះ ជំហានដោយលំបាក ។ ទៅដល់ថ្មមួយផ្ទាំងនៅក្រោមម្លប់ ឈើសាខាខ្ញុំអង្គុយចុះ ហើយមើលទៅមេឃដោយស្មារតីវិលវល់ ។ សម្លេងរៃស្រែករពេ៍ជាប់រដឹកនៅ ក្បែរនោះ ។ ខ្ញុំដាក់មុខចុះមកវិញ ឈ្ងោកថ្មមើលស្រមោច ២-៣ កំពុងត្រេច ទៅមក មានក្លិនផ្កាអ្វីម្យ៉ាងក្រអូបភាយមក ក្លិននោះហាក់ដូចជាជួយអប់ដួង ចិត្តខ្ញុំឱ្យរីតតែមនោរម្យស្នេហាខ្លាំង

ទេ្វ សេចក្តីប្តេជ្ញចិត្តរបស់ខ្ញុំ ដែលថាត្រូវតែ សារភាពរឿងពិតដល់នាងនោះបានតឿនខ្ញុំគ្រប់ដង្ហើម ។ តែខ្ញុំមិនដឹងជាផ្តើម យ៉ាងណាមុនទេ ។ ទេវីនាងនៅឈរជិតនោះសួរខ្ញុំដោយសម្លេងស្រាលថា :

- លោកមិនស្រួលខ្លួនឬចាស បានជាមកអង្គុយដូច្នេះ

- បាទទេអ្នក !

- កើតទុក្ខអ្វីចាស !

- ហើយនាងទៅអង្គុយនៅលើថ្មមួយផ្ទាំងមើលមកខ្ញុំ ។ ខ្ញុំដកដង្ហើម ធំយ៉ាងវែងមើលទៅមុខនាង ។

- អ្នកវី ! ខ្ញុំមានទុក្ខធ្ងន់ណាស់ . . . ។

នាងមិនតបទេ ខ្ញុំបន្តទៅទៀត :

- ខ្ញុំមិនហ៊ាននិយាយទេ ទាល់តែអ្នកវីអត់ទោសឱ្យខ្ញុំ

ខ្ញុំបង្អង់សំដីព្រោះដូចជាគិតមិនឃើញទៅទៀត, ឯនាង នាងនៅ ស្ងៀម ឈ្ងោកមុខយកដៃកេះថ្ម ។ ខ្ញុំទើបរកពាក្យនិយាយបន្ថែម

- អ្នកកុំប្រកាន់ខ្ញុំឱ្យសោះ ខ្ញុំចង់ជំរាបអ្នកដោយស្មោះរឿងមួយ. . .

សំដីនេះបង្អាក់សិនរកតទៅទៀតពុំកើត ។ នាងងើបមើលមុខខ្ញុំបន្តិច ទើបឈ្ងោកទៅវិញហើយនិយាយថា :

- លោក ខ្ញុំបានដឹងបំណងរបស់លោកហើយ ខ្ញុំបានលបស្តាប់លោក និងលោកសុវណ្ណនិយាយគ្នានៅប្រាសាទព្រះខ័ននោះហើយ . . . !

វាចាប៉ុណ្ណេះម៉ាត់ ស្ទើរឱ្យខ្ញុំស្ទុះក្រោកលែងហ៊ាននៅជិតនាង ដោយ ខ្មាស ប៉ុន្តែស្ងប់ចិត្តទៅវិញភ្លាមដោយរហ័សថា រឿងនេះជាពាក្យផ្តើមរបស់ខ្ញុំ ទៅវិញទេតើ ដែលខ្ញុំពិបាកនឹងនឹករកនោះ ។ ដូច្នេះខ្ញុំនៅសល់តែពាក្យលន់តួ ទេ ដែលត្រូវនិយាយទៅកាន់នាង ។

- បើអ្នកបានឮខ្ញុំ និងសុវណ្ណនិយាយគ្នាហើយ ខ្ញុំក៏ដូចជាអស់សេចក្តី ជំរាបទៅហើយ ហេតុនោះហើយសូមអ្នកអត់ទោសឱ្យខ្ញុំចុះ ដែលគ្រាន់តែមក ជួបអ្នកម្តង ហើយហ៊ានស្រឡាញ់អ្នកដល់ទៅម្ល៉េះ

ខ្ញុំបញ្ឈប់សំដីចាំស្តាប់នាង ក្រែងនាងត តែនាងមិនតនឹងខ្ញុំទេ នៅ ឈ្ងោកមុខដដែល ខ្ញុំនិយាយទៀត :

- អ្នកវី ! ដោយមានជំនឿដ៏ពិតប្រាកដថា កន្លែងនេះ ជាកន្លែងពិសិដ្ឋ ខ្ញុំសូមយកទេវរូបទាំងឡាយ នៅកន្លែងនេះជាកសិណសាក្សីនៃពាក្យសំដីរបស់ ខ្ញុំ ! ខ្ញុំសូមជំរាបថា ខ្ញុំបានលួចស្រឡាញ់ទេវី តាំងពីគ្រាឃើញទេវីលោកដំបូង ម្ល៉េះ ។ ហើយសេចក្តីស្រឡាញ់នោះ បង្ខាប់ឱ្យខ្ញុំមានចិត្តប្តេជ្ញមួយស្ថិតនៅក្នុង ការផ្សងព្រេង ។ ខ្ញុំពុំដែលស្រឡាញ់ស្រីណាដល់ទៅរវើរវាយទេ . . . ។

សំដីនេះត្រូវបង្អង់ដោយនាងងើបមើលមកខ្ញុំ មុខនាងឡើងក្រហម តែស្រងូត ខ្ញុំអាចយល់ថា នាងខ្មាសអៀនលាយឡំនិង សេចក្តីអាណិតដល់ខ្ញុំ ។ ខ្ញុំក៏បន្តវាចាទៅទៀត :

- អ្នកវី ! ខ្ញុំដែលហ៊ាននិយាយនេះគឺមកពីអត់ទ្រាំពុំបាន ខ្ញុំពុំអាចឱប យកសេចក្តីព្រួយវិតក្កទៅស្រុកវិញបានទេ ហេតុនេះសូមអ្នកវីអត់ទោសខ្ញុំទៅ ចុះ ហើយសូមអ្នកវីមេត្តាសម្រេចចិត្តបានបន្តិច ឱ្យខ្ញុំដឹងផង ។

នាងនៅស្ងៀមហើយមុខក៏កាន់តែឈ្ងោកទៅ ខ្ញុំអង្គុយសម្លឹងនាង ដោយអំណាចស្នេហាដែលជិតដាមមកជាយូរ ខ្ញុំក៏ងើបទៅអង្គុយក្បែរនាង ដោយឥតក្រែង ប៉ុន្តែក្នុងទ្រូងញាប់ញ័រខ្លាំងណាស់ ។ ខ្ញុំនិយាយថ្នមទៅនាង !

- ទេវី ! ទេវីមិនអាណិតខ្ញុំដល់បន្តិចសោះឬ ? ទេវីចង់ឱ្យខ្ញុំទៅស្រុក វិញក្លាយទៅជាមនុស្សមានវិបត្តិចិត្តឬអី ខ្ញុំស្តាយណាស់ អ្នកវី ដែលខ្ញុំមិនគួរ យកដៃនសៀមរាបនេះ ជាដើមហេតុនៃសេចក្តីទុក្ខប្រចាំជីវិតសោះ . . . ។

ខ្ញុំបង្អង់វាចាត្រឹមនេះ ដកដង្ហើមធំយ៉ាងណែន ដោយអស់សង្ឃឹម ។ ពេលនេះនាងនិយាយស្ទើរខ្សិបថា :

- ខ្ញុំមិនបានប្រកាន់លោកទេ ហើយខ្ញុំក៏មិនស្អប់ខ្ពើមលោកដែរ តែថា ការនេះខ្ញុំពុំអាចកាត់ជំរាបបានទេចាស ម្យ៉ាងទៀត សូមលោកជ្រាបថា លោក កំពុងធ្វើខុសនឹងទំនៀមទំលាប់ផងចាស . . .

វាចាប៉ុណ្ណេះម៉ាត់ ហាក់ដូចជាឱ្យដំណឹងពិតថា នាងមិនបដិសេធរូបខ្ញុំ ទេ ខ្ញុំក៏ដូចជាឡើងសេចក្ដីសង្ឃឹមជាថ្មីវិញ ហើយទុកចិត្តថានាងគង់ស្រឡាញ់ខ្ញុំ ដែរ ។ ការពារមិនឱ្យនាងថា ខ្ញុំជាមនុស្សជួរជងខុសទំនងច្បាប់នោះ ខ្ញុំប្រញាប់ និយាយថា :

- អ្នកវី ! សូមអ្នកជឿជាក់ថា ខ្ញុំមានស្មារតីជាអ្នកថ្លៃថ្នូរជាដរាប ខ្ញុំ នឹងសូមស្ដីដណ្ដឹងអ្នកដល់មាតាបិតា ប៉ុន្តែដែលខ្ញុំហ៊ានមកនិយាយនេះគឺដោយ ប្រាថ្នាដឹងចិត្តអ្នកជាមុនតែប៉ុណ្ណោះទេ . . .

នាងនៅស្ងៀមតទៅទៀត ។ ក្លិនផ្កាដែលខ្ញុំមិនដឹងជាឈ្មោះអ្វីនោះ នៅតែចោលគន្ធពិដោរក្រអូបសាយមកទៀត ញ៉ាំងទឹកចិត្តខ្ញុំឱ្យរិតតែអណ្ដែត អណ្ដូង ហើយប្រាថ្នានាងរិតតែខ្លាំង ។ ខ្ញុំខិតទៅជិតនាង នាងនៅតែឈ្ងោកមុខ ដដែល ។

- ទេវី ! ខ្ញុំហៅនាងដោយថ្នមសម្លេង ហើយលើកដៃទាំងញ័រទៅ ចាប់ដៃនាង ។ នាងមិនបំរះទេ ខ្ញុំលើកដៃនោះមកថើប ដោយសេចក្ដីរំភើបជា បំផុត ខ្ញុំដាក់ទៅវិញក្នុងទ្រូងញ័រដោយសេចក្ដីភ័យ ខ្ញុំយល់ថានាងក៏ដូច្នោះដែរ ។ ខ្ញុំម្ដងនេះទើបដឹងច្បាស់ថា នាងមិនបដិសេធរូបខ្ញុំទេ ហើយស្រឡាញ់ខ្ញុំវិញផង ។ ខ្ញុំកាន់ស្មានាងដោយដៃម្ខាង ហើយម្ខាងទៀតទ្រចង្កានាង នាងច្រានខ្ញុំចេញ នាងងើបឈរឡើង ។ មុខនាងឡើងក្រហមតែពុំមានក្រហមដោយ សេចក្ដីខេរខឹងទេ គឺក្រហមដោយសេចក្ដីអៀនខ្មាស នាងពុំហ៊ានមើលចំខ្ញុំទេ ។ ដោយប្រាថ្នាសម្ផស្សរូបនាងនោះ ខ្ញុំអត់ទ្រាំពុំបានក៏ឈោងចាប់ដៃនាងទាញឱ្យ អង្គុយមកវិញ នាងបណ្ដោយតាម ប៉ុន្តែតាមក្នុងទំនងយឺត។ ខ្ញុំចាប់ដៃនាងច្របាច់ថ្នម ហើយលើកថើបយ៉ាងយូរ :

- ទេវីខ្ញុំ ! ខ្ញុំស្រឡាញ់ទេវីណាស់ ខ្ញុំហ៊ានស្លាប់រស់នៅទីនេះហើយ ទោះណាជាវង្សមកទាន់ហើយវង្សបាញ់ខ្ញុំសម្លាប់ ក៏សុខចិត្តដែរ . . . តើទេវី មានអាណិតខ្ញុំទេ ?

- ចាស . . .

វាចានាងពោលឡើងសឹងមិនហើបបបូរមាត់ផង តែខ្ញុំហាក់ដូចជា ច្បាស់ណាស់ ។ ដូច្នោះក៏ទាញនាងមកឱបយ៉ាងណែន នាងមុនដំបូងបំរះ តែក្រោយមកនាងបន្ទន់តាមខ្ញុំ កេសាខ្មៅរលើបរបស់នាងនៅផ្ទាប់ផ្ទាល់នឹងទ្រូងខ្ញុំ ។ អារម្មណ៍ពេលនេះជាងពេលណាទាំងអស់ ដែលធ្វើឱ្យខ្ញុំឈ្លក់ចិត្ត ។ ខ្ញុំត្រកង នាងលើកឡើងហើយផ្គង់នាសា ស្រូបថ្ពាល់នាងដោយចិត្តរំភើបផុតថ្លែង ។ ពិសម័យលាយឡំនឹង សេចក្ដីភ័យបារម្ភ ខ្ញុំសម្លឹងកែវភ្នែកនាងយ៉ាងចំ នាងក៏ សម្លឹងខ្ញុំដែរ ភួងភក្ត្រនាងក្រហមព្រឿងពោរពេញដោយសម្ផស្សតណ្ហា ។ ខ្ញុំឱនថើបនាងម្ដងទៀត :

- ទេវីអូន !

- ចាសបង ! នាងឆ្លើយដោយសម្លេងស្រាលហើយញ័រ

- បងសូមធ្វើចិត្តស្នេហាលើរូបអូន បងសុខចិត្តប្ដូររូបកាយយករូបអូន ជាគូប្រចាំជីវិតលុះត្រាតែបាន ! ទេវីជាជីវិតបង !

ខ្ញុំងើបមុខឡើង រង្វង់ភក្ត្រនាងពេលនេះខ្ញុំឃើញច្បាស់ថា ជាទេព កញ្ញាយ៉ាងសុទ្ធសាធ នាងល្អបណ្ដាច់ដែលខ្ញុំមិនដែលឃើញស្រីណាល្អស្មើ ។ ខ្ញុំ បានប៉ះពាល់រាងកាយនាង ក៏ដូចជាខ្ញុំនេះជាទេវបុត្រមួយអង្គ ទេវបុត្រដែល កំពុងមានសេចក្ដីភ្លើតភ្លើននឹងសម្ផស្សរបស់ទេវធីតា ។

មិនមែនជាការយល់សប្ដិសោះឡើយ ពេលនេះប្រាកដជាបានទេវីមក ប្រត្យក្ស ។ ខ្ញុំពោលទៅកាន់នាងដោយអង្អែលស្មានាងថ្នម :

- ទេវី ! បងសូមសារភាពចំពោះអូនថា បងស្រឡាញ់អូនស្មោះ ណាស់ កន្លែងរស់នៅរបស់បងក្នុងជាតិនេះ តោងមានរូបអូននៅជិតជាដរាប ។

- ចាស បង ! បើដូច្នោះមែនទេវីត្រេកអរណាស់ ព្រោះទេវីត្រូវ ចៀសផុតពីការអភ័ព្វ ចាស . . . ប៉ុន្តែទេវីថប់តែមិនបានដូច្នោះ ចាស . . . ទេវី មិនដែលមានសេចក្ដីស្នេហាម្ដងសោះ ដូច្នេះពេលនេះប្រសិនជាខុសបំណងនេះ ពិតជាទេវីខ្ញុំបានសេចក្ដីខកចិត្តអស់មួយជីវិតហើយចាស . . .

វាចានាងចេញមកនេះមួយៗ ទ្រង់តានតឹង ខ្ញុំប្រញាប់ញ៉ាំងនាងឱ្យ សប្បាយឡើងវិញ ។

- ទេវី ! សេចក្តីស្នេះរបស់បងចំពោះទេវី បើសិនជាអាចពុះទ្រូងយក ចេញមកបាន បងនឹងពុះភ្លាម តែនេះធ្វើទៅពុំរួច ។ ប៉ុន្តែ ទេវី ! បងសូម បញ្ជាក់ថាពាក្យពេចន៍របស់បងពោលនេះ បងពោលក្រោមការមើលឃើញនៃ ទសបារមី ដែលថែរក្សាមហាប្រាសាទនេះ ប្រការណាមួយដែលបងមាន សំណាមចិត្តគិតទេវីគ្រាន់តែជាការសប្បាយទេ ប្រការនេះត្រូវតែបងទទួលទណ្ឌ កម្មយ៉ាងធ្ងន់អំពីវត្ថុសក្តិសិទ្ធិនៅទីកន្លែងនេះ ជឿបងចុះអូន . . .

ឆ្លើយតបនឹងវាចាខ្ញុំដោយញញឹម នាងមើលមុខខ្ញុំក្នុងសភាពស្ងប់ ។ ខ្ញុំឱនក្រេបសម្ផស្សភក្ត្រនាងយ៉ាងស្នេហាដ៏លើស . . . ក្លិននាងសែនក្រអូប ពិសម័យ ខ្ញុំខ្សិបដាក់ត្រចៀកនាងតិចៗថា :

ទេវីបង ! បងសង្ឃឹមថា យើងមានសុភមង្គលក្នុងអនាគត ព្រោះ យើងបានយល់ដល់ជម្រៅចិត្តគ្នាទៅវិញទៅមកហើយ ។ ទេវី បង ! បងនឹង ពឹងម្តាយ ឪពុករបស់សុវណ្ណឱ្យគេស្តីដណ្តឹងទេវីក្នុងពេលខាងមុខនេះហើយ តើ ទេវីយល់ព្រមទេ . . .

- យល់ព្រម ចាស . . . !

ចំឡើយនេះសែនទន់ភ្លន់ណាស់ ដែលធ្វើឱ្យខ្ញុំរីតតែសប្បាយខ្លាំងឡើង ខ្ញុំក្រសោបនាងពេញរង្វង់ដៃ នាងក៏លើកហត្ថទាំងគូ ប្រឱបកខ្ញុំយ៉ាងណែន ស្តន់ យុគលដ៏សែនក្បូរបស់នាងក៏បានប៉ះផ្ទាល់នឹងទ្រូងខ្ញុំ ពេលនោះហើយដែលខ្ញុំ យល់ថាធម្មជាតិនានា ដែលនៅជុំវិញយើងសុទ្ធតែជាបរិវារដែលចាំថែរក្សាខ្ញុំ និងនាង ខ្ញុំលែងខ្លាចអ្វីទាំងអស់ . . . ប៉ុន្តែសតិសម្បជញ្ញៈខ្ញុំនៅរស់រវើក និយាយរំលឹកខ្ញុំថាៈ

- ឯងកំពុងប្រព្រឹត្តខុសមួយ ដែលបើសិនជាគេទាន់គេមិនអាចនឹង អត់ឱនឱ្យបាន ឯងតែម្នាក់ឯងគត់ ដែលមកដល់ស្រុកគេ ហើយហ៊ានប្រព្រឹត្ត អំពើនេះ . . . ។ ស្របគ្នានឹងសតិសម្បជញ្ញៈនេះ ពេលនោះក៏ឮសូរមាត់រអ៊ុសៗ មក ។ ខ្ញុំភ្ញាក់លែងកាយនាងមួយរំពេចងើបមើលទៅក៏ឃើញមនុស្សមួយ គ្រួសារដើរមក គឺពួកទេសចរ ដែលគេដើរមើលប្រាសាទ ។ ខ្ញុំនិងនាងឈប់ ប្រឱបគ្នាត្រឹមនោះ ហើយដូចជាខ្មាសគ្នាទៅវិញទៅមកផង យើងងើបឈរ ឡើង ហើយមើលនាយអាយ ។ ខ្ញុំនិយាយយ៉ាងក្លាហានថា :

- សុទ្ធតែជាពួកអ្នកដើរមើលប្រាសាទទេ ពួកនោះយើងមិនស្គាល់ ឯគេក៏មិនដែលស្គាល់យើង ដូច្នេះគ្មានហេតុអ្វីដែលនាំឱ្យយើងខ្លាចនោះទេ ។

ទេវីនាងមានអាការញញឹមបន្តិចយ៉ាងសែនសម ហើយនិយាយតប នឹងខ្ញុំ

- យើងត្រូវត្រឡប់ទៅឡាន ! បងវង្សប្រហែលមកវិញហើយ ហើយលោកសុវណ្ណប្រហែលនៅចាំឯណោះផង ចាស ។

នាងលើកដៃជ្រងសក់ឱ្យមានរបៀបរៀបរយ កិរិយានាងទន់ភ្លន់ ហើយមិនរំលងទេអាការញញឹមនោះ ។ ខ្ញុំញញឹមតបវិញ :

- គ្មាននរណា គេសង្ស័យថាយើងស្រឡាញ់គ្នាទេ !

- ថាមិនបានដែរ លោកសុវណ្ណប៉ិនខាងសង្កេតណាស់ បងមិនឃើញ ទេឬ គាត់និយាយឱ្យយើងសឹងតែចំៗតែម្តង ខ្ញុំខ្មាសគាត់សឹងអីចាស. ដូចជានៅ ក្នុងរោងកុន នៅកន្លែងកំពុងញ៉ាំបាយនោះ នៅកន្លែងអណ្តូងប្រេងជាដើម គាត់ ថាឱ្យយើងសុទ្ធតែត្រូវគ្នាសុទ្ធតែអី ។ ហើយម្តងនេះ បាត់យូរដូច្នេះផង ចាំមើល គាត់ថា . . .

- ប៉ុន្តែ បងពេញចិត្តនឹងពាក្យលេងសើចរបស់សុវណ្ណណាស់

- មែនហើយ តែខ្ញុំវាខ្មាសណាស់ ចាស

នាងវាចាហើយក៏សន្សឹមជំហានទៅ ខ្ញុំក៏តាមនាងដែរ ។ ដោយ សេចក្តីស្នេហា ខ្ញុំកាន់ដៃនាងយ៉ាងរីករាយតែភ្នែកយើងរមែងរំពៃមើលក្រែង សុវណ្ណ ឬក៏វង្សគេដើរមក ។ យើងមិនបានជួបនឹងអ្នកទាំងពីរទេ យើងជួបតែ ពួកកទេសចរ ពួកនេះយើងគ្មានខ្លាចគ្មានខ្មាសអ្វីសោះ ហើយខ្ញុំសង្កេតឃើញថា មានពួកទេសចរខ្លះនៅកម្លោះ ក្រមុំបានមើលមកយើងទ្រង់ច្រណែន ។ យើង គ្មានកង្វល់អ្វីនឹងពួកនេះទេ ចេះតែដើរទៅមុខជាធម្មតា ។ ផុតពីកំពែងមួយ នោះស្រាប់តែឃើញសុវណ្ណដើរមកដោយមានកាន់ឈើមួយមែកផង ។ យើងក៏ ដើរឃ្លាតពីគ្នាទៅវិញ ។ សុវណ្ណមកដល់ហើយសើចញញឹមញញែម :

- យី ! ឯងមើលពីចម្ងាយមកស្មានតែគួសង្ឃាណោ ? ឯងខំច្រណែន បន្តិច មិនដឹងជាអ្នកវីនឹងចរណៃសោះ ។ យីសមគ្នាណាស់ លោកអើយ ! ណេះ ខ្ញុំសូមជូនផ្កាវំដួលនេះមួយមែក !

ហើយហុចផ្កា ដែលខ្ញុំមើលពីចម្ងាយមកស្មានថាជាមែកឈើនោះមក ឱ្យនាង ។ ទេវីខ្មាសឡើងក្រហម

- ដឹងជាស្អីទេ លោកសុវណ្ណឯងផ្តេសផ្តាសណាស់ ...

- ផ្តេសផ្តាសម៉េច ខ្ញុំជូនជាកិត្តិយស ដល់អ្នកវី ព្រោះខ្ញុំឃើញ អ្នកវី សមគ្នានឹងចរណៃណាស់ !

សងវាចានេះទេវិញធ្វើឱ្យនាងរិតតែក្រហមមុខ នាងទទួលផ្កានោះ ហើយក៏យារវាយសុវណ្ណមួយរំពេច តែសុវណ្ណរហ័សគេចទាន់រត់ទៅឈរឆ្ងាយ ពីនោះ ។

- យើ ! កាចណាស់អ្នកវីខ្ញុំ បានភ្ញៀវថ្មីលេងសុទ្ធតែធមិ វាយតបតែ ម្តង . . .

នាងសើចទាំងខាំមាត់ ហើយនិយាយបែបនឹងធឹងតបទៅ សុវណ្ណ :

- កុំនិយាយលេងច្រើនលោកសុវណ្ណ ប្រយត្ន័ខ្ញុំប្រាប់បង វង្សណ៎ា ! . . .ហើយឥឡូវមកណេះខ្ញុំសួរបន្តិច !

សុវណ្ណដើរចូលមករកនាងធ្វើកិរិយាត្រុន១ ដូចខ្លាច នាងញញឹមសួរ យើង ។

- បេះផ្កាវំដួលនេះពីណាមក ?

- ខ្វះណាស់ផ្កាវំដួលពេញតែព្រៃ ចង់បានប៉ុន្មានក៏ខ្ញុំរកជូនបានដែរ ប៉ុន្តែម្តងណេះខ្ញុំជូនតោងតែឈរទទឹមគ្នាទាំងពីរនាក់ទៅ ហើយទទួលផ្កាពីខ្ញុំ ។

- ណ្ហើយ ! ឈប់និយាយលេងច្រើនទៅ ទៅយើង ទៅឡាន ! លោកសុវណ្ណឯងទើបមកពីឡានឬ ?

- ហ្នឹងឯង ទើបតែបញ្ចូលកង់កៅស៊ូថ្មីជាមួយនឹងវង្សរួចអម្បាញ់មិញ ទៅបើដូច្នោះព្រោះល្ងាចណាស់ហើយ ។

បន្ទាប់នឹងការនិយាយគ្នានេះ សុវណ្ណក៏ដើរនាំមុខទៅ ។ នាងទេវីដូច ជាមិនមានសេចក្តីខ្មាសនាងហុចផ្កាមកឱ្យខ្ញុំ ។

- នេះឯង គេហៅថាផ្កាវំដួល លោកដែលស្គាល់ទេ ចាស ?

- បានឮតែគេហៅឈ្មោះពុំដែលស្គាល់ទេ ទើបតែស្គាល់ម្តងនេះទេ ។

ខ្ញុំឆ្លើយដោយទទួលផ្កានោះមកកាន់ ហើយដើរទៅតាមគេតទៅ ។ សុវណ្ណងាកមកនិយាយនឹងខ្ញុំ

- នែ ! ចរណៃ ផ្កានេះក្រអូបណាស់ ពេលល្ងាចក្រអូបផ្កានេះពេញ ព្រៃនេះដូចជាក្លិនចេកនួនទុំអីចឹង ។ កាលគេអស់កម្លាំងគេបានធុំក្លិនផ្កានេះ ក៏ នឹងមានកម្លាំងឡើងវិញព្រោះក្រអូបបែបត្រជាក់

- អីចឹងហើយ កាលនៅក្នុងព្រៃជាមួយអ្នកវី ខ្ញុំធុំក្លិនផ្កានេះ ខ្ញុំមិន ដឹងជាផ្កាអី មិនហ៊ានសួរអ្នកវី . . .

យី ! គិតទៅក្នុងព្រៃនេះមានទីកន្លែងឱ្យសប្បាយដែរហ្ន៎ ខ្ញុំមិនភ្លេចទេ ទៅភ្នំពេញវិញខ្ញុំនឹងឱ្យគេតែងចម្រៀងមួយបទសរសើរពីទីដ៏មនោរម្យនេះ . . . ។

ខ្ញុំពោលដោយមើលមុខនាងទេវី ដែលនាងសម្លក់មកដែរ ធ្វើឆ្លើយ ។ យើងបានដល់រថយន្ត ។

វង្សនិយាយយ៉ាងរាក់ទាក់ថា :

- យើងអស់បានមើលប្រាសាទឯទៀតហើយ ព្រោះត្រូវត្រឡប់ទៅ ផ្ទះវិញ ប៉ុន្តែចាំខែក្រោយ ឆ្នាំក្រោយទៅដែល មិត្តមានពេលមកទៀតមិនថាអី ចឹងឬ ?

- បាទ ខ្ញុំក៏បានមើលអស់ចិត្តហើយដែរ ឥឡូវយើងទៅផ្ទះ ព្រោះ ល្ងាចណាស់ហើយកុំឱ្យលោកអ៊ំគាត់ទន្ទឹង ។

បន្ទាប់មកយើងនាំគ្នាឡើងរថយន្ត ហើយចាប់ចេញដំណើរសំដៅមក ទីក្រុងសៀមរាប ។ ខ្ញុំនឹកអណ្តែតអណ្តូងក្នុងចិត្ត សកម្មកិរិយាដែលខ្ញុំបានធ្វើ កាលនៅក្នុងព្រៃនោះ ហាក់ដូចជាប្រគល់សេចក្តីស្រមៃដល់ខ្ញុំជាដរាប ។ ខ្ញុំ សប្បាយចិត្តណាស់ចំពោះគោលបំណងរបស់ខ្ញុំដែល

សម្រេចនេះ ។ ដោយ សប្បាយពេកទៅ ខ្ញុំថ្លែងអំណរគុណតែម្នាក់ឯងចំពោះវត្ថុពិសិដ្ឋនានា ដែលជួយប្រទានវាសនាខ្ញុំឱ្យបានជួបនាងទេវី ហើយស្រឡាញ់នាងបានដូច្នេះ ។ ពេល នោះសុវណ្ណ ងាកមកនិយាយកាត់មនោគតិខ្ញុំថា :

- ល្ងាចនេះ គ្នាសូមឱ្យចរណៃឯងទៅគេងផ្ទះគ្នាបានមួយយប់ ប្រយោជន៍ឱ្យលោកពុកអ្នកម្ដាយគ្នាស្គាល់ឯងផង គ្នាបានជំរាបគាត់ហើយ !

ខ្ញុំគិតបន្តិចក៏យល់ថា ត្រូវតែទៅគួរសមនឹងគ្រួសាររបស់សុវណ្ណផងដែរ ក៏មិនជំទាស់នឹងសេចក្ដីហៅនេះទេ ខ្ញុំងក់ក្បាលទទួលថា អើ !

- លុះរថយន្តទៅដល់សណ្ឋាគារ វង្សនិងសុវណ្ណក៏ចុះ ឯខ្ញុំក៏ដូច្នោះដែរ ។ វង្សចាប់ដៃខ្ញុំនិងសុវណ្ណរលាក់បន្តិចជាសញ្ញាមិត្តភាព នៃការលាគ្នា ។ ឯនារី ទេវី នាងក៏លាខ្ញុំដោយលើកហត្ថទាំងគូ ប្រណម្យពីក្នុងឡានមកដែរ ខ្ញុំក៏រហ័ស តបទៅនាងវិញ ។

ខ្ញុំនិងសុវណ្ណឡើងទៅលើសណ្ឋាគារ ។ ខ្ញុំរៀបចំប្រដាប់ប្រដា រួចក៏ចុះ ពីរនាក់សុវណ្ណមកវិញ យើងហៅរ៉ឺម៉កមួយមកជិះ ។

ក្នុងដំណើរកាត់ថ្នល់ដ៏ខ្វាត់ខ្វែងជាច្រើន ក៏បានមកដល់នៅមុខគេហ ដ្ឋានមួយត្រង់មាត់ស្ទឹង ។

- នេះមកដល់ផ្ទះគ្នាហើយ

សុវណ្ណនិយាយដោយហួតលុយឱ្យថ្លៃរ៉ឺម៉កផង ។ បន្ទាប់មកគេនាំខ្ញុំ ចូលទៅ ។ ពេលនេះភ្លើងភ្លឺព្រោងព្រាតហើយ ។ ឡើងទៅលើផ្ទះខ្ញុំប្រញាប់ សំដែងសេចក្ដីគោរព គួរសមដល់មាតាបិតារបស់ សុវណ្ណដែលគេនេះបានណែ នាំខ្ញុំឱ្យស្គាល់ :

- ជំរាបសួរលោកអ៊ំ

- បាទ លើកដៃថ្វាយព្រះ ។

គេហជនទាំងពីរ ជាមាតាបិតារបស់សុវណ្ណមានវ័យយល់ប្រហែលគ្នា នឹងមាតាបិតារបស់នាងទេវីដែរ ។ លោកអ៊ំប្រុសជាម្ចាស់ផ្ទះនោះនិយាយឡើង ថា :

- ខ្ញុំខំតែទន្ទឹងផ្លូវ ព្រោះសុវណ្ណគេប្រាប់ថាគេនឹងអញ្ជើញលោកក្មួយ មកសំរាន្តឯណេះមួយយប់ !

- បាទ លោកអ៊ំ !

- បាទ ការនេះត្រូវតែអញ្ជឹងហើយ រាប់អានគ្នាត្រូវតែបានដេកបើ មិនបានអី មួយយប់ទៅចុះសិមទៅវិញទើបសម ។

- បាទ លោកអ៊ំ ។

ខ្ញុំឆ្លើយដោយដាក់មុខចុះ ឯលោកអ៊ំស្រីដែលក្បែរនោះក៏ឧទានឡើង ថា ។

- ហើយឥឡូវ សុវណ្ណនាំលោកក្មួយទៅងូតទឹកសិនទៅ ហើយញ៉ាំ បាយ . . .

សុវណ្ណនាំខ្ញុំទៅផ្លាស់សំលៀកបំពាក់នៅបន្ទប់របស់គេ មួយសន្ទុះ ក្រោយមកទើបងូតទឹក ។ ខ្ញុំសង្កេតឃើញម្ដាយឪពុករបស់ សុវណ្ណ គាត់រាក់ ទាក់នឹងខ្ញុំណាស់ ។ ពេលដែលខ្ញុំចុះងូតទឹកនោះ លោកអ៊ំប្រុសចុះមកនិយាយ លេងទៀត ។

- នែ ! លោកក្មួយ នៅខាងក្រោយនោះគឺជាទ្រើងទំពាំងបាយជូរ តែ ដូចជាគ្មានផ្លែសោះ ឬមកពីដីស្រុកនេះគ្មានជង្ហើមទឹកក៏មិនដឹង ខ្ញុំដាក់ពាងទឹក ជិតគល់ហើយនៅតែមិនល្អទៀត ។

- ចុះ ភ្សៀវ គូលែន សាវម៉ាវ សីរមាន់ អី១ នោះគេដាំឯណាលោកអ៊ំ ?

- អូ ! អានោះឯងគេដាំងជើងភ្នំឯណោះ . . .

ងូតទឹករួចឡើងមកវិញ ក៏ឃើញនៅកណ្ដាលផ្ទះតុអាហាររៀបចំជា ស្រេច ។ ពេលនោះ គាត់ទាំងពីរនាក់ហៅខ្ញុំដោយគួរសមឱ្យចូលអាស្រ័យ ។ ក្នុងពេលបាយនោះអ្នកម្ចាស់ផ្ទះនេះ សាកសួរខ្ញុំគ្មានធុញទ្រាន់ទេ ។ លោកអ៊ំ ប្រុសផ្ដើមឡើងថា :

- ម៉េចលោកក្មួយ សប្បាយទេចូលឆ្នាំស្រុកនេះ ។

- បាទ សប្បាយណាស់លោកអ៊ំ !

- លោកក្មួយបានដើរមើលប្រាសាទណាខ្លះ ?

- ឃើញប្រាសាទច្រើនណាស់រាប់ពុំអស់ទេ លោកអ៊ំ !

- ហើយប្រាសាទណាល្អជាងប្រាសាទណា ?

- ល្អដូចតែគ្នាទេ តែខ្ញុំអស្ចារ្យនឹងប្រាសាទមួយនោះ ដែលមានសុទ្ធ តែក្បាលព្រហ្ម ដែលគេហៅថាបាយ័ននោះ ។

- អូ ! ក្មួយឯងច្រឡំហើយ ពុំមែនមុខព្រហ្មទេ គឺមុខព្រះពោធិ៍សត្វ ឈ្មោះលោកកេស្វរៈ ។ ពោធិសត្វនេះនៅក្នុងជំនឿព្រះពុទ្ធសាសនាផ្នែកមហា យាន ។

- បាទ ! ខ្ញុំយល់តែព្រហ្ម១ ប៉ុណ្ណោះលោកអ៊ំ ។

- បាន តែលោកក្មួយគោងចំណាំថា ប្រាសាទណាដែលមានមុខ៤ ដូច ជាបាយ័នក្តី ប្រាសាទនោះគេសាងឧទ្ទិសចំពោះព្រះពុទ្ធសាសនាលទ្ធិមហាយាន ទាំងអស់ ។

- បាទ !

គេហជនស្រីដែលស្តាប់ការសន្ទនានេះដែរ កាលបើលោក អ៊ំប្រុសចប់ គាត់ក៏ចាប់បន្តឡើងថា :

- ហើយលោកក្មួយ បានពេញចិត្តនិងក្រមុំស្រុកសៀមរាបនេះទេ ?

សំនួរនេះខ្ញុំតបពុំកើត ។ រាល់គ្នាក៏សើចឡើង ។ បន្ទាន់នោះ សុវណ្ណ អារកាត់ឡើងថា :

- ម៉ែ ! មិត្តខ្ញុំនេះនិងទេវីសមគ្នាចំណាប់ម៉ែ ! ខ្ញុំគិតឱ្យមិត្តនេះគេ ដណ្តឹង ទេវី ម៉ែ !

- អើមែន ! ក្មួយឯណេះរាងសុភាពសមនឹងក្មួយទេវីមែន ពេញចិត្ត នឹងកូនគេនោះទេក្មួយ ?

ខ្ញុំមិនតបទេតែក្នុងចិត្តដូចជាចង់ថា " ពេញចិត្ត " យ៉ាងភ្លាម ។

ពេលបរិភោគបាយចប់រួចរាល់ អ្នកម្ចាស់ផ្ទះក៏ចាប់សន្ទនា និងខ្ញុំពីជីវ ភាពនៅភ្នំពេញ ពីនេះពីនោះដោយបោរី ។ ខ្ញុំយល់ថាគេរាប់អាចខ្ញុំដូចជាបង ប្អូនកូនចៅគេយ៉ាងនោះ ។ ខ្ញុំដូចជាមាននិស្ស័យនឹងអ្នកសៀមរាបនេះតែម្តង តែតាមការពិត ខ្ញុំបានដឹងខ្លួនថា ខ្ញុំជាភ្ញៀវរបស់គេ ក៏គោងតែគេគួរសមដូច្នោះ ហើយ ។ នាទីចុងក្រោយមិត្តខ្ញុំ សួរខ្ញុំ

- ចរណៃឯងគិតទៅភ្នំពេញម៉ោងប៉ុន្មាន ? ឡានមានចេញ ម៉ោង ៦-៩-១២ !

- គ្នាគិតទៅម៉ោង ៦ ចុះ

- តែវាដូចជារួសរាន់ពេក ! ណ្ហើយ ទៅម៉ោង ៩ ចុះ ក្រែងឯងត្រូវ ឆ្លៀតទៅជំរាបលាអ៊ំចៅហ្វាយស្រុក និង វង្ស ផងឬ ? ហើយក្រែងទេវីផ្តាំនេះ នោះផង មិនអីចឹងឬ ?

ចំពោះសំដីនេះខ្ញុំមិនតបទេគ្រាន់តែញឹម១ ។ សុវណ្ណនាំខ្ញុំចូលបន្ទប់ ដេករបស់គេ ។ យើងនាំគ្នាទទួលទានដំណេក មិត្តខ្ញុំមិនបានប៉ុន្មាននាទីផង ក៏ លេចសូរស្រមុកតែម្តង ។ ខ្ញុំខំសំងំយកលក់តាមគេ តែពុំបានសម្រេចដោយ ងាយឡើង យូរម៉ោងក្រោយមកទើបខ្ញុំលក់ទៅដែរ ។

ព្រឹកឡើងហើយ ។ ខ្ញុំក៏ជំរាបលាអ្នកម្ចាស់ផ្ទះទាំងពីរនាក់ ដោយ សេចក្តីគួរសមជាទីបំផុត ។ សុវណ្ណមិត្តខ្ញុំបានជូនដំណើរខ្ញុំមកផ្សារ ដើម្បីទិញ សំបុត្រឡាន ។ នៅតុគុយទាវមិត្តនេះចាប់ពិភាក្សា :

- ចរណៃ ឯងមាននិយាយនឹងនាងទេវីទេ ?

- មាន ! តែនិយាយធម្មតា គ្មានចូលរឿងស្នេហាអីទេ ។

- ឯងល្មមស្មានបានថា នាងចូលចិត្តឯងទេ ?

- គ្នាមិនអាចស្មានបានថា ព្រោះគ្នាមិនមែននៅក្នុងពោះនាង ទេវី ឯ ណា . . .

- អីចឹងហើយ ប៉ុន្តែយ៉ាងណាក៏អាចឱ្យយើងស្មានបានដែរថា នាង ចូលចិត្តឬមិនចូលនោះ ឯគ្នា គ្នាជឿជាក់ថា ទេវីពិតជាចូលចិត្តនឹងឯង ពិតជា ស្រឡាញ់ឯងផងក៏មិនដឹង ។ ដូច្នេះឯងគិតយ៉ាងណា ដើម្បីសម្រេចរឿងនេះ ?

- គ្នាគិតដូចឯងបានគិតឱ្យគ្នានោះ គឺថាគ្នាត្រូវពឹងពាក់លើលោកអ៊ំ ដែលជាម្ដាយឪពុករបស់របស់មិត្តឯងនោះហើយ ។

- ហ្នឹងឯង ត្រូវតែសូមឱ្យគាត់ជួយទើបកើត ។ គ្នាជឿជាមុនថា រឿង នេះនឹងសម្រេចមិនខាន លោកអ៊ំចៅហ្វាយស្រុកបានឃើញអំពើរបស់ឯងហើយ ហើយការងាររបស់ឯងគួរសមល្មមដូច្នេះផង ក៏គ្មានអ្វីនាំឱ្យគាត់ទុកទើវដល់ណា ទៀតដែរ . . . ឥឡូវឯងគិតទៅលាគាត់យកគួរសមផងទៅ ព្រមទាំងទើវីផង មុននឹងទៅភ្នំពេញវិញនេះ ។

- ហ្នឹងហើយ ! ហើយក្នុងរវាងមួយខែពីរទៀតសឹមគ្នាគិតរឿងនេះ ព្រោះថាទៅភ្លាមមកគិតភ្លាមដូចជាមិនសមសោះ យើងត្រូវពន្យាពេលបន្តិច !

- ហ្នឹងឯង ! ប៉ុន្តែ តិចលោមានគេឯណាមកដណ្ដឹងមុនទៅ នាំឱ្យខក . . . ព្រោះអីទើវីមានគេចង់បានច្រើនណាស់ កុំពន្យារពេលឆ្ងាយពេក ។

- ទេ ប្រថុយយ៉ាងនេះទៅចុះ បើនាងជាគូរបស់គ្នាមែន នាងមិនទៅ ណាទេ គ្នាជឿវាសនាហើយ !

សុវណ្ណបែរជាសើច ហើយតបថា :

- មែនហើយ ពន្យារក៏ពន្យារសិនចុះ ព្រោះថារដូវនេះក្ដៅ ណាស់ការ ដល់ទៅខែកត្តិកនោះវាត្រជាក់ស្រួល យី ! គិតយ៉ាងនេះល្អម្យ៉ាងដែរ ។ ខ្ញុំសើចតិចៗតាមសុវណ្ណ ។

ក្រោយពេលបរិភោគគុយទាវ និងសន្ទនាគ្នាយ៉ាងនោះហើយ សុវណ្ណគេលាខ្ញុំទៅផ្ទះវិញ ដោយទុកពេលឱ្យខ្ញុំឆ្លៀតទៅគួរសម និង គ្រួសារទើវី ។

ខ្ញុំឡើងរ៉ឺម៉កទៅផ្ទះអតីត ចៅហ្វាយស្រុក ។ គេហជនទាំងអស់ ទទួលខ្ញុំដោយរាក់ទាក់ ។ ខ្ញុំជំរាបលាគាត់ :

-លោកអ៊ំប្រុស អ៊ំស្រី ខ្ញុំបាទសូមលាទៅភ្នំពេញថ្ងៃនេះហើយ

-បាទ សូមលាលោកក្មួយ អញ្ជើញទៅឱ្យបានសុខសប្បាយ ! ខ្ញុំមិនភ្លេចគុណលោកក្មួយទេ កុំតែបានលោកក្មួយខ្ញុំដឹងជាយ៉ាងណាទេ ។

-បាទ មិនជាអ្វីទេ

-នែ ! លោកក្មួយ ថ្ងៃក្រោយបើមកសៀមរាបទៀតឆ្លៀតចូល មកលេងនឹងអ៊ំផង ។

លោកអ៊ំស្រីនិយាយឡើងទំនងស្មោះ ។ ខ្ញុំក៏ទទួលបាទ តបទៅ គាត់វិញដោយគោរព វង្សនិយាយឡើងថា :

-ខ្ញុំទៅភ្នំពេញ ខ្ញុំនឹងទៅលេងផ្ទះមិត្តឯងមិនខាន ...

-បាទ ខ្ញុំនឹងទទួលមិត្តដោយរីករាយ ខ្ញុំមិនភ្លេចទេ គុណមិត្ត ដែលបាននាំខ្ញុំឱ្យស្គាល់អង្គរ ឥឡូវខ្ញុំលាសិនហើយ ហើយរង់ចាំមិត្តទៅ លេងបុណ្យអុំទូកសំពះព្រះខែនៅឯភ្នំពេញ ...

-បាទ ! អញ្ជើញតែខ្ញុំជូនឡានទៅ !

-ទេទេ ! រ៉ឺម៉កនៅចាំឯខាងក្រៅហើយ

-អញ្ជើញចុះសុខសប្បាយ ។

ខ្ញុំឡើងរ៉ឺម៉កមកចំណតរថយន្តវិញ ។ ខ្ញុំឆ្ងល់ណាស់ព្រោះបាត់ នាងទេវីមិនឃើញ តើនាងពួនខ្ញុំដោយខ្មាសអៀន ព្រោះរឿងអ្វី ? ស្តាយ ណាស់មិនបានឃើញមុខនាង ។ ខ្ញុំមកដល់ចំណតឡាន ក៏ឈរវេរ៉ចាំដល់ ម៉ោង ។ មនុស្សនៅនោះច្រើនកុះករ សុទ្ធតែជាអ្នកប្រុងចេញដំណើរដូច ខ្ញុំដែរ ។

ខ្ញុំមើលទៅនាឡិកាដៃឃើញនៅមួយម៉ោងទៀត ទើបដើរទៅ អង្គុយលើកៅអីថ្ម នាមាត់ស្ទឹងក្រោមម្លប់ឈើសាខា ។ ពេលនោះស្រាប់ តែលេចនាងទេវីនាងដើរសំដៅមក ... ខ្ញុំងើបឈរទទួលនាង យើងឈរ ឃ្លាតពីគ្នា ប្រយោជន៍ជៀសវាង សេចក្តីឆ្អែប្រមាណរបស់អ្នកមើលមក ។

-បង បងអញ្ជើញទៅតឡូវឬ ?

-ពិតមែនទេវី បងត្រូវឡើងឡានទៅតឡូវហើយ ។ ទេវីព្រឹកមិញ ខ្ញុំទៅជំរាបលាលោកអ៊ំមិនឃើញអូន តើអូនទៅណា?

-ខ្ញុំមកផ្សារតាំងពីព្រឹកព្រលឹម ទិញអីវ៉ាន់ ហើយប្រយោជន៍ នឹងបានមកសួរបងផង ថាបងគិតយ៉ាងណាចំពោះរឿងយើងនោះ ។

វាចានាងមួយៗ ដោយស្រទន់ពោលមកនេះសឱ្យឃើញថានាង នៅមិនទាន់ទុកចិត្តខ្ញុំ ។ ខ្ញុំប្រញាប់ប្រាប់នាងវិញ :

-ទេវី បងបានគិតទុករួចហើយយ៉ាងនេះថា ក្នុងរវាងមួយខែពីរទៀត បងនឹងមកពឹងម្តាយឪពុករបស់ សុវណ្ណឱ្យគាត់ចូលដណ្តឹងអូន បងពន្យាពេលដូច្នេះ ព្រោះថាបើទៅភ្លាមមកគិតភ្លាមទៅវាមិនសូវសម ។ ដូច្នេះបងសូមមេត្តាអូនរង់ ចាំបងក្នុងពេលនេះ ទេវី

-ចាស ចុះគ្រួសារលោកសុវណ្ណមានថាយ៉ាងណាដែរ ?

-លោកមីង គាត់សរសើរថាទេវីល្អណាស់ ហើយចំអន់ឱ្យបង ដណ្តឹងទេវីផង ។

ដល់សំដីត្រង់នេះ ទេវីដែលនាងមានទឹកមុខស្រពោននោះ ក៏ ញញឹមស្រស់ឡើងវិញ ។

-ចុះបងឆ្លើយយ៉ាងម៉េចទៅគាត់វិញ ចាស ?

-បងឥតថាអ្វីទេ តែបងសប្បាយណាស់ ព្រោះបងដឹងជាមុនថា គាត់ នឹងទទួលពុំនឹងរបស់បងមិនខានទេ នាងញញឹមទៀត ហើយភ្នែកនាងមើលទៅគេឯងក្នុងទំនង ប្រយ័ត្ន ទើបនាងលូកយកប្រអប់តូចមូលមួយ នាងហុចប្រអប់នោះមកខ្ញុំ ដោយសំដីស្រទន់ស្រងូតស្រងាត់ថា :

-បង ! កូនប្រអប់នេះមានចិញ្ចៀនមួយវង់ និងរូបថតខ្ញុំនៅពី ខាងក្នុង ។ ខ្ញុំសូនជូនបង ជាភស្តុតាងនៃសេចក្តីស្នេហាដែលខ្ញុំបានសាង ជាមួយបង ។

វាចានេះធ្វើឱ្យខ្ញុំរំភើបផុតថ្លែង ខ្ញុំទទួលកូនប្រអប់នោះពីដៃ នាងដោយចិត្តរន្ធត់ ខ្ញុំមើលមុខនាងយ៉ាងចំដោយស្នេហាដ៏លើស ឯនាង ក៏ដូច្នោះដែរ ។

ខ្ញុំគ្មានអ្វីជាភស្តុតាងឱ្យនាងវិញទេ ក៏នឹកឃើញដល់ខ្សែកដែល កំពុងពាក់ជាប់នឹងខ្លួន ខ្ញុំត្រូវតែដោះជូននាងវិញ ។

-ទេវីអូន ! បងគ្មានអ្វីជូនអូនទេ មានតែខ្សែកមួយខ្សែនេះ ដែលជាកេរ្តិ៍របស់ម្ដាយឪពុកបង បងសូមជូនអូនសិនទំរាំបងទៅភ្នំពេញ ហើយត្រឡប់មកពឹងគេឱ្យដណ្ដឹងអូន ។ ទេវីអូន! ពេលនេះបងសូមឱ្យទេវតាដ៏មានរិទ្ធិទាំងឡាយ ដែលថែរក្សាបុរីអង្គរធ្វើជាកសិនស្នេហាយើងទាំងពីរ ។ ទេវី ! បងស្រឡាញ់ទេវីណាស់ ! ហើយបងជឿចិត្តទេវី ហើយថា ទេវីរង់ចាំបងជរាប ! មិនមែនឬទេវីអូន ?

-ចាស ប្រាកដហើយបង !

ការសាសងនេះ ដែលប្រព្រឹត្តិទៅក្នុងបរិយាកាសដ៏ស្ងប់ស្ងាត់ នោះ ត្រូវបញ្ចប់ដោយសញ្ញាហៅនៃរថយន្ត ទីន ! ទីន ! ខ្ញុំប្រញាប់ លើកវ៉ាលីយួរ

-ដល់ម៉ោងឡានចេញហើយអូន !

-ចាសបង ! អញ្ជើញខ្ញុំជូន !

ខ្ញុំនិងនាងបានទៅដល់រថយន្ត ។ ពេលនេះខ្ញុំរារែកយ៉ាងខ្លាំង ក្នុងចិត្ត ដូចជាបន់ឱ្យឡានដែលនឹងចេញនេះវាខូច ខកដំណើរទៅវិញ ដើម្បីបានផ្ដែផ្ដាំសង្សារខ្ញុំតទៅទៀត តែឡានឥតមានទាស់គ្រឿងអ្វី នីមួយទេ ម៉ាស៊ីនទៅតែញ័រយ៉ាងខ្ទរ ហើយបន្ថែមសញ្ញា ទីន យ៉ាងរន្ថើន ។មនុស្សពេញជាស្រេច ខ្ញុំងាកទៅរកទេវីដោយទឹកចិត្តស្រណោះ ខ្ញុំហុចប័ណ្ណឈ្មោះខ្ញុំទៅឱ្យនាង ហើយនិយាយតិចៗ

-ទេវី ! បើអូនត្រូវការផ្ញើសំបុត្រទៅរកបង អូនមើលតាម ប័ណ្ណនេះ ! បងលាអូនសិនហើយ !

-ចាសបង ! បងអញ្ជើញទៅឱ្យបានសុខសប្បាយ ចាស ។

ខ្ញុំដូចជាស្ទះដង្ហើមវិលវល់យ៉ាងណា ប្រាកដពេលនោះអ្នកឡានម្នាក់ស្រែកប្រាប់ខ្ញុំថា : អញ្ជើញឡើង លោក ឡាន ចេញហើយ ។ ហើយវានោះឯង កញ្ឆក់វ៉ាលីពីដៃរបស់ខ្ញុំដាក់ទៅក្នុងឡាន ។ ខ្ញុំប្រញាប់ ឡើងរថយន្តទាំងតឹងតែង ។ ឡានរំកិលទៅមុខ ... ខ្ញុំងាកមើលទៅទេវី ទៀត ឃើញនាងឈរមើលខ្ញុំ, មើលមកឡាន ទឹកមុខនាងស្រពោន ណាស់ ... ឡានបត់ចេញមកខ្ញុំខានឃើញនាងត្រឹមនោះ សេចក្ដីស្ដាយ ស្រណោះក៏កញ្ច្រោលក្នុងប្រមាត់ថ្លើមខ្ញុំ ខ្ញុំកើតអន្ទះអន្ទែងសឹងតែស្រែក ប្រាប់រថយន្តឱ្យឈប់ដើម្បីចុះទៅលានាងម្ដងទៀត ប៉ុន្តែខ្ញុំពុំអាចប្រព្រឹត្ត យ៉ាងនោះឡើយ ដោយមានសតិសប្បជញ្ញៈភ្ញាក់រលឹកទាន់ថា ត្រូវតែកាត់ចិត្តចេញពីនាងសិន ... ។ រថយន្តចេញពីទីក្រុងកាត់ស្ពាន ខ្ញុំមើល ស្ទឹងដែលហួតហែងទាំងក្ដីអាល័យ ... ។ ផុតពីទីក្រុងដល់វាលស្រែ ហើយចេះតែលឿនជាលំដាប់ ។ ខ្ញុំឥតចាប់អារម្មណ៍អ្វីទេ ស្មារតីមូលតែ ទៅលើរូបនាងទេវីតែប៉ុណ្ណោះ ។ ខ្ញុំសែនអាណិតនាងឥតអ្វីប្រៀប នាងពិតជាស្រឡាញ់ខ្ញុំមែន ។ គ្រាខាងក្រោយនេះ ដែលនាងកាត់កេរ្តិ៍ខ្មាស យកវត្ថុបញ្ជាំចិត្តមក ឱ្យខ្ញុំនេះ សឱ្យឃើញនូវទឹកចិត្តស្នេហាយ៉ាងប្តូរផ្តាច់ របស់នាងចំពោះខ្ញុំយ៉ាងប្រាកដប្រជាមែន ពិតឥតក្លែង ។

ខ្ញុំលើកយកវត្ថុនោះមកបើកមើល ក៏ឃើញចិញ្ចៀនពេជ្រមួយ វង់ និងរូបថតមួយកំណាត់ខ្លួនរបស់នាង មានមុខញញឹម ។ ខ្ញុំក្ដោប របស់ទាំងនោះក្នុងបាតដៃ ហើយមើលតែម្នាក់ឯង ។ នៅជិតខ្ញុំមានមីង ម្នាក់ ដែលគាត់ដូចជាចង់ដឹងរឿងខ្ញុំដែរ

ព្រោះគាត់ចេះតែមើលមុខខ្ញុំ ទ្រង់រាងសង្កេត តែគាត់ឥតហ៊ានសួរខ្ញុំអ្វីទេ ខ្ញុំក៏មិនត្រូវភ័យនឹងគាត់នេះដែរ គាត់សង្កេតបានថា ខ្ញុំជាមនុស្សវិកលចរិត ក៏តាមតែគាត់ទៅចុះ ។ ដល់ទីក្រុងកំពង់ធំរថយន្តឈប់ ដើម្បីឱ្យអ្នកដំណើរចុះទៅស្រស់ស្រូបអាហារថ្ងៃត្រង់ ។ ខ្ញុំចុះទៅចូលភោជនីយដ្ឋានមួយ ហើយបង្គាប់ឱ្យចិនយកបាយមក ។ ពេលទទួលទានអាហារនោះ ខ្ញុំក៏បាននឹកថាថ្មើរនេះទេវីនាងកំពុងញ៉ាំបាយ ... ។

ចេញពីទីក្រុងកំពង់ធំមកទៀត ... ម៉ោង៦ទើបមកដល់ភ្នំពេញ ។ ខ្ញុំឡើងជិះស៊ីក្លូតម្រង់មកផ្ទះ ។ បងស្រីខ្ញុំ ព្រមទាំងក្មួយតូចរបស់ខ្ញុំពីរ បីនាក់រត់មកទទួល តែខ្ញុំរហ័សនិយាយថា ឥតបានទិញអ្វីផ្ញើទេ ។ ម្ដាយធំខ្ញុំក៏ខ្ញុំមិនចូលទៅជួបគាត់ដែរ ក្រែងគាត់សួរដូច្នេះដូច្នោះនាំឱ្យរវល់ ខ្ញុំ ខ្ជិលនិយាយណាស់ ត្រូវការស្ងប់ស្ងៀមបានបន្តិច ។

យប់នោះខ្ញុំគេងមិនលក់ទេ ងើបដើរចេញពីផ្ទះសំដៅទៅយក ខ្យល់អាកាសឯមុខព្រះបរមរាជវាំង ។ រំលងមកពីរថ្ងៃខ្ញុំចូលធ្វើការវិញ ខ្ញុំដូចជាគ្មានវិញ្ញាណក្នុងខ្លួន ចេះតែភ្លេចៗ ។ ហើយជាមួយអ្នកផ្ទះខ្ញុំក៏ មិនសូវនិយាយស្ដីប៉ុន្មាន ។ ការនេះខ្ញុំមិនដឹងជាធ្វើខុស ឬត្រូវទេ ។ ខ្ញុំ គិតថា ចាំមួយខែទៀតសឹមខ្ញុំជំរាបម្ដាយធំខ្ញុំឱ្យគាត់ដឹង ។ ស្រីៗដែល ធ្លាប់ស្គាល់ទាំងប៉ុន្មានបានស្ដីបន្ទោសខ្ញុំថា ជាមនុស្សនឹងធឹងហួសពេក ក្នុងប៉ុន្មានថ្ងៃនេះ ។ នាងមន្ទាដែលឧស្សាហ៍ទាក់ទងនឹងខ្ញុំ ថ្ងៃមួយបាន ចោទយ៉ាងចំថា ខ្ញុំត្រូវស្នេហ៍ក្រមុំសៀមរាប ។ នាងឆវីក៏ដូច្នោះដែរ ថាខ្ញុំ ជាមនុស្សគ្មានព្រលឹងក្នុងខ្លួន ។ មិត្តប្រុសក៏រិះគន់ខ្ញុំយ៉ាងខ្លាំងដែរ ត្បិតគេសំគាល់បានថា ខ្ញុំជាមនុស្សខុសពីដើម ដែលរួសរាយរាក់ទាក់ ។ ខ្ញុំចេះស្ងប់ស្ងៀមតទៅ ។ ប៉ុន្តែព្រឹកមួយនោះម្ដាយធំខ្ញុំហៅខ្ញុំទៅសួរ :

-ចរណៃ ឯងវាយ៉ាងម៉េចក្នុងខ្លួន ក្នុងប៉ុន្មានថ្ងៃនេះ ?

-មិនដឹងយ៉ាងម៉េចទេលោកអ៊ំ

-គាត់សើចយ៉ាងចំអក រួចបន្ត :

-តាំងពីមកសៀមរាបវិញ ឯងប្លែកច្រើន ដេកមមើរាល់យប់ ហៅឈ្មោះទេវី ទេវី !

អញស្ដាប់ច្បាស់ មុនដំបូងអញស្មានថាហៅនាងឆវី

-វាយ៉ាងម៉េចលោកអ៊ំ ...

-វាមានយ៉ាងម៉េច ហើយអញឆ្ងល់ អញលបបើកកាបូបឯង ទៅ ក៏ឃើញស្អីនេះនែ !

គាត់លាបង្ហាញរបស់ដែលគាត់កាន់ឱ្យខ្ញុំមើល ខ្ញុំស្គាល់ជាក់ថា ជារូបថតទេវី និងចិញ្ចៀននាង ខ្ញុំក្រោកឡើងដណ្ដើមពីគាត់ តែគាត់លាក់ ខ្វៃទៅក្រោយខ្នង

-ឈប់ ! ឯងនិយាយសិនមើល ឯងស្រឡាញ់ស្រីនេះមែនឬ ?

ខ្ញុំអេះបន្តិចរួចទើបនិយាយ :

-បាទ លោកអ៊ំ ខ្ញុំស្រឡាញ់គេមែន ខ្ញុំគិតថា មួយខែទៀតសឹម ជំរាបលោកអ៊ំឱ្យគិតគូរឿងហ្នឹង !

-ចុះ ឆវីនិងមន្ថា ឯងគិតយ៉ាងណា អញគិតថា បើមិនយកមួយ ឱ្យយកមួយដែរ ឥឡូវឯងទុកគេទាំងពីរជាអ្វីទៅវិញ ។

-អត់ទុកជាអ្វីទេលោកអ៊ំ ប៉ុន្តែខ្ញុំឥតស្រឡាញ់គេទេ !

-យី ! ឯងនិយាយយ៉ាងម៉េច អញស្តាប់មិនបានទេ ថាឱ្យច្បាស់ មកមើល ?

-បាទខ្ញុំឥតស្រឡាញ់មន្ថាទេ !

-ចុះឆវី

-ខ្ញុំឥតស្រឡាញ់ឆវីទេ !

-ស្លាប់ ! មន្ថាគ្នាខំយកចិត្តយកថ្លើមឯង គោរពអញដូចម្តាយ គេទៅហើយ ទៅជាឥតត្រូវការមន្ថាទៅវិញ ហើយចំណែកឆវីទៀតក៏ អីចឹងដែរ គ្រុនរងា កោសខ្យល់ កោសអី គ្នាធ្លាប់ធ្វើឱ្យ គួរស្គាល់ចិត្តថ្លើម គ្នាដែរ មិនគួរផ្តេសផ្តាសទៅឯណាងណោះទេ ។ អញឆ្ងល់ណាស់ ម៉េច ក៏ឯងមិនស្រឡាញ់មន្ថានិងឆវី ហ:ចរណៃ ?

-បាទ ! ព្រោះមន្ថារាងធាត់ពេក ហើយនិយាយគ្រលមិនពិរោះ ស្តាប់សោះ ឯឆវីវិញមានដំណើរឱនខ្នងកំពឹស ហើយទាបជាងខ្ញុំច្រើន ហើយនិយាយច្រើនណាស់ ខ្ញុំអីចឹងហើយបានជាខ្ញុំមិនយកជាគ្ចីគ្នា ។ រីឯ ការចេះដឹងថ្នាក់ថ្នម ដឹងគួរដឹងសមនោះដូចតែគ្នាទេ នាងខ្ញុំខាងក្រោយ នេះប្រហែលជាចេះលើសមន្ថា និងឆវីទៅទៀតផង ។

-ឯងសង្កេតច្បាស់ហើយឬ ?

-ច្បាស់ហើយ ហើយសុវណ្ណមិត្តខ្ញុំដែលរៀនជាមួយខ្ញុំពីដើម នោះ គេនិយាយរឿងពិតឱ្យខ្ញុំដឹងអស់ហើយ គេថ្លៃថ្នូរណាស់ថប់តែ យើងទៅគិតគេមិនឱ្យផងក៏មិនដឹង ...

ដល់ត្រង់នេះម្តាយធំខ្ញុំនៅទ្រឹង ខ្ញុំបន្ថែមទៀតថា :

-ប៉ុន្តែខ្ញុំស្មឹមថា គេនឹងឱ្យជាប្រាកដ ព្រោះខ្ញុំបានធ្វើអំពើល្អ មួយឱ្យគ្រួសារគេ ។

-ឯងធ្វើយ៉ាងណាទើបគេស្គាល់ឯង ?

គាត់បន្ធូសម្លេងទ្រង់ស្របតាមខ្ញុំ ខ្ញុំបានអំណាចហើយក៏និយាយ ។

-លោកអ៊ំមិនជ្រាបទេឬ ការឱ្យអាហារដល់មនុស្សដែលមិន សូវឃ្លាន វាមិនបានកុសលដូចឱ្យអាហារដល់មនុស្សដែលឃ្លាននោះទេ ។ ឱ្យខោអាវដល់អ្នកដែលមានខោអាវស្រាប់នោះ វាមិនបានសកុសល ដូចដែលឱ្យខោអាវ អ្នកវណ្ណកន្ទបនោះទេ ។ ហើយការសង្គ្រោះដល់ មនុស្សដែលជិតនឹងស្លាប់ឱ្យរស់រានមានជីវិតនោះ ជាកុសលមួយយ៉ាងធំ មនុស្សដែលទទួលការសង្គ្រោះបែបនេះ តែងដឹងគុណយើងជាងអ្វីទាំង អស់ ។

ខ្ញុំបានសង្គ្រោះមនុស្សម្នាក់ដែលខ្យល់គ ក្បែរគ្នានឹងស្លាប់នៅទី ក្រុងសៀមរាប កាលដែលខ្ញុំចុះពីលើឡានទៅ ។ បុរសនេះត្រេកអរ ហើយសរសើរគុណខ្ញុំយ៉ាងច្រើន គាត់ត្រូវជាឪពុកនាងដែលលោកអ៊ំ កំពុងកាន់រូបថតនេះ ខ្ញុំស្គាល់អ្នកសៀមរាបនេះនៅពេលនោះហើយ ខ្ញុំក៏ ចាប់ចិត្តស្រឡាញ់កូនគាត់តាំងពីពេលនោះមក រឿងហ្នឹតីវាមិនវែង មិនខ្លីដូច្នេះ សូមលោកអ៊ំជ្រាប !

-អើ ស្រេចតែឯងទេ អញពុំដឹងទេ ប៉ុន្តែឯងគិតយ៉ាងណាឱ្យ មន្ថានិងឆវីត្រជាក់ចិត្តផង ។

-គិតយ៉ាងណា. ខ្ញុំមិនយកតែទាំងពីរទៅ វារួចគ្នាទៅហើយ ព្រោះថាបើយកមន្ថា ឆវីមិនសប្បាយចិត្ត បើយក ឆវីទៅ មន្ថាមិនស្រួល ។ បើយើងចោលទាំងពីរទៅ ហើយយកឯសៀមរាបឯណោះវិញទៅ វា ផុតរឿងរ៉ាវទៅហើយ ។

-អើ ម្យ៉ាងទៅដែរ អញលែងគិតគូអីហើយ ស្រេចតែឯងចុះ ហើយឯងគិតពឹងអ្នកណា ?

-បាទ ម្ដាយឪពុករបស់សុវណ្ណនោះ គាត់មុខជាទទួលសំរេចមិន ខាន លោកអ៊ំកុំព្រួយ ។

-អើ ប៉ុន្តែអញនឹងឱ្យដំណឹងទៅកំពង់ចាម ឱ្យម៉ែឯងនិងពុកឯង ដឹងក្នុងថ្ងៃនេះ ។

-បាទ តែឥឡូវឱ្យខ្ញុំសូមរបស់នោះមកវិញ ...

-ហ: យកទៅចុះ អញមិនទុកទេ

គាត់ហុចរូបថតនឹងអលង្ការនោះមកឱ្យខ្ញុំវិញ ។ ខ្ញុំទទួលដោយ ញញឹមរីករាយចូលទៅក្នុងបន្ទប់ ។

ខែក្រោយនេះខ្ញុំបានទៅសៀមរាបម្ដងទៀត ដោយខ្លួនឯង ដោយមានសេចក្ដីយល់ព្រមពីលោកឪពុក និងអ្នកម្ដាយខ្ញុំ និង ម្ដាយធំខ្ញុំ ។ ខ្ញុំទៅពឹងលោកអ៊ំដែលជាមាតាបិតារបស់សុវណ្ណ ក្នុងការស្ដីដណ្ដឹង នាងទេវី ។

ខ្ញុំត្រឡប់មកព្រះរាជធានីវិញ ហើយរង់ចាំដំណឹងរបស់សុវណ្ណ ។ ក្នុងការរង់ចាំនេះ ខ្ញុំបារម្ភក្រៃលែង ក្រែងតែ លោកអ៊ំចៅហ្វាយស្រុក ឪពុកនាងទេវី គាត់មិនព្រមឬដូច្នេះដូច្នោះ ។ មួយថ្ងៃពីរថ្ងៃ ខ្ញុំគិតថា គ្រប់ដប់ថ្ងៃ បើមិនឃើញ សុវណ្ណមកទេ ឬគ្មានសំបុត្រស្នាមអ្វីមកទេ ខ្ញុំ ត្រូវតែទៅសៀមរាបម្ដងទៀត ដើម្បីដឹងការណ៍នេះ ។

ប៉ុន្តែនៅថ្ងៃទី៣នោះ នៅការិយាល័យរបស់ខ្ញុំមានសំបុត្រអនុ សាសន៍មួយមកពីខេត្តសៀមរាប មកឈ្មោះខ្ញុំ ។ ខ្ញុំអរផង ភ័យផង ត្រឡប់មើលខាងម្ខាងទៀត ក៏គ្មានឃើញឈ្មោះអ្នកផ្ញើ ខ្ញុំប្រញាប់ហែក ភ្លាមក៏ឃើញក្រដាសស្ដើង ពណ៌កូលាប រាយអក្សរយ៉ាងល្អិត ដោយ ផ្ដើមពាក្យថា :

សៀមរាប ថ្ងៃទី ១៥ ឧសភា ឆ្នាំ១៩៦០

ជូនបងជាទីស្នេហា

ខ្ញុំកាន់សំបុត្រយ៉ាងញ័រដៃ មិនមែនសំបុត្ររបស់សុវណ្ណទេ គឺជា សំបុត្ររបស់ទេវី ! យី តទៅយ៉ាងណាទៀត ខ្ញុំប្រញាប់រំកិលភ្នែកយ៉ាង ឆាប់ទៅខាងបន្ទាត់ក្រោមតទៅទៀត ដែលមានសេចក្ដីហួរហែយ៉ាងនេះ ។

អ្នកបងជាទីស្នេហា ! ប្អូនសូមជំរាបអ្នកបងថា ប្អូនបានឃើញលោក អ៊ំប្រុស លោកអ៊ំស្រី ជាឪពុកម្ដាយលោកសុវណ្ណ មកជួបឪពុកម្ដាយរបស់ប្អូន គាត់មកស្នើការស្ដីដណ្ដឹងរូបប្អូននេះ តាមសេចក្ដីពឹងពាក់របស់អ្នកបង ។ ខ្ញុំបានលបស្ដាប់ ដោយសេចក្ដីភិតភ័យ ខ្លាចតែលោកពុក អ្នកម្ដាយខ្ញុំគាត់យល់ទាស់ អីចេះអីចុះ ប៉ុន្តែអ្នកបងអើយ លោកឪពុក អ្នកម្ដាយខ្ញុំគាត់ថា មិនអីទេ ឱ្យឪពុកម្ដាយអ្នកបងចូលមកចុះ ។

អ្នកបងជាទីស្នេហា ដូច្នេះយើងពិតជាមានវាសនាល្អហើយ ! ប្អូន សប្បាយណាស់ ក៏ប្រញាប់សរសេរសំបុត្រនេះ ជំរាបអ្នកបងឱ្យបានជ្រាប ហើយសូមផ្តាំអ្នកបងថា ឱ្យអ្នកបងប្រញាប់ជំរាបលោកឪពុក អ្នកម្តាយរបស់បងទៅ ។

ប្អូនសូមគោរពពីចម្ងាយ ចំពោះលោកឪពុក អ្នកម្តាយបង ដែល អនាគតឆាប់នេះ គាត់ក៏ជាឪពុកក្មេក ម្តាយក្មេករបស់ខ្ញុំដោយជាប្រាកដ ។

អ្នកបងសំឡាញ់ខ្ញុំអើយ ! ខ្ញុំសូមឱ្យបងអត់ទោសឱ្យខ្ញុំ ក្រែងខ្ញុំ សរសេរនេះមិនពិរោះពិសា ត្បិតពុំចេះរៀបពាក្យឱ្យល្អដូចអ្នកតែងសេចក្តីទេ កាលនៅរៀនខ្ញុំក៏មិនសូវពូកែតែងសេចក្តីទេ ។ ប៉ុន្តែខ្ញុំដឹងថា ការផ្តាំផ្ញើរបស់ខ្ញុំនេះគង់តែនឹងទូទាត់ផាត់ចោលទៅបានអាស្រ័យដោយ ទឹកចិត្តស្នេហា របស់បងចំពោះខ្ញុំមែនទេបង ?

អ្នកបងជាទីស្នេហា ! បញ្ចប់សំបុត្រនេះ ខ្ញុំសូមជូនពរបងឱ្យបានសុខ សប្បាយតទៅកុំបីឃ្លាត ។ សូមបងទទួលនូវសេចក្តីនឹករលឹកពីខ្ញុំដោយស្មោះស្ម័គ្រ ។

សេចក្តីគួរំពុគួរសូមអភ័យទោស

ហត្ថលេខា

ទេវី

គូជីវិតរបស់បង

ចំពោះសេចក្តីខាងលើនេះ ហាក់ដូចជាសន្លឹកមាសមួយសន្លឹកដែល ប្រាប់នូវសេចក្តីសម្រេចរបស់ខ្ញុំ ។ ខ្ញុំសែន អរមហាអរ ... ហាក់អណ្តែត ចេញពីក្នុងផ្ទៃនៃលិខិតនោះមក ខ្ញុំថ្នមបត់ទុកក្នុងហោប៉ៅយ៉ាងត្រឹមត្រូវ ។

រូបនាងនៅជាប់នឹងទ្រូងរបស់ខ្ញុំ នាងនៅស្ងៀមស្ងាត់ក្រោមដង្ហើម ចេញចូលរបស់ខ្ញុំ រង់ចាំឱកាសមួយដែលកម្រងវាសនាត្រូវលាតសន្ធឹង នូវគន្ធពិដោរ នៃសុភមង្គលឱ្យយើង ។

ល្ងាចនោះ ខ្ញុំយកចំបុត្រពិសិដ្ឋនោះចេញមកដាក់នៅលើខ្នើយហើយ និយាយតិចៗ ដោយសេចក្តីអាល័យលាយឡំ និងសេចក្តីសង្ឃឹមថា :

ដែនសៀមរាបជាទីស្នេហា ! អ្នកជាដែនសម្រាប់ដួងចិត្តខ្ញុំ ! ខ្ញុំនៅ ឆ្ងាយពីអ្នកប្រាកដមែន តែនិស្ស័យខ្ញុំនៅជិតអ្នកជាដរាប ... ក្នុងកាលដ៏ខ្លី ខាងមុខនេះ ខ្ញុំនឹងបានសម្រស់របស់អ្នកមកនៅជិតខ្ញុំតទៅ ។ ទេវី ជាទី ស្នេហា ! អូនជាកំពូលដួងចិត្ត តែមួយរបស់ចរណៃ !

ហើយខ្ញុំគេងសម្លឹងរូបថតទេវី និងសំបុត្រមាសនោះ ដោយទឹកចិត្ត ពិសម័យ ខ្ញុំបង្ហើរមនោរថឱ្យត្រាច់រង្គាត់ទៅកាន់ដែនដួងចិត្ត ក្នុងរាត្រីដ៏ សែនមនោរម្យនោះ ។

**ចប់ដោយបរិបូណ៍ !**